ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# វិធីសាស្ត្រនៃការសរសេរ

# តែងសេចក្តី

## សម្រាប់បឋមសិក្សា

## ថ្នាក់ទី៤ ទី៥ និងទី៦



នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១៨

# វិធីសាស្ត្រនៃការសរសេរ
# តែងសេចក្តី

## សម្រាប់បឋមសិក្សា
## ថ្នាក់ទី៤ ទី៥និងទី៦

**នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**
**ឆ្នាំ២០១៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៤៥១ **អយក.**ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## «វិធីសាស្ត្រនៃការសរសេរតែងសេចក្តីសម្រាប់បឋមសិក្សា»
## ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងកំណត់ហេតុស្តីពីកិច្ចប្រជុំសេចក្តីព្រាងឯកសារវិធីសាស្ត្រសរសេរតែងសេចក្តីសម្រាប់បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

ប្រការ ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយ «វិធីសាស្ត្រនៃការសរសេរតែងសេចក្តីសម្រាប់បឋមសិក្សា» ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦ ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការរៀន និងបង្រៀននៅតាមសាលារៀនបឋមសិក្សាចំណោះទូទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានបឋមសិក្សា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងសាលារៀនបឋមសិក្សា មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ជួន ណារ៉ុន**

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិនា.អកស.

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

# **មុខកថា**

បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់វិស័យអប់រំជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងការលើកកម្ពស់គុណភាពអប់រំ និងសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងចំណោមកំណែទម្រង់ទាំងអស់យើងឃើញថា កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោលជាចំណុចអាទិភាពបំផុតក្នុងការអភិវឌ្ឍ និងលើកកម្ពស់គុណភាពសិក្សាទាំងកម្រិតបឋមសិក្សា និងមធ្យមសិក្សា។

ផ្អែកតាមតម្រូវការសិក្សារបស់សិស្សានុសិស្ស នៅតាមសាលាបឋមសិក្សាចំណោះទូទៅ ក៏ដូចជាការកំណត់អាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីណែនាំ លេខ១៩អយក.សណន ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ស្តីពីការពង្រឹងការអនុវត្តសំណេរអក្សរផ្ចង់ ការសរសេរតាមអាន និងសំណេរតែងសេចក្តីមុខវិជ្ជាភាសាខ្មែរនៅតាមសាលារៀនចំណោះទូទៅកម្រិតអប់រំមូលដ្ឋាន ក្រុមការងារបានរៀបចំឯកសារស្តីពី«**វិធីសាស្ត្រសរសេរតែងសេចក្តី**»គឺជាការឆ្លើយតបទៅនឹងស្ថានភាពសិក្សាបច្ចុប្បន្នដែលសិស្សានុសិស្សនៅតាមសាលាបឋមសិក្សាមានតម្រូវការបន្ថែមលើការអនុវត្ត ក៏ដូចជាការផ្តល់នូវវិធីសាស្ត្រសរសេរតែងសេចក្តីបានល្អ ច្បាស់លាស់ត្រឹមត្រូវ។ ម្យ៉ាងទៀតឯកសារនេះ នឹងក្លាយជាឯកសារគោលមួយសម្រាប់ជួយគ្រូបង្រៀននូវវិធីបង្រៀនក្នុងការធ្វើគម្រោងតែង និងសំណេរតែងសេចក្តី តាមប្រភេទនីមួយៗ ដើម្បីបានជាទុនសម្រាប់បង្រៀនសិស្សានុសិស្សនៅតាមសាលាបឋមសិក្សាចំណោះទូទៅ ប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ក្នុងនាម ក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំយល់ថាឯកសារ«**វិធីសាស្ត្រសរសេរតែងសេចក្តី**»នេះពិតជាមានសារៈសំខាន់ណាស់ សម្រាប់ជួយគ្រូបង្រៀនឱ្យយល់ច្បាស់ពីវិធីសាស្ត្រសរសេរតែងសេចក្តី ព្រោះវាជាមូលដ្ឋានមួយ ជួយគ្រូបង្រៀនក្នុងការស្វែងយល់បន្ថែមនូវវិធីសាស្ត្រសរសេរអំពីប្រការមួយចំនួន ដែលគួរចៀសវាងក្នុងការសរសេរតែងសេចក្តី លំណែនាំទូទៅអំពីគម្រោងតែងសេចក្តី ប្រភេទតែងសេចក្តី ឧទាហរណ៍មួយចំនួនដោយមានគម្រោងតែង និងសេចក្តីអធិប្បាយជាឧទាហរណ៍ងាយបង្រៀនសិស្សឆាប់យល់ ចេះ ចាំ និងអនុវត្តបានទៅតាមក្បួនខ្នាត ឬវិធីសាស្ត្របានត្រឹមត្រូវ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា ឯកសារនេះ នឹងជាជំនួយស្មារតីយ៉ាងសំខាន់ក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតែងសេចក្តី និងបានជាគុណប្រយោជន៍ច្រើនចំពោះលោកគ្រូ អ្នកគ្រូ ដើម្បីពង្រឹងសមត្ថភាពសំណេរតែងសេចក្តីដល់សិស្សានុសិស្សឱ្យមានសមត្ថភាព និងជំនាញក្នុងការសរសេរតែងសេចក្តីបានល្អ ហើយស្របតាមកម្មវិធីសិក្សាដែលបានកំណត់ និងសម្រេចលទ្ធផលល្អ ជាទីគាប់ប្រសើរថែមទៀតផង។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

# បញ្ជីរាយនាមគណៈកម្មការ

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ឯកឧត្តមបណ្ឌិត ណាត ប៊ុនរឿន

ឯកឧត្តមបណ្ឌិត អ៊ឹម កុច

លោកជំទាវ ទន់ សាអ៊ីម

ឯកឧត្តម រស់ សាលីន

## គណៈកម្មការនិពន្ធ

លោក អោ សៀម

លោក យិន ធី

លោក យ៉ង់ កំស៊ាន

លោកស្រី ម៉ៅ តាន់ណារី

លោក ព្រៃ សំបូរ

លោក ងិន សុតារា

លោកស្រី វ៉ាន់ សុភី

លោកស្រី ផាន់ សុជាតា

លោក វ៉ិត សុខខេង

លោកស្រី សេង ពិសិដ្ឋនារី

## គណៈកម្មការពិនិត្យ

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ឯកឧត្តមបណ្ឌិត ណាត ប៊ុនរឿន

ឯកឧត្តមបណ្ឌិត អ៊ឹម កុច

លោកជំទាវ ទន់ សាអ៊ីម

ឯកឧត្តម ពុត សាមិត្ត

បណ្ឌិត ម៉ុក សារ៉ុម

## គណៈកម្មការបច្ចេកទេសកុំព្យូទ័រ

លោក លឹម សុត្ថារិទ្ធ

កញ្ញា ឈុន សុរិយា

# មាតិកា

ទំព័រ


**បញ្ជីរាយនាមគណៈកម្មការ** ..... i
**មាតិកា** ..... ii
**អារម្ភកថា** ..... iii
**សេចក្តីផ្តើម** ..... 1
**វិធីសាស្ត្រសរសេរតែងសេចក្តី** ..... 2
**១- តើអ្វីទៅដែលហៅថា វិធីសាស្ត្រសរសេរតែងសេចក្តី?** ..... 2
**២- ប្រការគួរចៀសវាងក្នុងការសរសេរតែងសេចក្តី** ..... 2
**៣- ការណែនាំអំពីគម្រោងតែងសេចក្តីបែបពណ៌នា** ..... 3
**៤- គម្រោងតែងសេចក្តីបែបពណ៌នា** ..... 3
**៥- ប្រភេទតែងសេចក្តី** ..... 3
**៦- គោលបំណង** ..... 4
**៧- តែងសេចក្តីបែបពណ៌នា** ..... 4
៧.១- ប្រធានពណ៌នាអំពីមនុស្ស ..... 5
៧.២- ប្រធានពណ៌នាអំពីសត្វ ..... 11
៧.៣- ប្រធានពណ៌នាអំពីវត្ថុ ..... 23
៧.៤- ប្រធានពណ៌នាអំពីរុក្ខជាតិនិងផ្លែឈើ ..... 29
៧.៥- ប្រធានពណ៌នាអំពីទេសភាព ..... 35
៧.៦- ប្រធានពណ៌នាអំពីទីកន្លែង ..... 45
៧.៧- ប្រធានពណ៌នាអំពីព្រឹត្តិការណ៍ ..... 50
៧.៨- ប្រធានពណ៌នាបែបនិទានរឿង ..... 54
៧.៩- ប្រធានសរសេរសំបុត្រសួរសុខទុក្ខ ..... 57
៧.១០- សំណេរពាក្យសុំផ្សេងៗ ..... 63
**បំណែងចែកខ្លឹមសារ និងប្រធានបទតែងសេចក្តី** ..... 71

# អារម្ភកថា

ដើម្បីពង្រឹងនិងលើកកម្ពស់ការសិក្សាភាសាខ្មែរ ពិសេសផ្នែក សំណេរតែងសេចក្តី កម្រិតបឋមសិក្សា ចំណេះទូទៅឱ្យមានគុណភាពនិងប្រសិទ្ធភាព។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការដើម្បីអភិវឌ្ឍឯកសារ "**វិធីសាស្ត្រសរសេរតែងសេចក្តី**" ដើម្បីជាជំនួយក្នុងការរៀន និងបង្រៀនតែងសេចក្តី ដែលជាមូលដ្ឋានក្នុងការជួយលោកគ្រូអ្នកគ្រូនិងអ្នកសិក្សា ជាពិសេសប្អូនៗសិស្សានុសិស្សដែលត្រូវ បន្ត ការសិក្សាជាបន្តបន្ទាប់រហូតទទួលបានជោគជ័យក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។

ឯកសារនេះមានបង្ហាញផ្នែកសំខាន់ៗមួយចំនួនដូចជា៖

- តើអ្វីទៅហៅថាវិធីសាស្ត្រសរសេរតែងសេចក្តី
- ប្រការគួរចៀសវាងក្នុងការសរសេរតែងសេចក្តី
- ប្រភេទនៃតែងសេចក្តី
- គោលបំណង
- តែងសេចក្តីបែបពណ៌នា
- គម្រោងតែង
- ឧទាហរណ៍និងសេចក្តីពណ៌នា
- អត្រាពិន្ទុ។

គោលគំនិតសំខាន់នៃឯកសារនេះគឺចង់ឱ្យលោកគ្រូ អ្នកគ្រូ បង្រៀនសិស្សានុសិស្សទាំងផ្នែកទ្រឹស្តីខាងដើមនៃឯកសាររហូតដល់ការហ្វឹកហាត់ឱ្យសិស្សសរសេរបានត្រឹមត្រូវ ញឹកញាប់ ផ្អែកតាមឧទាហរណ៍និងលំហាត់អនុវត្តជាក់ស្តែង។

គណៈកម្មការនិពន្ធសង្ឃឹមថា ឯកសារ "**វិធីសាស្ត្រសរសេរតែងសេចក្តី**" នេះមានប្រយោជន៍សម្រាប់លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សក្នុងការបង្រៀននិងរៀនផ្នែកសំណេរតែងសេចក្តីដោយមានសមត្ថភាពសរសេរច្បាស់លាស់ ព្រមទាំងរួមចំណែកលើកកម្ពស់សមត្ថភាពសិស្សក្នុងការប្រើប្រាស់ភាសាខ្មែរបានត្រឹមត្រូវ។

**គណៈកម្មការនិពន្ធ**

# សេចក្តីផ្តើម

ឯកសារ "វិធីសាស្ត្រសរសេរតែងសេចក្តី" សម្រាប់ថ្នាក់ទី៣ដល់ទី៦នេះបានរៀបចំឡើងដើម្បីជួយគ្រូ ក្នុងការពង្រឹងសមត្ថភាពសិស្សឱ្យមានចំណេះដឹង និងបំណិនមូលដ្ឋានគ្រឹះរឹងមាំក្នុងការសរសេរតែងសេចក្តី នៅកម្រិតបឋមសិក្សាចំណេះទូទៅ។ ការពង្រឹងវិធីសាស្ត្របង្រៀននេះ គឺជាការឆ្លើយតបទៅនឹងតម្រូវការ ចាំបាច់របស់សិស្សក្នុងពេលបច្ចុប្បន្ន។ ដូច្នេះ ទាមទារគ្រូបង្រៀនត្រូវយល់ច្បាស់ពីអ្វីដែលហៅថា " វិធីសាស្ត្រ សរសេរតែងសេចក្តី " តើមានប្រភេទតែងសេចក្តីអ្វីខ្លះដែលតម្រូវឱ្យគ្រូបង្រៀនសិស្សនៅថ្នាក់ទី៣ ទី៤ ទី៥ និងទី៦ ឱ្យមានចំណេះដឹងមូលដ្ឋានគ្រប់គ្រាន់ក្នុងការសរសេរ និងបន្តការសិក្សាទៅមធ្យមសិក្សា។ ហេតុអ្វីបានជាត្រូវមានវិធីសាស្ត្របង្រៀនតែងសេចក្តី។ តើមានការណែនាំអនុវត្តដូចម្តេចខ្លះ តើវិធីសាស្ត្រសរសេរតែងសេចក្តីនេះមានប្រយោជន៍ឬសារៈសំខាន់អ្វីខ្លះសម្រាប់គ្រូ តើសិស្សនឹងទទួលបានចំណេះដឹងពីគ្រូតាម រយៈវិធីសាស្ត្រនិងមធ្យោបាយណាខ្លះ ដើម្បីសម្រេចបានជោគជ័យ និងលទ្ធផលល្អក្នុងការសិក្សា។

ដើម្បីឆ្លើយតបក្របខណ្ឌកម្មវិធីសិក្សាកម្មវិធីសិក្សាលម្អិតក៏ដូចជាខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាភាសាខ្មែរថ្នាក់ទី៣ ទី៤ ទី៥ និងទី៦ ក្រសួងអប់រំ យុវជន និងកីឡា ពិសេសក្រុមការងារនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានខិតខំយកចិត្តទុកដាក់រៀបចំចងក្រងឯកសារ "វិធីសាស្ត្រសរសេរតែងសេចក្តី" សម្រាប់បឋមសិក្សានេះ ដើម្បីឱ្យលោកគ្រូ អ្នកគ្រូ មានមូលដ្ឋានដកស្រង់យកទៅបង្រៀន សិស្សានុសិស្សនៅតាមសាលាបឋមសិក្សា ចំណេះទូទៅឱ្យមានបំណិនផ្នែកសំណេរតែងសេចក្តីកាន់តែរឹងមាំស្របតាមឬសម្រេចបានទៅនឹងលទ្ធផលសិក្សាស្តង់ដាកម្មវិធីសិក្សាដែលបានកំណត់។

គណៈកម្មការរៀបចំឯកសារសង្ឃឹមថា ឯកសារនេះនឹងបានជាជំនួយស្មារតីឬជាទុនដ៏ល្អប្រសើរសម្រាប់លោកគ្រូ អ្នកគ្រូយកទៅបង្រៀនសិស្សានុសិស្សដូចមានក្នុងការកំណត់កម្រិតថ្នាក់ស្របតាមប្រធានបទនីមួយៗ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

# វិធីសាស្ត្រសរសេរតែងសេចក្តី

## ១- តើអ្វីទៅដែលហៅថា វិធីសាស្ត្រសរសេរតែងសេចក្តី?

វិធីសាស្ត្រសរសេរតែងសេចក្តី គឺជាក្បួនខ្នាតសម្រាប់តាក់តែងន័យសេចក្តី អត្ថបទដែលគេបានចោទឡើងជាប្រធានដើម្បីឱ្យស្មេរពណ៌នា រៀបរាប់ពីអ្វីដែលគេចង់បានទៅតាមរបៀប ឬក្បួនវិធីបានត្រឹមត្រូវតាមរយៈការបញ្ចេញគំនិត យោបល់ ទស្សនៈរបស់ខ្លួនដោយមានការរៀបចំពាក្យសម្តី ឃ្លា ល្បះ ឬភាពពីរោះទាក់ទាញ មានលំដាប់លំដោយរបៀបរៀបរយ ងាយអាន ងាយស្តាប់ ងាយយល់ ហើយស្របនឹងប្រធានបទដែលបានកំណត់ទៀតផង។

ដើម្បីសរសេរតែងសេចក្តីបានល្អ អ្នកតែងត្រូវអនុវត្តតាមគោលវិធីមួយចំនួនដូចខាងក្រោម ៖

១- អានប្រធានដែលលើកឡើងដោយយកចិត្តទុកដាក់ឱ្យបានច្រើនលើកច្រើនសា។

២- ពិនិត្យរកពាក្យគន្លឹះ ឃ្លា ល្បះ ឬប្រយោគសំខាន់ៗ និងន័យរបស់ប្រធានឱ្យបានច្បាស់លាស់។

៣- ស្វែងយល់ន័យសេចក្តីប្រធានឱ្យបានច្បាស់ថា តើសេចក្តីប្រធានមានខ្លឹមសារនិងចំណងជើងដូចម្តេច? តើប្រធាននិយាយអំពីអ្វី ឬមានន័យដូចម្តេច? តើប្រធានតម្រូវឱ្យយើងសរសេរដូចម្តេច? តើសរសេរដើម្បីជាប្រយោជន៍អ្វីខ្លះ?

៤- សិក្សាពីប្រភេទ ឬស្គាល់លក្ខណៈរបស់ប្រធានឱ្យបានច្បាស់ថា តើប្រធានដែលលើកឡើងនេះជាប្រធានបែបពណ៌នាអំពីអ្វី? (មនុស្ស សត្វ វត្ថុ រុក្ខជាតិ ទេសភាព ទីកន្លែង ព្រឹត្តិការណ៍ និទានរឿង ការសរសេរសំបុត្រនិងសំណេរបំពេញពាក្យផ្សេងៗ)

៥- ខិតខំរកអំណះអំណាង ឧទាហរណ៍បង្ហាញហេតុផល ឬភស្តុតាងដើម្បីបញ្ជាក់ពីការសរសេរបកស្រាយ ឱ្យកាន់តែមានភាពច្បាស់លាស់គឺ រៀបរាប់ពីអ្វីដែលពិតជាក់ស្តែង ដូចបានឃើញពិតប្រាកដ ឱ្យបានត្រឹមត្រូវច្បាស់លាស់និងគ្រប់គ្រាន់។

៦- សរសេរតាមគំនិតរបស់ប្រធានដែលបានចោទ ដោយប្រុងប្រយ័ត្ន មិនឱ្យខុស ឬចាកប្រធាន។

៧- ត្រូវរៀបចំគម្រោងជាសេចក្តីព្រាង ដើម្បីប្រមូលគំនិត យោបល់ សរសេរឱ្យបានត្រឹមត្រូវតាមលំដាប់ លំដោយនៃប្រភេទតែងនីមួយៗ មិនថាចំពោះតែប្រធានពណ៌នាអំពីមនុស្ស សត្វ វត្ថុ រុក្ខជាតិ ឬទីកន្លែង នោះទេ សំខាន់គឺត្រូវសរសេរទៅតាមលំនាំគម្រោងតែងទាំងបីផ្នែកគឺ សេចក្តីផ្តើម តួសេចក្តី និងសេចក្តី បញ្ចប់។

៨- សរសេរសេចក្តីអធិប្បាយទៅតាមគម្រោងដែលបានរៀបចំរួចឱ្យបានល្អ ច្បាស់លាស់ ត្រឹមត្រូវតាមប្រធានដែលបានលើកឡើង។

## ២- ប្រការគួរចៀសវាងក្នុងការសរសេរតែងសេចក្តី

១- មិនត្រូវសរសេរជាគម្រោង ឬដាក់ចំណងជើងបែបមេរៀន (ក្នុងសេចក្តីអធិប្បាយ)

២- មិនប្រើពាក្យ ឃ្លា ល្បះ ឬប្រយោគច្រំដែល

៣- មិនត្រូវសរសេរអក្សរធំ អក្សរកាត់ ជាលេខរ៉ូម៉ាំង ឡាតាំង ឬលេខខ្មែរ

៤- សរសេរមិនឱ្យខុស ឬមានកំហុសអក្ខរាវិរុទ្ធ និងកំហុសវេយ្យាករណ៍

៥-មិនប្រើសញ្ញាគំនូស សញ្ញាផ្កាយ ឬសញ្ញាផ្សេងៗ គូសប្រអប់ គូសបន្ទាត់ពីក្រោម ឬជាចំណុចផ្សេងៗ ជាសម្គាល់ឡើយ

៦- មិនត្រូវប្រើប្រាស់ពាក្យដែលមិនច្បាស់ មិនមានន័យត្រឹមត្រូវ

៧- មិនត្រូវប្រើពាក្យលែបខាយ ផ្តេះផ្តង លន្លង់លន្លោច ស្រងេះស្រងោច ខ្លោចផ្សាបែបប្រលោមលោកឡើយ។

## ៣- ការណែនាំអំពីគម្រោងតែងសេចក្តីបែបពណ៌នា

កាលណាគេនិយាយពីតែងសេចក្តីប្រៀបបាននឹងការនិយាយពីមនុស្សម្នាក់ ដែលត្រូវមានលក្ខណៈពិសេសសំខាន់ចាំបាច់គឺ ក្បាល ដងខ្លួន និងអវយវៈ។ ដូចគ្នានឹងគម្រោងតែងសេចក្តីនេះដែរគឺត្រូវមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។ តើនៅក្នុងផ្នែកសំខាន់ៗទាំងបីខាងលើតម្រូវឱ្យអ្នកសរសេរ ឬអ្នកធ្វើតែងសេចក្តីធ្វើដូចម្តេចខ្លះ?

ដូច្នេះ ការធ្វើតែងសេចក្តីបែបពណ៌នាតម្រូវឱ្យយើងលើកយកមកបង្ហាញឡើងវិញនូវអ្វីៗដែលបានឃើញបានឮ បានស្រង់ក្លិន បានភ្លក់ ពោលគឺអ្វីៗដែលមានទំនាក់ទំនងទៅនឹងធម្មជាតិខាងក្រៅនិងឥន្ទ្រិយរបស់ យើង។ ប្រធានបែបនេះតម្រូវឱ្យយើងសង្កេត ពិនិត្យ និងចងចាំជាងការត្រិះរិះពិចារណា ឬវិភាគ។ ការសង្កេត ពិនិត្យ កត់ចំណាំនោះទៀតសោត ត្រូវមានបំណិនប្រសប់ជ្រើសរើសតែលក្ខណៈពិសេសៗនៃមនុស្ស សត្វ វត្ថុ រុក្ខជាតិ ទីកន្លែង ឬព្រឹត្តិការណ៍ មកធ្វើការពណ៌នាឡើងវិញដើម្បីឱ្យគេបានដឹង បានឮ បានឃើញផ្ទាល់ នឹងភ្នែកពិតៗ។ ការពណ៌នាបានល្អជាក់ស្តែងនិងរស់រវើកគឺការប្រើឥន្ទ្រីយារម្មណ៍គួបផ្សំ ដូចជាការប្រើភ្នែក ត្រចៀក ដៃ ច្រមុះ អណ្តាត និងបំណិនប្រសប់ជ្រើសរើសទិដ្ឋភាព ឬលក្ខណៈពិសេសៗមកពណ៌នាតាមកាល អាកាស តាមលំដាប់លំដោយគំនិតប្រកបដោយភាពទាក់ទាញ ឬសិល្បវិធី។

## ៤- គម្រោងតែងសេចក្តីបែបពណ៌នា

តែងសេចក្តីបែបពណ៌នាដូចតែងសេចក្តីប្រភេទដទៃទៀតដែរគឺតម្រូវឱ្យមាន សេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ ដូចបានពោលខាងលើរួចមកហើយ។ ដូច្នេះ អ្នកសរសេរត្រូវៈ

### ក- សេចក្តីផ្តើម

ផ្តើមដោយការសរសេររៀបរាប់ទាក់ទងទៅនឹងប្រធានដែលបានលើកឡើង។

### ខ- តួសេចក្តី

រៀបចំគំនិតសរសេរដោយរៀបរាប់ពណ៌នាលម្អិតយ៉ាងក្បោះក្បាយតាមលំដាប់លំដោយ គំនិតដែលមានឃ្លា ល្បះ ត្រឹមត្រូវ ស្របតាមប្រធាន។

### គ- សេចក្តីបញ្ចប់

បង្ហាញពីការវាយតម្លៃប្រធាននិងចំណាប់អារម្មណ៍ ឬការសម្តែងពីមនោសញ្ចេតនាផ្ទាល់ខ្លួន។

## ៥- ប្រភេទតែងសេចក្តី

តែងសេចក្តីបែបពណ៌នាមានច្រើនប្រភេទដូចជា ការពណ៌នាពីមនុស្ស សត្វ វត្ថុ រុក្ខជាតិ ទីកន្លែង ទេសភាព ព្រឹត្តិការណ៍ ការនិទានរឿង សំណេរសំបុត្រ និងបំពេញពាក្យសុំផ្សេងៗ។

ប្រភេទតែងសេចក្តីសម្រាប់កម្រិតបឋមសិក្សាមានដូចខាងក្រោមៈ

១- ប្រធានពណ៌នាអំពីមនុស្ស

២- ប្រធានពណ៌នាអំពីសត្វ

៣- ប្រធានពណ៌នាអំពីវត្ថុ

៤- ប្រធានពណ៌នាអំពីរុក្ខជាតិនិងផ្លែឈើ
៥- ប្រធានពណ៌នាអំពីទីកន្លែង
៦- ប្រធានពណ៌នាអំពីទេសភាព
៧- ប្រធានពណ៌នាអំពីព្រឹត្តិការណ៍
៨- ប្រធាននិទានរឿង
៩- ប្រធានសរសេរសំបុត្រ
១០- សំណេរបំពេញពាក្យសុំផ្សេងៗ។

## ៦- គោលបំណង

តើតែងសេចក្តីបែបពណ៌នាមានគោលបំណងនិងសារៈសំខាន់អ្វីខ្លះ?

តែងសេចក្តីបែបពណ៌នាមានគោលបំណងបណ្តុះទម្លាប់សិស្សឱ្យចេះ សង្កេត ពិនិត្យ លើលក្ខណៈ មនុស្ស សត្វ វត្ថុ រុក្ខជាតិ សកម្មភាព ឬព្រឹត្តិការណ៍ផ្សេងៗដោយយកចិត្តទុកដាក់។ បន្ទាប់មក សិស្សមានសមត្ថភាពសរសេររៀបរាប់ បង្ហាញអ្វីដែលបានឃើញ បានឮនៅជុំវិញខ្លួន នៅក្នុងផ្ទះ សាលារៀន ភូមិ ឬសហគមន៍។ ជាងនេះទៅទៀតចេះវាយតម្លៃ សម្តែងពីអារម្មណ៍ឬសញ្ចេតនា គោរព ស្រឡាញ់ ពេញចិត្ត បានត្រឹមត្រូវគ្រប់ជ្រុងជ្រោយដោយមានឧទាហរណ៍ ឬអំណះអំណាងបញ្ជាក់ច្បាស់លាស់ ព្រមទាំងចេះប្រើ ចំណេះដឹងទាំងនេះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃបានយ៉ាងល្អប្រសើរទៀតផង។

ការសរសេរតែងសេចក្តីបែបពណ៌នាមានសារៈសំខាន់បំផុតសម្រាប់សិស្សនៅបឋមសិក្សា ព្រោះវាជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ក្នុងការផ្តល់ចំណេះដឹងនិងបំណិនប្រសប់ ផ្នែកសំណេរតែងសេចក្តី ពីកម្រិតបឋមសិក្សាទៅកម្រិតមធ្យមសិក្សា។

## ៧- តែងសេចក្តីបែបពណ៌នា

មុននឹងឈានដល់ការសិក្សាពីប្រភេទតែងសេចក្តីបែបពណ៌នា យើងគប្បីយល់ន័យនៃពាក្យថា "តែងសេចក្តី" ជាមុនសិន។ តើតែងសេចក្តីជាអ្វី?

**តែងសេចក្តីពណ៌នា** មានន័យថា ជាការសរសេររៀបរាប់បកស្រាយ សម្តែង បញ្ចេញមតិ យោបល់ ទស្សនៈរបស់ស្មេរ ដើម្បីចងក្រងជាអត្ថបទមួយដែលពោរពេញដោយការយល់ដឹងច្បាស់លាស់ ពិតជាក់ស្តែងឆ្លើយតបទៅនឹងប្រធានដែលលើកឡើងដែលតម្រូវឱ្យសរសេរបកស្រាយ ពន្យល់ រៀបរាប់ វិភាគ ថ្លឹងថ្លែងទៅលើសកម្មភាព ព្រឹត្តិការណ៍ រឿងរ៉ាវ ទស្សនៈ ទ្រឹស្តីរបស់បុគ្គលណាមួយ ឬពណ៌នាអំពីមនុស្ស សត្វ វត្ថុ រុក្ខជាតិ ធម្មជាតិ ទេសភាពដែលគេចង់ដឹង តាមរយៈការរៀបចំពាក្យសម្តី ឃ្លា ល្បះមានការបកស្រាយ ពន្យល់ រៀបរាប់បានក្បោះក្បាយ មានសណ្តាប់ធ្នាប់រៀបរយល្អ ងាយអាន ងាយស្តាប់ ងាយយល់ ធ្វើឱ្យគេជក់ចិត្តចាប់អារម្មណ៍និងស្របទៅតាមប្រធានថែមទៀតផង។

តែងសេចក្តីបែបពណ៌នា គឺជាប្រភេទតែងសេចក្តីដែលតម្រូវឱ្យអ្នកសរសេររៀបរាប់បង្ហាញពីអ្វីដែលខ្លួនបានសង្កេត ពិនិត្យ ហើយសរសេររៀបរាប់បង្ហាញតាមសភាពពិតជាក់ស្តែង តាមការយល់ដឹងរបស់ខ្លួនទាក់ទងវិញ្ញាណទាំងប្រាំ ដូចជាចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ស្របតាមគំនិតប្រធានដែលបានចោទប្រកបដោយភាពទាក់ទាញ។

ប្រធានប្រភេទនេះតម្រូវឱ្យអ្នកសរសេរចេះបង្ហាញពីរូបរាង ភិនភាគ របស់ មនុស្ស សត្វ រុក្ខជាតិ វត្ថុ ទីកន្លែង សកម្មភាព បាតុភូតធម្មជាតិ ណាមួយដែលបានកើតឡើងជាក់ស្ដែងទៅតាមលំដាប់លំដោយនៃពេលវេលានិងទីកន្លែងដែលព្រឹត្តិការណ៍នោះបានកើតឡើង។

ក្នុងការបកស្រាយប្រធានបែបនេះតម្រូវឱ្យអ្នកសរសេរចេះសង្កេត ពិនិត្យ ទៅលើអ្វីដែលបានឃើញយកមកពណ៌នាឱ្យបានច្បាស់លាស់ ហើយត្រូវស្គាល់ ឬឆ្លងកាត់ព្រឹត្តិការណ៍នោះថែមទៀត ទើបងាយស្រួលនៅក្នុងការសរសេរទាក់ទាញអារម្មណ៍អ្នកអាន អ្នកសិក្សា ឱ្យមើលឃើញពីសកម្មភាពឬព្រឹត្តិការណ៍នោះ ហាក់ដូចជាបានឃើញផ្ទាល់នឹងភ្នែករបស់ពួកគេ។ លើសពីនេះទៀត អ្នកសរសេរត្រូវបង្ហាញពីចិត្តគំនិត ឬមនោសញ្ចេតនាទៅលើអ្វីដែលខ្លួនបាននិយាយរៀបរាប់នោះផង ទើបអានទៅមានភាពច្បាស់លាស់ឥតមានភាពស្រពិចស្រពិល។

ពាក្យ **ពណ៌នា** នៅក្នុងវចនានុក្រមខ្មែរសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ប្រែថា ពាក្យពោលរៀបរាប់ពាក្យអធិប្បាយសេចក្ដី អដ្ឋកថា។ បើយោងតាមការបកស្រាយបែបនេះមានន័យថា ដើម្បីពោលពាក្យរៀបរាប់ឱ្យបានល្អនោះអ្នកសរសេរត្រូវរៀបរាប់ឱ្យបានសមសួន ចេះច្បិចយកចំណុចណាដែលច្បាស់លាស់មក បកស្រាយនោះទើបបានទទួលការចាប់ចិត្តជិតអារម្មណ៍ពីអ្នកអាន។ អ្នករៀបរាប់នោះត្រូវមានភាពប៉ិនប្រសប់ហើយមានភាពឈ្លាសវៃ នៅក្នុងការបន្ថែមសេចក្ដី ដោយមិននិយាយបញ្ច្រាសព្រឹត្តិការណ៍រឿងឡើយ។

ខាងក្រោមនេះគឺជាការលើកយកមកបង្ហាញនូវប្រភេទតែងសេចក្ដីបែបពណ៌នានីមួយៗ ដែលមានលំនៃនាំគម្រោងតែងនិងសេចក្ដីអធិប្បាយមួយចំនួនជាឧទាហរណ៍ដោយឡែកៗពីគ្នាដូចតទៅ៖

## ៧.១- ប្រធានពណ៌នាអំពីមនុស្ស

ការពណ៌នាអំពីមនុស្ស តម្រូវឱ្យយើងប្រើលំនឹកទៅខាប ឬថតយករូបរាង សកម្មភាព ឥរិយាបថ បរិយាកាសរបស់មនុស្ស ដែលយើងធ្លាប់ស្គាល់ ឬបានឃើញនោះមកបង្ហាញគេឡើងវិញ ដើម្បីឱ្យគេស្គាល់ ឬហាក់ដូចជាបានឃើញផ្ទាល់នឹងភ្នែកតាមរយៈពាក្យសម្ដីនិងសំណេររបស់យើង។

ក្នុងការពណ៌នាទូទៅពីមនុស្សត្រូវពឹងផ្អែកលើលក្ខណៈពីរយ៉ាងជាចាំបាច់ ហើយលក្ខណៈទាំងពីរនេះត្រូវមានទំនាក់ទំនងគ្នា៖

- ពណ៌នារូបសម្បត្តិ ៖ អ្នកសរសេរត្រូវសរសេររៀបរាប់លក្ខណៈមនុស្សជាដំបូង គឺយើងត្រូវសង្កេតពិនិត្យទៅលើរូបរាងខាងក្រៅដែលជាលក្ខណៈទូទៅឱ្យបានច្បាស់លាស់តាំងពី ក្បាល មុខមាត់ ដៃ ជើង ឬអវយវៈ អាយុ កម្ពស់ មាឌ ពណ៌សម្បុរ។ ឥរិយាបថសំដៅលើការពណ៌នាពីការនិយាយស្ដី ដេក ដើរ ឈរ អង្គុយ ការស្លៀកពាក់ និងសកម្មភាពផ្សេងៗ ដូចជាសកម្មភាពក្នុងគ្រួសារ ឬសង្គម។ល។
- ពណ៌នាចរិយាសម្បត្តិ៖ តម្រូវឱ្យអ្នកសរសេររៀបរាប់បង្ហាញពីចរិតនិងអាកប្បកិរិយារបស់មនុស្ស ដូចជា កាច ស្លូត សុភាពរាបសា រម្យទម ទន់ភ្លន់ ថ្លៃថ្នូរ ឧស្សាហ៍ព្យាយាម ឬខ្ជិលច្រអូស។ បានន័យថាត្រូវ រៀបរាប់ទាំងចំណុចវិជ្ជមាននិងអវិជ្ជមាន ឬគុណសម្បត្តិនិងគុណវិបត្តិ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

បង្ហាញមនុស្សនោះដោយប្រាប់ពី : ឈ្មោះ ភេទ អាយុ មុខរបរ និងទីលំនៅ។ (បើការពណ៌នានោះ តម្រូវឱ្យនិយាយអំពីសិស្សសាលាត្រូវបង្ហាញពីទីកន្លែងសិក្សាផង)

**ខ- តួសេចក្តី**

***រូបសម្បត្តិ:*** រូបរាង មាឌ កម្ពស់ ពណ៌សម្បុរ ដោយពណ៌នាពីក្បាល ដងខ្លួនទៅអវយវៈ ឬពណ៌នាពីលើ ចុះក្រោម មុខមាត់ ភ្នែក ច្រមុះ សក់ ។

**ចរិយាសម្បត្តិ:** ស្លូត កាច ឧស្សាហ៍ ព្យាយាម សុភាពរាបសា រម្យទម ទន់ភ្លន់ ថ្លៃថ្នូរ ខ្ជិល...។ អាកប្បកិរិយាក្នុងការនិយាយស្តី ដំណើរ ការឈរ អង្គុយ ការស្លៀកពាក់ និងសកម្មភាពផ្សេងៗ ដូចជា សកម្មភាពក្នុងគ្រួសារ ឬក្នុងសង្គម។

- **គុណសម្បត្តិ:** ចំណុចល្អរបស់មនុស្សដែលមានចំពោះគ្រួសារនិងសង្គមជាតិ។

***ឧទាហរណ៍ :*** យកចិត្តទុកដាក់រៀនសូត្រ ជួយការងារផ្ទះ ជួយទុក្ខធុរៈមិត្តភក្តិ ឬអ្នកដទៃ ឆ្លាត វាងវៃ ឆាប់យល់ដឹងចងចាំ ធ្វើការងារដោយផ្ចិតផ្ចង់។

- **គុណវិបត្តិ:** ចំណុចខ្វះខាត

ឧទាហរណ៍: ឆាប់ខឹង ឆេវឆាវ មករៀនយឺតម្តងម្កាល ។ល។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: បង្ហាញពីតម្លៃរបស់មនុស្ស។

***ឧទាហរណ៍ :*** ជាមនុស្សមានអត្តចរិតល្អ មានគំនិតមារយាទ ឬឫកពាសមរម្យ ថ្លៃថ្នូរ ចេះជួយគ្នាក្នុងពេលមានទុក្ខធុរៈ ឬពេលមានអាសន្នផ្សេងៗ។

- ចំណាប់អារម្មណ៍: បង្ហាញពីមនោសញ្ចេតនាចំពោះមនុស្សនោះ ដូចជាអាណិត ស្រឡាញ់ ចូលចិត្ត គោរពរាប់អាន ឬក៏យកតម្រាប់តាម។

**៧.១.១- ឧទាហរណ៍ទី១** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

---

**ប្រធាន** : ចូរប្អូនពណ៌នាអំពីមិត្តភក្តិរបស់ប្អូនម្នាក់ដែលប្អូនបានស្គាល់។

---

## សេចក្តីពណ៌នា

ខ្ញុំមានមិត្តភក្តិស្រីម្នាក់ឈ្មោះ សុខ គន្ធា។ នាងមានអាយុប្រាំបួនឆ្នាំ។ គន្ធាជាសិស្សរៀននៅថ្នាក់ទី៤ (ក)នៃសាលាបឋមសិក្សាកោះច្រែង។ សព្វថ្ងៃ នាងរស់នៅ ភូមិព្រែក ឃុំកោះច្រែង ស្រុកចិត្របុរី ខេត្តក្រចេះ។

គន្ធាមានរាងតូចស្តើង កម្ពស់ប្រហែលមួយម៉ែត្រម្ភៃប្រាំ សម្បុរខ្មៅស្រអែម ទម្រង់មុខរាងមូលទ្រវែង ភ្នែកមូលធំ ចិញ្ចើមខ្មៅក្រាស់ ច្រមុះតូចស្រួច បបូរមាត់ស្តើង ហើយត្រចៀកសមនឹងទម្រង់មុខ សក់របស់នាងស្លូតវែងប៉ប្រះស្មាគួរឱ្យស្រឡាញ់។ គន្ធាមានដៃជើងតូចស្រឡូនសមនឹងដងខ្លួន។ នាងមានសម្តីពីរោះ ឥរិយាបថសុភាពរាបសាទន់ភ្លន់ និយាយស្តីមួយៗ ច្បាស់ៗមានដំណើរមួយៗ ប៉ុន្តែស្វាហាប់ ការឈរ អង្គុយ មានឥរិយាបថ សមរម្យ ថ្លៃថ្នូរ។ នាងជាកុមារីម្នាក់ដែលមានទឹកមុខស្រស់ បស់ រូសរាយរាក់ទាក់។ គន្ធាជាក្មេងចេះគួរសម ដូចជានៅពេលជួបគ្រូម្តងៗនាងតែងតែមានទម្លាប់ល្អក្នុងការសួរ ឆ្លើយដោយគោរព និងញញឹមជានិច្ច។ ចំពោះការសិក្សាវិញ គន្ធាជាសិស្សដែល

ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់រៀនសូត្រ។ នាងបានរៀននិងហ្វឹកហាត់តាមដំបូន្មានរបស់ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ គ្រប់កិច្ចការដែលគ្រូដាក់ឱ្យធ្វើនិងមេរៀនដែលត្រូវរៀននៅថ្ងៃបន្ទាប់ជានិច្ច។ នាងព្យាយាមសិក្សារៀនសូត្រ ជាមួយគ្រូ ជាមួយមិត្តភក្តិ និងស្វ័យសិក្សាដោយខ្លួនឯងផងដែរ។ នាងក៏បានជួយពន្យល់ ផ្តល់គំនិត យោបល់ ទៅមិត្តរួមថ្នាក់ណាដែលមិនទាន់យល់មេរៀន ឬកិច្ចការលំហាត់ណាមួយ។ ពេលជួបមាមីង បងប្អូន ញាតិមិត្តជិតខាងគន្ធាតែងនិយាយពាក្យគួរសមនិងមានកាយវិការឱនលំទោន។ នៅពេលទំនេរពីការសិក្សា នាងបានជួយធ្វើការងារឪពុកម្តាយ ដូចជាមើលថៃប្អូន បោសសម្អាតផ្ទះសម្បែង ជួយលាងចានឆ្នាំង និងថែទាំសួនដំណាំ។ នាងមិនចូលចិត្តនិយាយលេងសើចក្រៅពីការងាររៀនសូត្រនោះទេ។ គន្ធាមិត្តខ្ញុំជាកុមារីយកចិត្តទុកដាក់ក្នុងការសិក្សាហើយស្លូតត្រង់ មានប្រាជ្ញាឈ្លាសវៃ ចិត្តទូលាយ ចេះជួយទុក្ខធុរៈមិត្តភក្តិ មានទំនាក់ទំនងល្អជាមួយបងប្អូន និងអ្នកជិតខាង។

សរុបសេចក្តីមក គន្ធាមិត្តរបស់ខ្ញុំគឺជាកុមារីម្នាក់ដែលមានសន្តានចិត្តល្អនិងជាសិស្សពូកែ។ នាងជាកុមារគំរូគួរឱ្យស្រឡាញ់រាប់អាននិងយកតម្រាប់តាម។

**៧.១.២- ឧទាហរណ៍ទី២** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនពណ៌នាអំពីលោកគ្រូរបស់ប្អូន។

## សេចក្តីពណ៌នា

លោកគ្រូខ្ញុំឈ្មោះសំ សុធា។ លោកមានអាយុសាមសិបប្រាំឆ្នាំ។ លោកបង្រៀននៅថ្នាក់ទីប្រាំមួយនៃសាលាបឋមសិក្សាព្រៃខ្មែរ ភូមិព្រៃខ្មែរ ឃុំលាល្អៀរ ស្រុកលាល្អៀរ ខេត្តកំពង់ឆ្នាំង។

លោកគ្រូខ្ញុំមានមាឌធំ ខ្ពស់ សម្បុរខ្មៅស្រអែម សក់រួញអង្កាដី។ មុខមាត់របស់លោកដូចមនុស្សខ្មែរ សម័យអង្គរ គឺមុខរាហ៍ ភ្នែកធំ ចិញ្ចើមខ្មៅក្រាស់ ច្រមុះខ្ពស់ស្រួច បបូរមាត់ធំក្រាស់ ទងត្រចៀកសំប៉ែត វែង។ គាត់មានទឹកមុខញញឹមស្រស់ស្រាយ រួសរាយរាក់ទាក់។ ដៃជើងរបស់លោកមានសាច់ដុំធំៗជាមនុស្ស មានកម្លាំងមាំមួន និងសុខភាពល្អ។ នៅពេលបង្រៀនមេរៀន ឬនិយាយជាមួយសិស្សលោកគ្រូនិយាយ មួយៗ ច្បាស់ៗ និងមានសំឡេងពីរោះគួរឱ្យចង់ស្តាប់។ លោកមានដំណើររហ័សរហួន។ សូម្បីតែការឈរឬអង្គុយនៅក្នុងថ្នាក់រៀននៅពេលបង្រៀនក៏មានឥរិយាបថសមសួន មិនទាស់ភ្នែកផងដែរ។ លោកនិយម ស្លៀកខោពណ៌ខៀវក្រមៅ អាវពណ៌ស ឬពណ៌ផ្ទៃមេឃ អ៊ុតរាបត្រង់យ៉ាងមានសណ្តាប់ធ្នាប់ និងថ្លៃថ្នូរ ជានិច្ច។

លើសពីនេះ លោកគ្រូមានចរិតស្លូតបូតតែម៉ឺងម៉ាត់ក្នុងការងារ។ លោកជាគ្រូឧស្សាហ៍ ហើយព្យាយាម និងខិតខំបង្រៀនសិស្សរាល់ថ្ងៃ មិនដែលអវត្តមានឡើយ។ ពិសេសលោកមានអធ្យាស្រ័យល្អចំពោះសិស្សទាំងអស់ដោយមិនរើសអើងវណ្ណៈ ជាតិសាសន៍ និងបែងចែកសិស្សពូកែ សិស្សមិនពូកែនោះឡើយ។ ពេលសិស្សមានកំហុសលោកពុំដែលសម្លុត បន្ទះបង្អាប់ឬប្រើអំពើហិង្សានោះទេ។ លោកតែងនិយាយណែនាំ ផ្តល់វិធីងាយៗដើម្បីឱ្យសិស្សខិតខំរៀនបានពូកែ ។ ជានិច្ចកាល លោកបានលើកទឹកចិត្តសិស្ស ជួយសិស្សក្នុង ការសិក្សា។ សិស្សទាំងអស់ គោរពស្រឡាញ់លោក ដូចជាឪពុកបង្កើតរបស់ខ្លួន។ លោកគ្រូខ្ញុំ ជាមនុស្សសកម្មការងារ។ លោកយកចិត្តទុកដាក់ ក្នុងការបង្រៀននិងកែកិច្ចការរបស់សិស្ស ជាប់ជាប្រចាំ។ រាល់ពេលទំនេរ លោកគ្រូឆ្លៀតដាំដំណាំ ចិញ្ចឹមសត្វ ដើម្បីបង្កើនជីវភាពគ្រួសារប្រចាំថ្ងៃ។ លោកក៏តែងតែចូលរួមយ៉ាងសកម្មក្នុងការងារអភិវឌ្ឍ

សហគមន៍។ លោកគ្រូខ្ញុំចូលចិត្តកីឡាវាយសីនិងបាល់បោះ ប៉ុន្តែលោកគ្រូមិនដែលដើរកម្សាន្តនោះទេ។ លោកគិតតែការងារបង្រៀនសិស្ស និងធ្វើការផ្សេងៗបន្ថែមទៀតដើម្បីបង្កើនជីវភាពគ្រួសារគាត់។

លោកពូខ្ញុំជាមនុស្សឧស្សាហ៍ព្យាយាមក្នុងការងារបង្រៀន ក៏ដូចជាការងារផ្ទះ។ ខ្ញុំគោរពនិងស្រឡាញ់ លោកគ្រូខ្ញុំណាស់ ព្រោះលោកជាអ្នកមានគុណទីពីររបស់ខ្ញុំ និងជាអ្នកបង្រៀនខ្ញុំ ឱ្យក្លាយជា សិស្សល្អ មិត្តល្អ និងកូនល្អ ។

**៧.១.៣- ឧទាហរណ៍ទី៣** (ថ្នាក់ទី៥ និងទី៦)

---

**ប្រធាន** : ចូរប្អូនពណ៌នាអំពីជីដូនរបស់ប្អូន។

---

## សេចក្តីពណ៌នា

ខ្ញុំមានជីដូនម្នាក់ឈ្មោះសុខ ថានី គាត់មានអាយុហុកសិបពីរឆ្នាំ។ បច្ចុប្បន្នគាត់រស់នៅភូមិបន្ទាយលើ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ជាមួយនឹងគ្រួសារខ្ញុំ។

ជីដូនខ្ញុំមានមាឌតូចល្មម រាងស្តើង មានកម្ពស់មួយម៉ែត្រហុកសិប សម្បុរសណ្តែកបាយ សក់ស្កូវមួយៗ ច្រមុះស្រួច ត្របកភ្នែកយារធ្លាក់បន្តិច ដៃជើងសមនឹងដងខ្លួន។ ជីដូនខ្ញុំជាអ្នកមិនសូវនិយាយស្តី ច្រើនទេ គាត់ច្រើននិយាយយឺតៗ មួយៗ តែពីរោះហើយមានសំឡេងឮខ្លាំង ច្បាស់ងាយស្តាប់។ គាត់តែងណែនាំផ្តល់ដំបូន្មានកូនចៅណាដែលមានកំហុសឆ្គង ឬធ្វើការមិនពេញចិត្តគាត់។ ខ្ញុំតែងសង្កេតឃើញពេលជីដូនខ្ញុំដើរម្តងៗ គាត់តែងតែដើរដោយយឺតៗ និងប្រុងប្រយ័ត្នបំផុតព្រោះខ្លាចជំពប់ជើងដួល។ នៅពេលអង្គុយឬក្រោកឈរក៏គាត់មានការប្រុងប្រយ័ត្ននិងរៀបឥរិយាបថបានសមរម្យ មិនឮលាន់ឬទាស់ឆ្គងអ្វីឡើយ។ លោកយាយខ្ញុំជាមនុស្សនិយមរាប់អានញាតិមិត្ត និងតែងចែករំលែក ម្ហូបអាហារ នំចំណី បន្លែ ផ្លែឈើ ដល់អ្នកជិតខាង។ លោកយាយមិនសូវចេះនៅស្ងៀមនោះទេ។ រាល់ថ្ងៃគាត់តែងតែជួយធ្វើកិច្ចការ នៅផ្ទះដូចជាបោសសំរាមជុំវិញផ្ទះ ជួយថែដំណាំ បន្លែក្បែរផ្ទះ ទៅតាមកម្លាំង និងសុខភាពរបស់លោក។ លោកយាយចូលចិត្តជួយទុក្ខធុរៈអ្នកដទៃជានិច្ច ដូចជាផ្តល់ថវិកាជួយដល់អ្នកជំងឺដែលទីទ័លលំបាកជាដើម។ លោកជាអ្នកមានគុណរបស់គ្រួសារខ្ញុំ ព្រោះលោកបានចិញ្ចឹមបីបាច់រក្សាកូនចៅ និងអប់រំកូនចៅឱ្យខិតខំរៀនសូត្រ ប្រកបរបរចិញ្ចឹមជីវិត ដោយប្រកាន់ភាពសុចរិតត្រឹមត្រូវនិងចៀសវាង អំពើអបាយមុខផ្សេងៗដែលជាទង្វើខុសច្បាប់។ នៅពេលទំនេរ ជីដូនខ្ញុំតែងតែនិទានរឿងព្រេងផ្សេងៗឱ្យចៅៗស្តាប់។ សព្វថ្ងៃនេះលោកយាយរបស់ខ្ញុំប្រែប្រួលបន្តិច ព្រោះគាត់ចាស់ឆាប់ខឹង ប្រកាន់ច្រើន ប៉ុន្តែ គ្រួសារខ្ញុំគ្រប់គ្នាបានយល់ចិត្តលោកយ៉ាងច្បាស់ហើយព្យាយាមនៅក្បែរគាត់ និងនិយាយលួងលោមគាត់ដើម្បីនាំភាពសប្បាយរីករាយជូនគាត់។

សរុបសេចក្តីមកទោះបីជាជីដូនខ្ញុំមានវ័យចំណាស់ក៏ពិតមែន តែលោកនៅមានការចងចាំ ហើយតែងតែ និទានរឿងឱ្យខ្ញុំស្តាប់ជាញឹកញាប់។ ខ្ញុំគោរព ស្រឡាញ់ជីដូនខ្ញុំណាស់ ព្រោះគាត់ជាអ្នកមានគុណ និងតែងតែ ផ្តល់ដំបូន្មានល្អៗដល់ខ្ញុំ គ្រប់ពេលវេលា។

**៧.១.៤- ឧទាហរណ៍ទី៤** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនពណ៌នាអំពីមន្ត្រីនគរបាលចរាចរណ៍ម្នាក់ដែលប្អូនបានស្គាល់។

## សេចក្តីពណ៌នា

លោកពូខ្ញុំឈ្មោះ ស៊ុន មៅ។ គាត់មានអាយុសាមសិបប្រាំបួនឆ្នាំ ជាមន្ត្រីនគរបាលចរាចរណ៍ រាជធានី ភ្នំពេញ។ សព្វថ្ងៃគាត់រស់នៅជាមួយគ្រួសារខ្ញុំនៃសង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។

ពូខ្ញុំមានមាឌធំ កម្ពស់មួយម៉ែត្រចិតសិបប្រាំ សម្បុរខ្មៅស្រអែម ទម្រង់មុខរាងមូល សក់គ្រង់បប្ញូរ មាត់ តូចស្តើងល្មម ច្រមុះខ្ពស់ស្រួច។ ចំណែកចិញ្ចើមខ្មៅក្រាស់ ទងត្រចៀករាងសំប៉ែតវែង។ ដៃជើងរបស់ គាត់វែងៗហើយមានសាច់ដុំធំៗជាអ្នកមានកម្លាំងមាំមួននិងសុខភាពល្អ។ ពូខ្ញុំជាមនុស្សមានរបៀបទាំងការនិយាយស្តី ការដើរហើរ ឬការឈរ និងអង្គុយក៏មានបែបបទសមរម្យ។ រីឯការស្លៀកពាក់វិញក៏មានរបៀបរៀបរយល្អ សមរម្យ ថ្លៃថ្នូរ តាមទម្លាប់ប្រចាំថ្ងៃរបស់គាត់។ សម្លៀកបំពាក់ឬឯកសណ្ឋាន សម្រាប់ស្លៀកធ្វើការ ឬនៅផ្ទះ គាត់បោកគក់ អ៊ុតដោយខ្លួនឯងបានរាបស្មើ មានភ្លី ត្រង់ភ្លឹងជានិច្ច។ ទោះជាខោអាវនោះចាស់ ឬយូរហើយក៏ដោយក៏មើលទៅឃើញស្អាតដដែល។ រាល់ថ្ងៃពូខ្ញុំចេញទៅធ្វើការនៅម៉ោងប្រាំមួយ ព្រឹក និងត្រឡប់មកវិញនៅម៉ោងប្រាំពីរយប់ជារៀងរាល់ថ្ងៃ។ ពូមិនដែលខកខានទៅធ្វើការទោះជាមាន ឧបសគ្គ ដោយសារភ្លៀង ខ្យល់ យ៉ាងណាក៏ដោយ ព្រោះគាត់ត្រូវទៅប្រចាំការ តាមគោលដៅបានទាន់ពេល វេលាដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍តាមផ្លូវធ្វើដំណើរ។ ពូខ្ញុំជាមនុស្សស្លូត សុភាព ចេះយកអាសា មិត្តភក្តិតែម៉ឺងម៉ាត់ក្នុងការងារ។ លោកពូមិនដែលឈ្លោះទាស់ទែងជាមួយអ្នកណាម្នាក់នោះទេ។ គាត់តែងតែ ជួយមិត្តដែលមានបញ្ហានិងអ្នកជួបទុក្ខលំបាកដូចជាជួយជាប្រាក់ ជួយជាសម្លៀកបំពាក់ជាសម្ភារៈប្រើប្រាស់ ជាកម្លាំងកាយចិត្តជាដើម។ គាត់មានទំនាក់ទំនងល្អជាមួយអ្នកជិតខាងដោយមិនប្រកាន់។ រាល់ពេលទំនេរពីការងារគាត់និយមនាំក្មេងៗលេងកីឡា ហាត់ប្រាណ និងនិទានរឿង ឬដាក់ប្រស្នា ធ្វើឱ្យមាន បរិយាកាសកាន់តែសប្បាយរីករាយ។ ក្មេងៗចូលចិត្ត និងស្រឡាញ់គាត់ណាស់។ ទន្ទឹមនឹងគុណសម្បត្តិ ខាងលើលោកពូរបស់ខ្ញុំក៏មានគុណវិបត្តិដែរគឺគាត់ចេះជក់បារី។

សរុបសេចក្តីមក គាត់ជាមនុស្សស្រឡាញ់ការងាររបស់គាត់ណាស់។ គាត់ជាមនុស្សឧស្សាហ៍ព្យាយាមគួរឱ្យយកតម្រាប់តាម។ ខ្ញុំគោរពស្រឡាញ់គាត់ដូចឪពុករបស់ខ្ញុំដែរ។

**៧.១.៥- ឧទាហរណ៍ទី៥** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនពណ៌នាអំពីជនពិការម្នាក់ដែលប្អូនបានស្គាល់។

## សេចក្តីពណ៌នា

ខ្ញុំបានស្គាល់បងស្រីម្នាក់ ឈ្មោះ សាន ចរិយា។ គាត់មានអាយុម្ភៃបួនឆ្នាំ ជាជនពិការ ហើយធ្វើការ នៅអង្គការជនពិការរាជធានីភ្នំពេញ។ សព្វថ្ងៃបងស្រីចរិយា រស់នៅភូមិមួយក្នុងសង្កាត់មនោរម្យ ខណ្ឌប្រាំពីរ មករា រាជធានីភ្នំពេញ។

បងស្រីចរិយាមានរាងតូចស្តើង កម្ពស់ប្រហែលមួយម៉ែត្រហុកសិប ឯសម្បុរវិញខ្មៅស្រអែម មាន ទម្រង់ មុខមូល ភ្នែកធំៗ ចិញ្ចើមខ្មៅក្រាស់ ច្រមុះតូចស្រួច បបូរមាត់ស្តើង ទឹកមុខញញឹមស្រស់ហើយ ត្រចៀកគាត់សមនឹងទម្រង់មុខ រីឯសក់រួញអង្កាដី។ ដៃរបស់គាត់ស្រឡូន ចំណែកជើងពិការដោយសារ ជំងឺស្វិតដៃជើងតាំងពីតូច។ រាល់ពេលនិយាយស្តីម្តងៗសំឡេងគាត់ស្រួយស្រទន់ ប៉ុន្តែលឿនបន្តិច។ គាត់ពិការមិនអាចដើរបានទេ គាត់តែងអង្គុយលើរទេះ គាត់និយមស្លៀកពាក់ខោអាវណាមានពណ៌ស្រស់ៗ។ បងស្រីរៀនចប់នៅសកលវិទ្យាល័យ មុខវិជ្ជាភាសាអង់គ្លេស និងធ្វើការ ផ្នែករដ្ឋបាលក្នុងក្រុមហ៊ុនឯកជន មួយ។ គាត់ជាមនុស្សឧស្សាហ៍ព្យាយាមធ្វើការងារនិងទទួលខុសត្រូវ។ ខ្ញុំមិនដែលឃើញគាត់ត្អូញពី ភាពលំបាកម្តងណាឡើយ។ បងស្រីចរិយាទោះបីពិការជើងក៏ពិតមែនតែគាត់ មិនពិការចិត្តទេគឺគាត់ ប្រឹង ពុះពារធ្វើការគ្រប់យ៉ាងដើម្បីរកប្រាក់ចិញ្ចឹមជីវិតខ្លួនឯង។ខ្ញុំមិនរើសអើងនឹងគាត់ទេ។ យើងត្រូវគោរពនិង ឱ្យ តម្លៃដល់ពួកគាត់ ព្រោះពួកគាត់ក៏ជាមនុស្សដែលមានសមត្ថភាពដូចមនុស្ស ធម្មតាដែរ។

សរុបសេចក្តីមក បងចរិយាជាជនពិការក៏ពិតមែន តែគាត់ជាមនុស្សស្លូតត្រង់ មានសមត្ថភាព ជំនាញ និងចំណេះដឹងគ្រប់គ្រាន់ មានការងារធ្វើអាចរកប្រាក់សម្រាប់ចិញ្ចឹមជីវិតខ្លួនផង និងជួយគ្រួសារ ហើយគួរ ឱ្យកោតសរសើរនិងយកតម្រាប់តាមថែមទៀតផង។ ខ្ញុំគោរពនិងស្រឡាញ់បងស្រីចរិយាដូចបងស្រីខ្ញុំដែរ។

## អត្រាកំណែ

### ៧.១.៦- អត្រាពិន្ទុតែងសេចក្តីពណ៌នាអំពីមនុស្ស

អត្រាពិន្ទុតែងសេចក្តីពណ៌នាអំពីមនុស្សមានអត្រា១០/១០។ ក្រោយពីសិក្សាទ្រឹស្តីការណែនាំអំពីវិធី សាស្ត្រសរសេរ គម្រោងសរសេរ និងសេចក្តីអធិប្បាយជាឧទាហរណ៍បញ្ជាក់រួចមកលោកគ្រូអ្នកគ្រូត្រូវបង្ហាញសិស្សពីអត្រាពិន្ទុផងដែរ។ ការបង្ហាញពីអត្រាពិន្ទុជាវិធីមួយដើម្បីលើកទឹកចិត្តសិស្សដែលខំសរសេរ។ សិស្សនិង មានការសប្បាយរីករាយនូវលទ្ធផលរបស់ខ្លួនទៅតាមអ្វីដែលគ្រូបានណែនាំនិងចង់បាន។

រាល់កិច្ចការសិស្ស បើគ្មានការដាក់ពិន្ទុនោះទេ នោះក៏ហាក់ដូចជាពុំសូវមានភាពទាក់ទាញចាប់អារម្មណ៍ឱ្យចង់សរសេរដែរ។គ្រូត្រូវមានសិល្បវិធីក្នុងការបង្ហាញនូវកម្រិតពិន្ទុក្នុងគម្រោងសរសេរតែងសេចក្តី តាមផ្នែកនីមួយៗឱ្យបានច្បាស់លាស់។ សិស្សក៏មានទម្លាប់សរសេរដោយយកចិត្តទុកដាក់ព្យាយាមព្រោះ ចង់បានពិន្ទុច្រើនផងដែរ។ ខាងក្រោមនេះជាអាត្រាដាក់ពិន្ទុតាមផ្នែកនីមួយៗ។

## គម្រោងតែង

**ក- សេចក្តីផ្តើម** (១,៥០ពិន្ទុ)

- បង្ហាញមនុស្សនោះដោយប្រាប់ពី : ឈ្មោះ ភេទ អាយុ មុខរបរ។ (១,០០ពិន្ទុ)
- ទីលំនៅ : ការពណ៌នានេះតម្រូវឱ្យនិយាយអំពីសិស្សសាលាបង្ហាញពីទីកន្លែងសិក្សាផង (០,៥០ពិន្ទុ)។

**ខ- តួសេចក្តី** (៦,០០ពិន្ទុ)

**រូបសម្បត្តិ** (២,០០ពិន្ទុ)

រូបរាង មាឌ កម្ពស់ ពណ៌សម្បុរ ដោយពណ៌នាពីក្បាល ដងខ្លួនទៅអវយវៈ ឬពណ៌នាពីលើចុះក្រោម មុខមាត់ ភ្នែក ច្រមុះ សក់។

**ចរិយាសម្បត្តិ** (២,០០ពិន្ទុ)

ស្លូត កាច ឧស្សាហ៍ ព្យាយាម សុភាពរាបសា រម្យទម ទន់ភ្លន់ ថ្លៃថ្នូរ ខ្ជិល...។ អាកប្បកិរិយាក្នុងការនិយាយស្តី ដំណើរ ការឈរ អង្គុយ ការស្លៀកពាក់ និងសកម្មភាពផ្សេងៗដូចជាសកម្មភាពក្នុងគ្រួសារ ឬក្នុងសង្គម។

(១,០០ពិន្ទុ) **គុណសម្បត្តិ** : ចំណុចល្អរបស់មនុស្សដែលមានចំពោះគ្រួសារនិងសង្គមជាតិ។

***ឧទាហរណ៍ :*** យកចិត្តទុកដាក់រៀនសូត្រ ជួយការងារផ្ទះ ជួយទុក្ខធុរៈមិត្តភក្តិ ឬអ្នកដទៃ ឆ្លាត វាងវៃ ឆាប់យល់ដឹងចងចាំ ធ្វើការងារដោយផ្ចិតផ្ចង់។

(១,០០ពិន្ទុ) **គុណវិបត្តិ** : ចំណុចខ្វះខាត

***ឧទាហរណ៍ :*** ឆាប់ខឹង ឆេវឆាវ មករៀនយឺតម្តងម្កាល ។ល។

**គ. សេចក្តីបញ្ចប់** (១,៥០ពិន្ទុ)

(១,០០ពិន្ទុ) ការវាយតម្លៃ : បង្ហាញពីតម្លៃរបស់មនុស្ស។

***ឧទាហរណ៍ :*** ជាមនុស្សមានអត្តចរិតល្អ មានគំនិតមារយាទ ឬឫកពាសមរម្យ ថ្លៃថ្នូរ ចេះជួយគ្នាក្នុងពេលមានទុក្ខធុរៈ ឬពេលមានអាសន្នផ្សេងៗ។

(១,០០ពិន្ទុ) ចំណាប់អារម្មណ៍ : បង្ហាញពីមនោសញ្ចេតនាចំពោះមនុស្សនោះ ដូចជាអាណិត ស្រឡាញ់ ចូលចិត្ត គោរពរាប់អាន ឬក៏យកតម្រាប់តាម។

(១,០០ពិន្ទុ) **រចនាបថ** : អក្សរស្អាត សរសេរមានរបៀប មានឃ្លាល្បះត្រឹមត្រូវ និងគ្មានកំហុសអក្ខរាវិរុទ្ធ។

## ៧.២- ប្រធានពណ៌នាអំពីសត្វ

ការពណ៌នាអំពីសត្វ តម្រូវឱ្យអ្នកសរសេរចាប់ផ្តើមតាំងពីការបង្ហាញឈ្មោះ មូលហេតុនៃការចិញ្ចឹមសត្វទាំងនោះក្នុងសេចក្តីផ្តើមដោយផ្អែកលើការសង្កេត ពិនិត្យ ភាពពិតជាក់ស្តែងរបស់សត្វដែលយើងបានឃើញ។

តាមរយៈការរៀបរាប់ដោយប្រើបញ្ញាញាណ ស្មារតីក្នុងការសរសេរឱ្យមានរបៀបរៀបរយ ហើយអាចទាក់ទាញទឹកចិត្តអ្នកអាន អ្នកស្តាប់ ឱ្យជក់ចិត្ត ជិតអារម្មណ៍បន្តដល់តួសេចក្តី និងសេចក្តីបញ្ចប់។ បន្ទាប់មកនៅតួសេចក្តីអ្នកសរសេរត្រូវសង្កេតមើលទិដ្ឋភាពរួមរបស់សត្វ ដូចជា មាឌតូច ធំ ខ្ពស់ ទាប ពណ៌សម្បុរ រួចទើបពណ៌នា ផ្នែកផ្សេងៗទៀត។ ពិសេស ត្រូវរៀបរាប់ពីចំណុចសំខាន់ៗដែលគួរ ចាប់ អារម្មណ៍ និងជាផ្នែកដែលអាចធ្វើឱ្យគេ សម្គាល់រូបរាងសត្វនានាដែលចង់លើកយកមកបង្ហាញ ប៉ុន្តែពុំមែន និយាយសព្វគ្រប់មិនឱ្យចន្លោះត្រង់ណានោះទេ។ លើសពីនេះ ត្រូវរកលក្ខណៈពិសេសរបស់សត្វដែលត្រូវពណ៌នាឱ្យឃើញភាពខុសប្លែកពីសត្វដទៃក្នុងជំពូករបស់វា។ ក្រៅពីរូបខាងក្រៅ ត្រូវសរសេររៀបរាប់ពី ឥរិយាបថ ដូចជា ការដើរ រត់ ឈរ ហើរ សំឡេង សម្រែក ហែល... និងគំនិតប្រាជ្ញារបស់សត្វទាំងនោះផង។ នៅចុងបញ្ចប់នៃការសរសេរក្នុងតួសេចក្តីត្រូវបង្ហាញផលប្រយោជន៍នៃសត្វទាំងនោះទៀតផង ទោះបីសត្វ មានប្រយោជន៍ច្រើន ឬក៏តិចក៏ដោយ។ ចំណែក នៅក្នុងបញ្ចប់សេចក្តី អ្នកសរសេរ ត្រូវឱ្យតម្លៃទៅលើសត្វដែលបានរៀបរាប់ ឬសម្តែងមនោសញ្ចេតនាអាណិត ស្រឡាញ់ ចូលចិត្តចំពោះសត្វទាំងនោះ។

នៅក្នុងលំហែនាំនេះ លោកគ្រូអ្នកគ្រូអាចនាំសិស្សសិក្សាទៅលើគម្រោងតែងនិងសេចក្តីអធិប្បាយក្នុងឧទាហរណ៍មួយចំនួនខាងក្រោមនេះឱ្យបានច្បាស់លាស់។ ពិសេស ត្រូវហ្វឹកហាត់សិស្សឱ្យអនុវត្តការធ្វើសេចក្តី អធិប្បាយ ឬពណ៌នាឱ្យបានច្រើន។

**៧.២.១- ឧទាហរណ៍ទី១** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនពណ៌នាអំពីរូបរាងនិងផលប្រយោជន៍មេមាន់ដែលប្អូនចិញ្ចឹម។

## សេចក្តីពណ៌នា

**ក- សេចក្តីផ្តើម**

- ឈ្មោះមាន់
- បុព្វហេតុនៃការចិញ្ចឹមមាន់(បានពីណា ចិញ្ចឹមដើម្បីអ្វី)។

**ខ- តួសេចក្តី**

- បង្ហាញលក្ខណៈ : រូបរាង ពណ៌សម្បុរ រាងរៅ ក្បាល ភ្នែក ចំពុះ ខ្លួន រោម ស្លាប កន្ទុយ ជើង។
- ការរស់នៅរបស់វា: ពេលថ្ងៃ ពេលយប់។
- ផលប្រយោជន៍នៃការចិញ្ចឹមមាន់ ដូចជាផ្តល់សាច់ជាអាហារ លក់បានប្រាក់កម្រៃចិញ្ចឹមគ្រួសារ រោមសម្រាប់ធ្វើអំបោស អាចម៍មាន់ផ្តល់ជីដាក់ដំណាំ។ល។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: សត្វមាន់ដែលជាសត្វមានតម្លៃចំពោះមនុស្ស
- ចំណាប់អារម្មណ៍: ចំណូលចិត្តក្នុងការចិញ្ចឹមសត្វមាន់ព្រោះវាជាសត្វមានប្រយោជន៍លើកស្ទួយ ជីវភាពគ្រួសារ។

## សេចក្តីពណ៌នា

ខ្ញុំមានមេមាន់មួយ ឈ្មោះ ត្រសក់។ ខ្ញុំចិញ្ចឹមវាព្រោះជាពូជមាន់គក មានទម្ងន់ធ្ងន់ និងផ្តល់សាច់ ស៊ុត បានច្រើន។

មេត្រសក់មាន់ខ្ញុំ មានសម្បុរពណ៌ក្រហមលាយខ្មៅសបន្តិចៗឯមាឌធំខ្ពស់។ ក្បាលរបស់វាមានដុះរោមខ្លីតូចៗ គ្របដណ្តប់និងផ្នែកនៅពីលើក្បាលមានដុះសាច់ពករាងជាបន្ទះពណ៌ក្រហមហៅថា សិរមាន់។ ខ្លួនរបស់វាមាន រាងមូល ទ្រលុកទ្រលន់ហ៊ុមព័ទ្ធដោយរោមនិងស្លាបវែងៗ ភ្លឺរលើបរលោងគ្របពេញ ដងខ្លួន អមដោយរោមកន្ទុយត្រសាយ ត្រសុសវែង ងឡើងទៅលើប្រៀបដូចសក់ដែលគេចងយ៉ាងមាន សណ្តាប់ ធ្នាប់។ ភ្នែកមេត្រសក់មាន់ខ្ញុំមានពណ៌ខ្មៅ រាងមូលតូច អមដោយផ្ទៃស្បែកពណ៌ ក្រហមព្រឿងៗ។ ចំពុះវាមានពណ៌ស លាយខ្មៅ រាងស្រួចវែងខុបបន្តិច ងាយក្នុងការចឹកចំណីបានរហ័ស។ ចំណែកឯជើង ទាំងពីរធំ មាំ ហ៊ុមព័ទ្ធដោយស្បែកមានសណ្ឋានពកៗក្រាស់សម្រាប់ ទ្រទ្រង់ដងខ្លួន។ ឯក្រញាំជើងនីមួយៗ មានម្រាម និងក្រចកស្រួចជាអាវុធ ឬឧបករណ៍យ៉ាងសំខាន់ក្នុងការកាយ ចំណីចិញ្ចឹមជីវិត ។ រាល់ពេល ខ្ញុំមកដល់ផ្ទះវា តែងតែរត់ទទួលខ្ញុំ។ ពេលយប់មេត្រសក់មាន់ខ្ញុំដេកនៅក្នុងទ្រុងមួយខាង ក្រោយផ្ទះ។ សព្វថ្ងៃវាផ្តល់ស៊ុតបានចំនួនប្រាំគ្រាប់ហើយ។ ខ្ញុំចិញ្ចឹមមេមាន់នេះកាលដំបូង សម្រាប់ជាបទពិសោធ សិក្សាប៉ុណ្ណោះ ប៉ុន្តែមកដល់ពេលនេះមាន់ខ្ញុំបានផ្តល់ស៊ុតមកផ្គត់ផ្គង់ ម្ហូបអាហារ របស់គ្រួសារខ្ញុំថែមទៀត។ មេត្រសក់មាន់

ខ្ញុំ វាជា សត្វមានប្រយោជន៍ក្នុងការ ផ្តល់ស៊ុត កូន និងជាសត្វដែលធ្វើឱ្យខ្ញុំស្រឡាញ់ថែរក្សាវា បានកាន់តែ ល្អថែម ទៀត។

ខ្ញុំស្រឡាញ់មេត្រសក់មាន់ខ្ញុំណាស់ ខ្ញុំនឹងខិតខំចិញ្ចឹមថែទាំ ដាក់ចំណីឱ្យបានគ្រប់គ្រាន់ដើម្បីផ្តល់ ប្រយោជន៍ដល់ខ្ញុំ ពិសេសរកចំណូលថវិកាសម្រាប់គ្រួសារបានច្រើន។

**៧.២.២- ឧទាហរណ៍ទី២** (ថ្នាក់ ទី៣ ទី៤ ទី៥ និងទី៦)

**ប្រធាន** : ឪពុករបស់ប្អូនមានគោមួយនឹម។ ចូរប្អូនពណ៌នាអំពីគោណាមួយដែលប្អូនស្រឡាញ់។

## សេចក្តីពណ៌នា

**ក- សេចក្តីផ្តើម**

- គោញី គោឈ្មោល និងឈ្មោះគោ
- បុព្វហេតុដែលនាំឱ្យពេញចិត្តសត្វគោណាមួយដែលប្អូនស្រឡាញ់។

**ខ- តួសេចក្តី**

- បង្ហាញលក្ខណៈ: រូបរាង ពណ៌សម្បុរ មាឌ ក្បាល ដងខ្លួន ជើងកន្ទុយ
- ការរស់នៅ: ថ្ងៃ យប់ ឧស្សាហ៍ ខ្ជិល រហ័សរហួន ឬស្ទក់ ទម្រន់
- ការថែទាំ: ឱ្យចំណី ងូតទឹកដុសលាង សម្អាតទ្រុង
- ផលប្រយោជន៍ : ជាកម្លាំងអូសទាញ ជាសត្វងាយចិញ្ចឹម ស៊ីស្មៅ អត់ចំណាយដើមទុនច្រើនក្នុងការចិញ្ចឹម ស្រួលថែទាំ ជាសត្វធន់នឹងកម្តៅ ធ្វើការរហ័សរហួនជាងក្របី។ សាច់ជាអាហារ អាចម៍ឬលាមក ជាជីសម្រាប់ដំណាំ ស្បែកផ្តល់ប្រយោជន៍ដូចជា ខ្សែព្រ័ត្រ ជ័រការ ស្នែងជាគ្រឿងតាំងលម្អ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: បង្ហាញពីសត្វគោ ដែលជាសត្វមានប្រយោជន៍ចំពោះកសិករក្នុងការធ្វើស្រែចម្ការ
- ចំណាប់អារម្មណ៍: ចំណូលចិត្តក្នុងការចិញ្ចឹមសត្វគោព្រោះវាជាសត្វមានប្រយោជន៍លើកស្ទួយ ជីវភាពគ្រួសារ។

## សេចក្តីពណ៌នា

ឪពុកខ្ញុំមានគោមួយនឹមឈ្មោះចំរើន និងឈ្មោះសំណព្វ។ គោដែលខ្ញុំពេញចិត្តជាងគេគឺ គោឈ្មោល។ វាមានឈ្មោះថាសំណព្វព្រោះវាជាពូជ គោល្អក្នុងស្រុក។ ឪពុកខ្ញុំចិញ្ចឹមវាសម្រាប់ប្រើប្រាស់ជាមធ្យោបាយ ជួយសម្រួលការងារកសិកម្មក្នុងគ្រួសារ ។

សំណព្វគោខ្ញុំជាគោឈ្មោល មានសម្បុរពណ៌ត្នោត កម្ពស់ប្រហែលមួយម៉ែតហុកសិប មាឌធំ និងមានបូកព្រៃកខ្នងយ៉ាងស្អាត ឯក្បាលវាមានស្នែងពីរកោងចូលគ្នា នៅខាងគល់ស្នែងមានពណ៌ស ឯខាងចុងស្នែងមានពណ៌ខ្មៅរាង ស្រួចខុបចូលគ្នាបានពាក់កណ្តាលរង្វង់។ ជើងទាំងបួនរបស់វាធំៗហើយមាំសម្រាប់ទ្រទ្រង់ដងខ្លួន។ នៅពីក្រោយដងខ្លួនគោមានកន្ទុយមួយវែងធ្លាក់ទៅក្រោមរាង

ដូចអំបោសសម្រាប់បក់សត្វល្អិតដែលរំខានវា។ គោខ្ញុំបានជួយភ្ជួររាស់ដីស្រែចម្ការ និងអូសរទេះជារៀងរាល់រដូវបង្កបង្កើនផលនិងរដូវ ប្រមូលផល។ ពេលថ្ងៃវាធ្វើ ការងារភ្ជួររាស់ ដឹកជញ្ជូននៅស្រែចម្ការ។ ពេលយប់វាត្រូវដេកក្នុងទ្រុងមានដាក់មុងការពារកុំឱ្យ មូសខាំ។ សំណព្វគោខ្ញុំមានសុខភាពល្អ កម្លាំងខ្លាំងនិងរហ័ស ព្រោះវាស៊ីស្មៅ ស៊ីចំបើង និងគ្រាប់ធញ្ញជាតិជាអាហារ។ រាល់ពេលធ្វើការងារគ្រួសារខ្ញុំតែងស្ងើចសរសើរកម្លាំង និងការអត់ធន់របស់វា។ ខ្ញុំតែងតែឱ្យស្មៅនិងចំបើងវាស៊ីរាល់ថ្ងៃ។ ពេលរសៀលខ្ញុំដុសលាងសម្អាតខ្លួនវាម្តង រួចបោសសម្អាតទ្រុងមុនពេល ឱ្យវាចូលដេក ដើម្បីកុំឱ្យវាមានជំងឺ។ វាមានប្រយោជន៍ផ្តល់ជាកម្លាំងអូសទាញជាសត្វងាយចិញ្ចឹម ស៊ីស្មៅ មិនចំណាយដើមទុន ច្រើនក្នុងការចិញ្ចឹម ស្រួលថែទាំ ជាសត្វធន់នឹងកម្តៅ ធ្វើការរហ័ស រហួនជាងក្របី។ រីឯសាច់អាចផ្តល់ ជាអាហារ លាមកធ្វើជីសម្រាប់ដំណាំ ស្បែកផ្តល់ប្រយោជន៍ដូចជា ខ្សែព្រ័ត្រ ជ័រការស្នែងជាគ្រឿងតាំងលម្អ ជាដើម។

គោជាសត្វចតុបាទ គ្មានធ្មេញលើ វាស្លូតហើយជួយកម្លាំងអូសទាញដល់ប្រជាកសិករក្នុងការធ្វើ ស្រែចម្ការ។ ខ្ញុំស្រឡាញ់និងចូលចិត្តគោនេះណាស់ ព្រោះវាជាសត្វដែលមានប្រយោជន៍ហើយថែមទាំងរួមចំណែកលើកស្ទួយជីវភាពគ្រួសារខ្ញុំបានកាន់តែប្រសើរឡើង។

**៧.២.៣- ឧទាហរណ៍ទី៣** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

---

**ប្រធាន** : ចូរប្អូនពណ៌នាអំពីសត្វកុកដែលប្អូនបានស្គាល់ឬធ្លាប់បានឃើញ។

---

## សេចក្តីពណ៌នា

**ក- សេចក្តីផ្តើម**

- ពេលវេលាដែលបានឃើញកុក
- ទីកន្លែងដែលបានឃើញ។

**ខ- តួសេចក្តី**

- បង្ហាញលក្ខណៈ : រូបរាង ពណ៌សម្បុរ រាងរៅក្បាល ក ភ្នែក ចំពុះ ខ្លួន រោម ស្លាប កន្ទុយ ជើង
- ការរស់នៅ : ពេលថ្ងៃ ពេលយប់ ការរកចំណី
- ផលប្រយោជន៍ : ទាក់ទាញភ្ញៀវទេសចរ ឱ្យទៅកម្សាន្ត ផ្តល់សាច់ជាអាហារ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ : បង្ហាញពីសត្វកុកជាសត្វមានតម្លៃចំពោះមនុស្ស
- ចំណាប់អារម្មណ៍ : ចំណូលចិត្តនិងមនោសញ្ចេតនាក្នុងការកម្សាន្ត សត្វស្លាប ព្រៃលិចទឹក ដើម្បីបង្កើនជីវភាពប្រជាជនក្នុងតំបន់។

## សេចក្តីពណ៌នា

កាលពីថ្ងៃអាទិត្យមុនគ្រួសារខ្ញុំបានទៅកម្សាន្ត នៅកន្លែងអភិរក្សសត្វស្លាបស្ថិតនៅតំបន់ព្រែកទាល់ ក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង។ ពេលទៅដល់ខ្ញុំបានឃើញហ្វូងសត្វទុង ក្រសា ស្មោញ ប្រវឹក និងកុកជាច្រើន។ ក្នុងចំណោមហ្វូងសត្វទាំងអស់ ខ្ញុំជក់ចិត្តចាប់អារម្មណ៍នឹងសត្វកុកច្រើនជាងគេ។

កុកជាប្រភេទសត្វស្លាបដែលស្អាតប្លែកម្យ៉ាងពីគេក្នុងចំណោមសត្វទាំងអស់ ព្រោះវាមានសម្បុរស។ ក្បាល របស់វាមូលដុះរោមខ្លីៗតូចៗគ្របដណ្ដប់។ ខ្លួនរបស់វាតូចល្មម ហ៊ុមព័ទ្ធដោយរោមនិងស្លាបវែងៗ ពណ៌សភ្លឺរលោងរលើបគ្របពេញដងខ្លួននិងអមដោយរោមកន្ទុយវែងផងដែរ។ បើពិនិត្យឱ្យបានជិតខ្ញុំ ឃើញ សត្វកុក មានភ្នែក ពណ៌ខ្មៅមូលតូចៗ មាត់វាជាចំពុះវែងស្រួចពណ៌ខ្មៅ កនិងជើងរបស់វា វែងៗខុស ពី សត្វ ស្លាបដទៃទៀតដែល ធ្វើឱ្យយើងងាយចំណាំនិងងាយស្គាល់បាន។ កុកចូលចិត្តរស់នៅ តំបន់ព្រៃរនាម ជា ព្រៃលិចទឹក ឬកន្លែងដែលមាន ទឹកមិនដាច់។ ពេលថ្ងៃ កុកតែងតែហើរជាហ្វូងៗចុះចាប់ ចំណីនៅតាមទឹក ទន្លេសាប ស្ទឹង បឹង ឬវាលស្រែ ដែលជាកន្លែងមានចំណីសម្រាប់ពួកវា។ កុកស៊ីត្រី ខ្ចៅ លៀសជាអាហារ។ ពេលយប់វារស់នៅអាស្រ័យដើមឈើជាជម្រក។ បក្សីព្រៃនេះត្រូវការទឹក និងព្រៃជា ចាំបាច់ក្នុងការរស់នៅ។ កុកជាសត្វបក្សីដែលមានភាពទាក់ទាញចំពោះ ភ្ញៀវទេសចរជាតិ អន្តរជាតិ។ ពិសេស នៅតំបន់ព្រែក ទាល់ ដែលធ្វើឱ្យប្រជាពលរដ្ឋរកប្រាក់ចំណូលបានច្រើនហើយវាក៏ជាប្រភេទសត្វ បក្សីម៉្យាងដែលរួមចំណែកលម្អបរិស្ថានបានល្អផងដែរ។

កុកជាសត្វបក្សីមានប្រយោជន៍ចំពោះបរិស្ថាននិងធម្មជាតិ។ ខ្ញុំនិងគ្រួសារខ្ញុំស្រឡាញ់ ដក់ចិត្តចាប់អារម្មណ៍មើលហ្វូងសត្វកុកទាំងអស់គ្នា។ ដូច្នេះ យើងទាំងអស់គ្នាត្រូវចូលរួមអភិរក្សនិងជួយថែរក្សាព្រៃលិច ទឹកដែល ជាជម្រករបស់ពួកវាឱ្យបានគង់វង្ស។

**៧.២.៤- ឧទាហរណ៍ទី៤** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនពណ៌នាអំពីសត្វក្ងោកដែលប្អូនបានស្គាល់ឬធ្លាប់បានឃើញ។

## សេចក្តីពណ៌នា

**ក. សេចក្តីផ្តើម**

- ពេលវេលាដែលបានឃើញសត្វក្ងោក
- កន្លែងដែលបានឃើញសត្វក្ងោក។

**ខ- តួសេចក្តី**

- លក្ខណៈរូបរាងៈ ពណ៌សម្បុរ ក្បាល ភ្នែក ចំពុះ រោម ស្លាប កន្ទុយ ជើង
- ការរស់នៅៈ ក្នុងព្រៃ លើដើមឈើធំៗនិងស៊ីគ្រាប់ធញ្ញជាតិ សត្វល្អិតជាអាហារ
- ផលប្រយោជន៍ៈ ជួយលម្អបរិស្ថាន ទាក់ទាញភ្ញៀវទេសចរអាចយកមកចិញ្ចឹម។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃៈ សត្វក្ងោកជាសត្វកម្រ មានតម្លៃនិងមានសម្រស់ល្អលើសសត្វដទៃ លម្អបរិស្ថាន ធម្មជាតិប្រកបដោយភាពទាក់ទាញ
- ចំណាប់អារម្មណ៍ុយៈ ស្រឡាញ់មានចំណូលចិត្តក្នុងការមើល ជួយអភិរក្ស ការពារកុំសម្លាប់។

## សេចក្ដីពណ៌នា

កាលពីថ្ងៃអាទិត្យមុនខ្ញុំនិងក្រុមគ្រួសារបានទៅកម្សាន្តនៅរមណីយដ្ឋានភ្នំតាម៉ៅដែលស្ថិតនៅក្នុងខេត្តតាកែវ។ ពេលនោះខ្ញុំបានឃើញសត្វស្លាបជាច្រើន។ ក្នុងចំណោមសត្វស្លាបទាំងអស់ ខ្ញុំចាប់អារម្មណ៍ ទៅលើសត្វក្ងោកជាងគេ។

ក្ងោកជាបក្សីកម្រ វាស្អាតហើយស្លូត។ សត្វក្ងោកមានសណ្ឋានស្រដៀងសត្វមាន់ តែមាឌវាធំជាងមាន់។ ដងខ្លួនក្ងោកមានរោមពណ៌បៃតងលាយខ្មៅសបន្តិចហ៊ុមព័ទ្ធជុំវិញនិងមានពន្លឺភ្លឺរលោងចែងចាំង។ នៅលើផ្ទាំងស្លាបទាំងពីរក៏មានរោមស្លាបវែងៗដែរ។ រីឯកន្ទុយក្ងោកវិញមានដុះស្លាបវែងប្រហែលជាងមួយម៉ែត្រនិងមានពណ៌បៃតងហើយអុចៗខ្មៅនៅកណ្តាលគ្រប់ទងស្លាបទាំងអស់។ ចៃដន្យណាស់ ពេល នោះខ្ញុំបានឃើញក្ងោកត្រដាងស្លាបនិងពង្រីកកន្ទុយយ៉ាងធំបានប្រហែលពាក់កណ្តាលរង្វង់មូល។ ពេល នោះទើបខ្ញុំដឹងថាក្ងោកជាសត្វមានសម្បុររោមល្អជាងគេ នៅពេលលាកន្ទុយ ព្រោះវាភ្លឺរលើបរលោងហើយធំ បាំងគ្របជិតដងខ្លួន។ ខ្ញុំពិតជាមិនហ៊ានព្រិចភ្នែក និងចំហមាត់ថែមទៀតផង។ ចំណែកឯជើងទាំងពីររបស់ ក្ងោកមានរាងធំមាំនិងមានក្រញ៉ាំម្រាមហ៊ុមព័ទ្ធដោយស្បែកជាតិស្នែង។ ក្ងោកមានភ្នែកខ្មៅមូលតូចនិងមាន ចំពុះរាងស្រួចវែងខុបបន្តិចងាយក្នុងការចឹកចំណីបានរហ័ស។ វាជាសត្វមានប្រយោជន៍សម្រាប់លម្អបរិស្ថាន និងទាក់ទាញភ្ញៀវទេសចរចង់ឱ្យគយគន់ទស្សនា។ ជាពិសេស វាជានិមិត្តរូបនៃរបាំខ្មែរដែលគេនិយមហៅថា "របាំក្ងោក"។

ក្ងោកជាសត្វមានរូបសម្រស់ល្អលើសសត្វដទៃនិងលម្អបរិស្ថានធម្មជាតិប្រកបដោយភាពទាក់ទាញ។ ខ្ញុំស្រឡាញ់សត្វក្ងោកនិងចូលចិត្តមើលវាពុំដាក់ភ្នែក។ ដូច្នេះ យើងត្រូវរក្សាការពារព្រៃនិងដាំដើមឈើបន្ថែម ដើម្បីជាជម្រករបស់ក្ងោក។ លើសពីនេះទៀតគឺ មិនត្រូវសម្លាប់វាដើម្បីបំពេញតម្រូវការរបស់យើងឡើយ។

**៧.២.៥- ឧទាហរណ៍ទី៥** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

---

**ប្រធាន** : ចូរប្អូនពណ៌នាអំពីសត្វសេកដែលប្អូនធ្លាប់បានឃើញ។

---

## សេចក្ដីពណ៌នា

**ក- សេចក្តីផ្តើម**

- ពេលវេលាដែលបានទៅឃើញ
- ទីកន្លែងដែលបានឃើញសត្វសេកនៅកន្លែងណាមួយ។

**ខ- តួសេចក្តី**

- លក្ខណៈ: រូបរាង ពណ៌សម្បុរ ក្បាល ភ្នែក ចំពុះ រោម ស្លាប កន្ទុយ ជើង ម្រាមជើង
- ការរស់នៅ: ក្នុងព្រៃ លើដើមឈើធំៗនិងស៊ីផ្លែឈើ គ្រាប់ធញ្ញជាតិ
- ផលប្រយោជន៍: ជួយលម្អបរិស្ថាន ទាក់ទាញមនុស្សឱ្យចង់មើល អាចយកមកចិញ្ចឹម អាចនិយាយ គ្រាប់តាមភាសាមនុស្សបានមួយម៉ាត់ៗ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ជាសត្វបក្សីមានរូបរាងតូចតែពណ៌សម្បុរល្អ ចេះគ្រាប់ភាសាមនុស្ស
- ចំណាប់អារម្មណ៍: ស្រឡាញ់ ចូលចិត្តសត្វសេក ត្រូវចូលរួមថែរក្សា ការពារ កុំសម្លាប់។

## សេចក្តីពណ៌នា

កាលពីថ្ងៃវិស្សមកាលតូចកន្លងទៅថ្មីៗនេះ ខ្ញុំបានធ្វើដំណើរទៅកម្សាន្តនៅខេត្តសៀមរាប។ ពេលនោះខ្ញុំទៅលេងប្រាសាទតាព្រហ្មក៏បានឃើញសត្វសេកមួយកំពុងទំលើដើមឈើក្បែរប្រាសាទ។

សត្វសេកមួយនេះមានរោមពណ៌បៃតងស្រស់ស្អាត។ វាមានមាឌតូចល្មម ក្បាលវាមូល ដងខ្លួនរាងវែងបន្តិច។ សត្វសេកមានរោមនិងស្លាបវែងៗភ្លឺរលើបរលោងពណ៌បៃតងស្រស់គ្របពេញដងខ្លួន។ ស្លាបកន្ទុយសេកវែងល្មម។ ពេលខ្ញុំទៅជិតឃើញភ្នែកវា ពណ៌ខ្មៅរាងមូលតូច មានចំពុះពណ៌ក្រហមខុបចូលក្នុងបន្តិច ហើយធំ ងាយស្រួលក្នុងការចឹកចំណីអាហារបានច្រើន និងរហ័សទៀត។ ចំណែកជើងទាំងពីររបស់វាមានម្រាមនិងក្រចកស្រួចៗ ពណ៌លឿង ជាឧបករណ៍សំខាន់ក្នុងការខ្ទាំចំណី។

សេកជាសត្វដែលរស់នៅក្នុងព្រៃ ស៊ីផ្លែឈើនិងគ្រាប់ធញ្ញជាតិជាអាហារ។ ខ្ញុំគិតថា សេកជាសត្វមាន ប្រយោជន៍សម្រាប់យើងទាំងអស់គ្នា ព្រោះវាជួយលម្អបរិស្ថានធម្មជាតិ ទាក់ទាញភ្ញៀវទេសចរឱ្យចង់គយគន់នៅពេល ដែលបានឃើញវា។ មិនតែប៉ុណ្ណោះ បើគេយកសេកមកចិញ្ចឹមក្នុងផ្ទះ ហើយបង្រៀនវា ឱ្យចេះនិយាយវាអាចនិយាយ គ្រាប់តាមភាសាមនុស្សបានមួយម៉ាត់ៗថែមទៀត។ សេកអាចប្រាប់ ឬហៅម្ចាស់ផ្ទះនៅពេលមានមនុស្សចូលផ្ទះ ។

សេកជាប្រភេទបក្សី ឬសត្វស្លាបតូច តែមានពណ៌បៃតងស្រស់ស្អាត។ ខ្ញុំស្រឡាញ់ហើយចូលចិត្តសត្វសេកនេះណាស់ ព្រោះវាជាសត្វស្លូត ចេះគ្រាប់ភាសាមនុស្សបានតិចៗនិងមានសំឡេងពីរោះគួរចង់សើចនិងស្ងើចសរសើរ ហើយមានប្រយោជន៍ចំពោះយើង។ ដូច្នេះ យើងទាំងអស់គ្នាត្រូវចូលរួមថែរក្សាការពារនិងមិនសម្លាប់វាធ្វើជាអាហារឡើយ។

**៧.២.៦- ឧទាហរណ៍ទី៦** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

---

**ប្រធាន** : ម្តាយប្អូនចិញ្ចឹមជ្រូកមួយក្បាល។ ចូរប្អូនពណ៌នាអំពីជ្រូកចិញ្ចឹមនោះ។

---

## សេចក្តីពណ៌នា

**ក- សេចក្តីផ្តើម**

- ជ្រូក ញី ឬឈ្មោល ឈ្មោះអ្វី អាយុ
- ពេលវេលានៃការចិញ្ចឹមតាំងពីពេលណា យកមកចិញ្ចឹមតាំងពីតូច ឬធំទើបចិញ្ចឹម។

**ខ- តួសេចក្តី**

- លក្ខណៈរូបរាង: ពណ៌សម្បុរ មាឌ (ធំឬតូច)រោម ស្បែក ក្បាល ភ្នែក ត្រចៀក មាត់ ច្រមុះ ជើង កន្ទុយ ដំណើរ ដេក ពេលវាឃ្លាន ពេលឃើញប្អូនយកចំណីឱ្យស៊ី ពេលស៊ី
- ផលប្រយោជន៍: សាច់និងស្បែកជាអាហារ លាមកជាជីសម្រាប់កសិកម្ម ធ្វើជាជីជីវឧស្ម័ន...។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: សត្វជ្រូក ជាសត្វចិញ្ចឹមមានប្រយោជន៍ផ្តល់សាច់ជាអាហារ និងថវិកា
- ចំណាប់អារម្មណ៍ : ចំណូលចិត្តក្នុងការចិញ្ចឹមសត្វជ្រូក ព្រោះវាជាសត្វមានប្រយោជន៍អាចយកទៅលក់បានថវិកាលើកស្ទួយជីវភាពគ្រួសារ។

## សេចក្តីពណ៌នា

ម្តាយខ្ញុំបានចិញ្ចឹមជ្រូកញីមួយក្បាល។ ជ្រូកនោះឈ្មោះអ៊ុជ ជាពូជជ្រូកហៃណាំ។ ម្តាយខ្ញុំបានយកវាមកចិញ្ចឹមតាំងពីតូចអាយុបីខែកន្លះ។

អ៊ុជ ជ្រូករបស់ខ្ញុំ វាមានសម្បុរស មាឌធំហើយខ្ពស់។ វាមានទម្ងន់ប្រហែលសែសិបគីឡូក្រាម។ ជ្រូកនេះមានក្បាលរាងបួនជ្រុងទ្រវែងនិងមានមាត់ធំ ភ្នែកខ្មៅថ្លាគ្រប់ដណ្តប់ដោយរោមភ្នែកពណ៌សក្បុស។ វាមានត្រចៀកពីរធំៗ រាងបាក់ខុបនៅលើក្បាល រីឯស្បែកនិងរោមវិញគឺពណ៌សលាយក្រហមបានជាសម្បុរពណ៌ផ្កាឈូក។ ជ្រូកនេះមាន ដងខ្លួនទ្រវែង ឯខ្នងអែនបន្តិច។ ចំណែកកន្ទុយវាវែងពណ៌ស ហើយមានរោមនៅចុងកន្ទុយ មើលទៅដូចជាអំបោស តូចមួយសម្រាប់បក់ ឬបោសសត្វល្អិត។ ជ្រូកមានជើងបួនហើយមានក្រចកនៅខាងចុងម្រាម។ ជ្រូកខ្ញុំស្រែកឮសូរអ៊្ញុកៗខ្លាំងៗ។ រាល់ពេលឃ្លានវាស្រែក ហើយយកច្រមុះ ទៅគាស់ទ្រុងឱ្យសំឡេងឮដល់ម្ចាស់។ ពេលស៊ីបាយវាត្របាក់ឮសូរ ផ្លាប់ៗរហូត អស់កាកបាយ រួចវាបឺតទឹក ពេលក្រោយ។ រាល់ថ្ងៃគ្រួសារខ្ញុំតែងតែ បោសសម្អាតទ្រុងវាឱ្យបានស្អាតជានិច្ច ចៀសវាងកុំឱ្យវាកើតជំងឺ ផ្សេងៗ។ ពេលវាឈឺ ខ្ញុំបានហៅពេទ្យសត្វមកព្យាបាលដោយចាក់ថ្នាំ ឬបញ្ចុកថ្នាំ។ អ៊ុជជ្រូកខ្ញុំពីមួយថ្ងៃទៅ មួយថ្ងៃកាន់តែធំធាត់។ ខ្ញុំសង្ឃឹមថា ថ្ងៃក្រោយវានឹងមានកូនច្រើនអាចយកទៅលក់បានថវិកាសម្រាប់ប្រើប្រាស់ក្នុងជីវភាពគ្រួសារខ្ញុំកាន់តែសម្បូរសប្បាយ។

អ៊ុជ ជ្រូកខ្ញុំជាសត្វចិញ្ចឹមយកសាច់និងកូនក៏ពិតមែន តែខ្ញុំមានមនោសញ្ចេតនាស្រឡាញ់ណាស់ ព្រោះវាចេះ ស្តាប់ខ្ញុំនិយាយបានខ្លះៗដូចមនុស្ស គ្រួសារខ្ញុំនឹងមានជីវភាពល្អប្រសើរប្រសិនបើវាកើតកូនបានច្រើនលក់បានថ្លៃ។

**៧.២.៧- ឧទាហរណ៍ទី៧** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

---

**ប្រធាន** : មិត្តភក្តិរបស់ប្អូនម្នាក់បានឱ្យឆ្កែមួយដល់ប្អូន។ ចូរប្អូនពណ៌នាអំពីឆ្កែនោះ។

---

## សេចក្តីពណ៌នា

**ក- សេចក្តីផ្តើម**

- ឆ្កែញី ឬឈ្មោល ឈ្មោះអ្វី អាយុ
- ពេលវេលានៃការចិញ្ចឹម។

**ខ- តួសេចក្តី**

- បង្ហាញលក្ខណៈ: រូបរាង មាឌ តូចឬធំ ធាត់ឬស្គម ខ្ពស់ឬទាប មុខមាត់ ច្រមុះ ត្រចៀក ភ្នែក រោមពណ៌ ធ្មេញ ចង្កូម ជើង កន្ទុយ ក្រចក
- ឥរិយាបថ: ដំណើរ ការរត់ លោត សម្រែក សំឡេងព្រូស វាចេះឬល្ងង់ កាយវិការ ពេលឃើញប្អូនឬ អ្នកនៅក្នុងផ្ទះនិងអ្នកដទៃ វាមានចរិតកាចឬស្លូត ឧស្សាហ៍ ឬខ្ជិល
- ផលប្រយោជន៍ : ចាំផ្ទះ ដេញចាប់សត្វផ្សេងៗ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: សត្វឆ្កែជាឆ្មាំដ៏សំខាន់និងតំណាងឱ្យភាពស្មោះត្រង់

- ចំណាប់អារម្មណ៍: ចំណូលចិត្តក្នុងការចិញ្ចឹមសត្វឆ្កែ ព្រោះវាជាសត្វមានប្រយោជន៍ចំពោះម្ចាស់។

## សេចក្ដីពណ៌នា

កាលពីប៉ុន្មានខែមុនខ្ញុំបានទៅលេងផ្ទះមិត្តរួមថ្នាក់ម្នាក់។ ពេលទៅដល់ក៏ឃើញមិត្តខ្ញុំមានកូនឆ្កែចិញ្ចឹមយ៉ាងច្រើន។ ខ្ញុំមានចំណាប់អារម្មណ៍ទៅលើកូនឆ្កែទាំងនោះយ៉ាងខ្លាំង ព្រោះចង់ចិញ្ចឹមវាដែរ។ មិត្តខ្ញុំ ក៏បានប្រគល់កូន ឆ្កែឈ្មោលមួយឱ្យខ្ញុំដើម្បីចិញ្ចឹម។ ឥឡូវនេះវាមានអាយុបានបីខែ ហើយនិងចេះស៊ីបាយបាន។ ខ្ញុំបានដាក់ឈ្មោះឱ្យវា ថាអាលុក។

អាលុកឆ្កែ ខ្ញុំឥឡូវនេះវាមានមាឌធំ ហើយសង្ហាទៀត។ វាមានសម្បុរពណ៌ខ្មៅ និងមានរោមក្រាស់ភ្លឺរលោង ស្អាតគួរឱ្យចង់កាន់អង្អែលលេង។ ក្បាលវាធំសមនឹងដងខ្លួន។ មុខវារាងទ្រវែង មាត់តូចខ្លីមានចង្កូមស្រួច តូចៗ ធ្មេញស ហើយតូចល្អិត ច្រមុះស្រួចហើយមានជាតិសំណើម។ ភ្នែកវាមូលៗភ្លឺថ្លាខ្មៅក្រិប។ ត្រចៀកវា ធំវែងហើយបាក់ចុះធ្លាក់ មកក្រោម។ កន្ទុយវាមានរោមរីកសំពោងដូចកន្ទុយស្ការ។ រីឯជើងវាខ្លីៗរឹងមាំល្អ។ វាចូលចិត្តឈរឬ ដើរជើងពីរ និងពេលខ្លះវាឈរជើងក្រោយ ឯជើងមុខទាំងពីរលើកឡើងលើដូចលើកដៃសំពះ។ អាលុកមានឫកពា រហ័សរហួននិងក្លាហាន។ នៅពេលមានភ្ញៀវមកលេងផ្ទះម្ដងៗវាតែងតែបក់កន្ទុយទទួលភ្ញៀវដែលវាស្គាល់។ បន្ទាប់មកនាំផ្លូវភ្ញៀវចូលក្នុងផ្ទះ។ បើភ្ញៀវណាដែលវាមិនស្គាល់ វាព្រូសគ្រហឹមដាក់ហាក់ដូចមិនចង់ឱ្យភ្ញៀវចូលផ្ទះនិងជាសញ្ញាប្រាប់ដល់ម្ចាស់ផ្ទះ។ ឆ្កែខ្ញុំចេះណាស់វាមិនព្រូសនិងមិនដេញខាំមនុស្សផ្ដេសផ្ដាសឡើយ។ នៅពេលយប់បើវាឃើញមានអ្វីប្លែក វាព្រូសហើយគ្រហឹមមិនឈប់ឡើយ។ ខ្ញុំតែងតែឱ្យបាយវាស៊ីបានគ្រប់គ្រាន់ និងងូតទឹកសម្អាតខ្លួនវាជាប្រចាំ។ រាល់ពេលវាឈឺខ្ញុំ តែងតែយកវាទៅឱ្យពេទ្យសត្វពិនិត្យនិងព្យាបាលចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតឱ្យវាទៀតផង។ អាលុកជាឆ្កែឧស្សាហ៍ចាំ ផ្ទះ មិនខ្ជិលទ្រមក់។

អាលុកឆ្កែខ្ញុំចេះណាស់។ វាមិនដែលដើរជុះឬស៊ីអ្វីផ្ដេសផ្ដាសទេ។ ខ្ញុំស្រឡាញ់អាលុកឆ្កែខ្ញុំណាស់ ព្រោះវាជាឆ្មាំពិសេសគួរជាទីទុកចិត្តប្រចាំផ្ទះខ្ញុំ។ គ្រួសារខ្ញុំស្រឡាញ់អាលុកទាំងអស់គ្នា ដោយសារវាមានចរិតស្មោះត្រង់ដូចឆ្កែដទៃដែលគេសន្មតថា វាជាតំណាងភាពស្មោះត្រង់ចំពោះម្ចាស់គ្រប់រូប។

**៧.២.៨- ឧទាហរណ៍ទី៨** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនពណ៌នាអំពីសត្វឆ្មាដែលប្អូនបានចិញ្ចឹម។

## សេចក្ដីពណ៌នា

**ក- សេចក្ដីផ្ដើម**

- ឆ្មាញី ឬឈ្មោល ឈ្មោះអ្វី អាយុ
- ពេលវេលានៃការចិញ្ចឹម។

**ខ- តួសេចក្ដី**

- បង្ហាញលក្ខណៈ :រូបរាង ធាត់ឬស្គម មាឌ តូចឬធំ  ខ្ពស់ ទាប មុខមាត់ ត្រចៀក ភ្នែក រោម ពណ៌ ធ្មេញ ចង្កូម ជើង កន្ទុយ ក្រចក

- ឥរិយាបថ: ដំណើរ ការរត់ លោត សម្រែក សំឡេង ចេះឬល្ងង់ កាយវិការ ពេលឃើញប្អូន ឬអ្នកនៅ ក្នុងផ្ទះនិងអ្នកដទៃ កាចឬស្លូត ឧស្សាហ៍ឬខ្ជិល
- ផលប្រយោជន៍ : ជាឆ្មាំ ជាសត្វលម្អក្នុងផ្ទះ ជាសត្វនាំមកនូវសេចក្តីសុខចម្រើន ជាសត្វដែលពូកែចាប់កណ្តុរ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: សត្វឆ្មាដែលជាឆ្មាំនិងជានិមិត្តរូបនៃសេចក្តីរីកចម្រើនដល់ម្ចាស់
- ចំណាប់អារម្មណ៍: ចំណូលចិត្តចំពោះសត្វឆ្មាព្រោះវាជាសត្វមានប្រយោជន៍ចំពោះម្ចាស់។

## សេចក្តីពណ៌នា

នៅផ្ទះខ្ញុំមានចិញ្ចឹមឆ្មាឈ្មោលមួយក្បាលមានឈ្មោះថាសម្បុរបី។ ឪពុកខ្ញុំបានយកវាមកចិញ្ចឹមបានបីខែហើយ។ ឥឡូវនេះវាមានអាយុជាងមួយឆ្នាំ។

សម្បុរបីឆ្មាខ្ញុំមានមាឌតូចតែធាត់។ ក្បាលវាតូចមានភ្នែកមុតថ្លានិងមានពន្លឺពណ៌បៃតងចាំងដូចភ្លើងពិលនៅពេលយប់។ ច្រមុះវាតូច និងមានឆ្អឹតពណ៌ស។ ឆ្មាខ្ញុំមានមាត់ធំល្មម មានធ្មេញតូចល្អិតៗនិងមានចង្កូមវែងៗបួនគឺចង្កូមលើពីរនិងក្រោមពីរ។ ដងខ្លួនវាវែងទន់ភ្លន់គ្របដណ្តប់ដោយរោមវែងៗទន់ដូចសំឡី។ រោមវាមានបីពណ៌គឺ ពណ៌ស ខ្មៅ និងពណ៌ទង់ដែង។ ជើងវារឹងមាំណាស់ហើយនៅចុងម្រាមនីមួយៗមានក្រចកស្រួចៗហើយមុតខ្លាំង។ វា តែងតែតោង ឬឡើងលើទីខ្ពស់ដោយប្រើក្រញាំក្រចករបស់វា។ សម្បុរបីមានកន្ទុយវែងហើយរាងកូក់ចុងបន្តិច។ វាជាសត្វហ័សរហ័នក្នុងការរត់លោត ហក់ តោង ឬដេញចាប់ កណ្តុរ។ នៅពេលឃ្លានចំណីវាតែងតែ ស្រែកម៉េវៗហើយយកក្បាលនិងខ្លួនវាមកត្រដុសនឹងជើងរបស់ខ្ញុំ។ វាមិនចេះលួចស៊ីត្រី សាច់ ផ្តេសផ្តាសទេ។ នៅពេលមានភ្ញៀវ ឬមនុស្សដទៃមកលេងផ្ទះ វាអង្គុយសម្លឹងមើលមុខភ្ញៀវ ហើយស្រែកម៉េវៗ ដើម្បីបញ្ជាក់ពីការស្វាគមន៍ទៅកាន់ភ្ញៀវ។ ខ្ញុំតែងសម្អាតនិងងូតទឹក ដុសសាប៊ូ ដើម្បីកុំឱ្យមានចៃ មានក្លិនមិនល្អ និងចៀសវាងពីជំងឺ ផ្សេងៗ នៅពេលវាឈឺ ខ្ញុំយកវាទៅឱ្យគ្រូពេទ្យសត្វព្យាបាលនិងចាក់ថ្នាំបង្ការជំងឺជាញឹកញាប់។ សម្បុរបីជាសត្វមានប្រយោជន៍សម្រាប់ផ្ទះខ្ញុំណាស់ ដូចជាវាចេះចាប់កណ្តុរ ចាប់សត្វល្អិត ជាឆ្មាំនិងជាសត្វលម្អគេហដ្ឋានជាដើម។ ម៉្យាងទៀតឪពុកខ្ញុំតែងនិយាយថាសម្បុរបីជាសត្វ នាំមកនូវសេចក្តីសុខចម្រើននិងលាភសំណាងដល់ម្ចាស់។

សម្បុរបីឆ្មាខ្ញុំ ជាពូជឆ្មាខ្មែរ មានពណ៌សម្បុរល្អទាក់ទាញខ្ញុំនិងក្មេងដទៃគួរឱ្យចង់ឱបលេង ខ្ញុំស្រឡាញ់ចូលចិត្តចិញ្ចឹមឆ្មាណាស់ ព្រោះវាជាសត្វមានប្រយោជន៍។ ពេលខ្លះវាក៏អាចជួយចៃករំលែកភាពនឿយហត់និង ធុញទ្រាំ នៅពេលដែលវាលេងជាមួយយើងនិងកែភាពអផ្សុកម្តងម្កាលដែរ ។

**៧.២.៩- ឧទាហរណ៍ទី៩** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនពណ៌នាអំពីសត្វដំរីដែលប្អូនបានឃើញ។

## សេចក្តីពណ៌នា

**ក- សេចក្តីផ្តើម**

- ដំរី ញីឬឈ្មោល អាយុ
- ពេលវេលានិងទីកន្លែងដែលប្អូនបានឃើញដំរីនោះ។

**ខ- តួសេចក្តី**

- លក្ខណៈរូបរាង: មាឌ កម្ពស់ ពណ៌សម្បុរ ស្បែក ក្បាល ប្រមោយ ភ្លុក ត្រចៀក ភ្នែក ខ្លួន ជើង កន្ទុយ ត្រចៀក ភ្នែក រោម ពណ៌ ជើង កន្ទុយ ក្រចក ភ្លុក
- ឥរិយាបថ: ពេលដើរ ពេលឈរ ពេលស៊ី
- ផលប្រយោជន៍: ប្រើសម្រាប់ជាមធ្យោបាយដឹកជញ្ជូន ជាជំនិះប្រើក្នុងសឹកសង្គ្រាមសម័យបុរាណ ទាក់ទាញទេសចរបានប្រាក់ចំណូល ភ្លុកជាគ្រឿងតាំងលម្អ ឬគ្រឿងអលង្ការ ជាមធ្យោបាយដឹកអ្នក ដំណើរនិងភ្ញៀវទេសចរ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ដំរីជាសត្វដែលមានតម្លៃនិងជាសត្វកម្រ
- ចំណាប់អារម្មណ៍: ចំណូលចិត្ត ព្រោះវាជាសត្វមានប្រយោជន៍ត្រូវថែរក្សាការពារ មិនបាញ់សម្លាប់។

## សេចក្តីពណ៌នា

កាលពីសប្តាហ៍មុនខ្ញុំបានធ្វើដំណើរទៅកំសាន្តនៅភ្នំបាខែង ខេត្តសៀមរាប។ នៅទីនោះមានភ្ញៀវទេសចរទៅកម្សាន្តច្រើនណាស់ អ្នកខ្លះឡើងលើភ្នំបាខែង ឯអ្នកខ្លះទៀតជិះដំរីកម្សាន្ត។ ពេលនោះ ខ្ញុំបានចាប់អារម្មណ៍ ទៅលើដំរីឈ្មោលមួយក្បាលដែលមានអាយុប្រហែលម្ភៃឆ្នាំ។

ដំរីមួយនោះមានមាឌធំខ្ពស់។ វាមានកម្ពស់ប្រហែលជាងបីម៉ែត្រ ហើយមានសម្បុរប្រផេះក្រមៅ។ ក្បាលវាធំ ហើយព្រែកនៅចំកណ្តាល។ ភ្នែកវាតូចៗតែខ្មៅ។ ប្រមោយដំរីមានរាងមូល ហើយធំគល់ ស្រួចចុង និងវែងមានសណ្ឋានដូចដៃ ឬតម្ពក់។ ប្រមោយនោះអាចកម្រើក ឬចាប់កាន់វត្ថុផ្សេងៗយកមកស៊ីបាន។ នៅសងខាងប្រមោយខ្ញុំឃើញភ្លុក ធំវែងៗពីរពណ៌ស ហើយកោងបន្តិចដុះលូតចេញមកខាងក្រៅ។ បន្ទាប់ពីក្រោមប្រមោយនិងភ្លុកឃើញមានមាត់ ដំរីរាងវែងបន្តិចស្របប្រមោយ។ ខ្លួនដំរីធំ ហើយមានពោះប៉ោង។ បើមើលទៅលើស្បែករបស់ដំរីឃើញមានសភាពក្រាស់ជ្រួញតិចៗ ហើយយារធ្លាក់។ ជើងវាធំៗរឹងមាំដូចសសរ ផ្ទះ ហើយមានក្រចកនៅខាងចុងម្រាម។ ឯកន្ទុយរបស់វាវិញមូលរាងខ្លី និងមានរោមនៅខាងចុងកន្ទុយដូច អំបោស។ ពេលដើរ ឬឈរវាតែងតែបក់ស្លឹក ត្រចៀក ហើយគ្រវីប្រមោយចុះឡើងៗ ដើម្បីដេញសត្វល្អិត ឬរុយដែលមកទំ ឬរោមលើខ្លួនរបស់វា។ ដំរីស៊ី ស្លឹកឫស្សីព្រិចនិង រុក្ខជាតិផ្សេងៗ។ ដំរីជាសត្វធំមាន កម្លាំងខ្លាំង អាចជួយអូសទាញឈើធំៗ ជាមធ្យោបាយក្នុងការដឹកជញ្ជូនផ្សេងៗ និងជាទ័ពដំរីដ៏ក្លាហាន ។

ដំរីជាសត្វមានប្រយោជន៍ ជាសត្វកម្រ អាចរកកម្រៃជាលក្ខណៈគ្រួសារ និងប្រាក់ចំណូលសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិតាមរយៈវិស័យទេសចរណ៍។ ដូច្នេះ យើងត្រូវជួយថែរក្សានិងការពារសត្វដំរីកុំឱ្យបាត់បង់ ឬផុតពូជដំរី។

**៧.២.១០- ឧទាហរណ៍ទី១០** (ថ្នាក់ ទី៥ និងទី៦)

លំហាត់សម្រាប់សិស្សអនុវត្តដោយហ្វឹកហាត់ធ្វើសេចក្តីអធិប្បាយ តាមគម្រោងដូចខាងក្រោម។

**ប្រធាន** : ចូរប្អូនពណ៌នាអំពីសត្វក្របីដែលគ្រួសារប្អូនបានចិញ្ចឹម។

## សេចក្តីពណ៌នា

**ក- សេចក្តីផ្តើម**

- ក្របី ញី ឬឈ្មោល អាយុ ឈ្មោះ
- ពេលវេលានៃការចិញ្ចឹម : ចិញ្ចឹមតាំងពីតូចឬទើបនឹងចិញ្ចឹម។

**ខ- តួសេចក្តី**

- បង្ហាញលក្ខណ:: រូបរាង  ពណ៌សម្បុរ មាឌ រោម ស្នែង ជើង ក្បាល ធ្មេញ ដងខ្លួន កន្ទុយ
- ឥរិយាបថ: ឧស្សាហ៍ ខ្ជិល រហ័ស រហ្សួន ឬស្លូត ទម្រន់
- ផលប្រយោជន៍ : ជាកម្លាំងអូសទាញ ជាសត្វងាយចិញ្ចឹម ស៊ីស្មៅ អត់ចំណាយដើមទុន ច្រើនក្នុង ការចិញ្ចឹម ស្រួលថែទាំ។ ផ្តល់សាច់ជាអាហារ ផ្តល់លាមក ឬអាចម៍ជាជីសម្រាប់ដំណាំកសិកម្ម ស្បែកផ្តល់ ប្រយោជន៍ ដូចជា ខ្សែព្រ័ត្រ ជ័រការ ស្នែងជាគ្រឿងតាំងលម្អផ្សេងៗជាដើម។

**គ សេចក្តីបញ្ចប់**

- ការវាយតម្លៃ : សត្វក្របី ដែលមានប្រយោជន៍ចំពោះកសិករក្នុងការធ្វើស្រែ ចម្ការ
- ចំណាប់អារម្មណ៍ : ចំណូលចិត្តក្នុងការចិញ្ចឹមសត្វក្របីព្រោះវាជាសត្វមានប្រយោជន៍លើកស្ទួយ ជីវភាពគ្រួសារ។

## អត្រាគំរែរ

## អត្រាពិន្ទុតែងសេចក្តីពណ៌នាអំពីសត្វ

អត្រាពិន្ទុតែងសេចក្តី ពណ៌នាអំពីសត្វ មានអត្រាពិន្ទុ១០/១០។ លោកគ្រូអ្នកគ្រូ គួរណែនាំសិស្សឱ្យដឹងផងដែរអំពីការសរសេររបស់សិស្សដែលត្រូវទទួលពិន្ទុតាមផ្នែកនីមួយៗដូចជា សេចក្តីផ្តើម តួសេចក្តី និង សេចក្តីបញ្ចប់ ដើម្បីជាការលើកទឹកចិត្តសិស្ស និងជំរុញសិស្សឱ្យខិតខំយកចិត្តទុកដាក់សរសេរឱ្យបាន ផ្ចិតផ្ចង់ ល្អត្រឹមត្រូវតាមគម្រោងដែលបានណែនាំ។

ការដាក់ពិន្ទុ គឺជាចំណុចសំខាន់ដែលធ្វើឱ្យសិស្សសប្បាយរីករាយចង់សរសេរ និងចង់បានពិន្ទុច្រើន  អាស្រ័យ លើភាពទាក់ទាញ និងវិធីបង្រៀនរបស់គ្រូផងដែរ។ ខាងក្រោមនេះជាអត្រាដាក់ពិន្ទុតាមគម្រោង។

## គម្រោងតែង

**ក- សេចក្តីផ្តើម** (១,៥០ពិន្ទុ)

- បង្ហាញពីឈ្មោះសត្វដែលចិញ្ចឹម និងភេទ  (១,០០ពិន្ទុ)
- ពេលវេលានៃការចិញ្ចឹម។   (០,៥០ពិន្ទុ)

**ខ- តួសេចក្តី** (៦,០០ពិន្ទុ)

- លក្ខណៈ : រូបរាង មាឌ តូច ធំ ស្គម ធាត់ ខ្ពស់ ទាប ស ខ្មៅ មុខមាត់ ភ្នែក ច្រមុះ មាត់ត្រចៀក រោម ដៃ ជើង ក្រញ៉ាំ ក្រចកវែង ខ្លី វែងកោងខុប ស្រួច។ (២,០០ពិន្ទុ)
- ឥរិយាបថ : សកម្មភាពរហ័សរហួន ទ្រមក់ ។ (២,០០ពិន្ទុ)
- ផលប្រយោជន៍ : (២,០០ពិន្ទុ)

**គ- សេចក្តីបញ្ចប់** (១,៥០ពិន្ទុ)

- ការវាយតម្លៃ : ជាសត្វមានប្រយោជន៍... ១,០០ពិន្ទុ)
- ចំណាប់អារម្មណ៍ : ចំណូលចិត្តក្នុងការចិញ្ចឹមសត្វ (០,៥០ពិន្ទុ)

**រចនាបថ:** អក្សរស្អាត សរសេរមានរបៀប មានឃ្លាល្បះត្រឹមត្រូវ និងគ្មានកំហុសអក្ខរាវិរុទ្ធ (១,០០ពិន្ទុ)

## ៧.៣- ប្រធានពណ៌នាអំពីវត្ថុ

ការពណ៌នាអំពីវត្ថុ មានគោលបំណងចង់ឱ្យសិស្សចេះពិនិត្យ សង្កេតវត្ថុផ្សេងៗជុំវិញខ្លួន ផ្ទះ ភូមិក្នុងថ្នាក់រៀន សាលារៀន។ល។ ហើយចេះសរសេររៀបរាប់បង្ហាញនូវវត្ថុទាំងនោះ។ ការពណ៌នាអំពីវត្ថុមានពីរយ៉ាង។ ជួនកាលគេឱ្យយើងពណ៌នាអំពីវត្ថុតែមួយដាច់ដោយឡែកដូចជាពណ៌នាពីតុ តុគ្រូ ក្តារខៀន។ល។ ជួនកាលទៀត គេតម្រូវឱ្យយើងពណ៌នាពីសំណុំវត្ថុនៅទីកន្លែងណាមួយដូចជា វត្ថុនៅក្នុងថ្នាក់រៀន គេហដ្ឋាន ផ្ទះបាយ ...។

៧.៣.១- **ឧទាហរណ៍ទី១** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនរៀបរាប់ពីក្តារខៀនធ្វើអំពីឈើនៅក្នុងថ្នាក់រៀនរបស់ប្អូន។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- ប្រាប់ឈ្មោះវត្ថុ
- ទីកន្លែង។

**ខ- តួសេចក្តី**

- រៀបរាប់ទីតាំងនិងរូបរាងក្តារខៀន : ក្នុងថ្នាក់រៀន ចំហៀងថ្នាក់រៀន ពីមុខតុសិស្ស ពីក្រោយតុគ្រូ ឬពីក្រោយតុសិស្ស
- សារប្រយោជន៍នៃក្តារខៀននោះ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ : បង្ហាញពីតម្លៃនៃក្តារខៀនដែលបានរៀបរាប់
- ចំណាប់អារម្មណ៍ : ការសម្តែងពីមនោសញ្ចេតនាចំពោះក្តារខៀននោះ។

### សេចក្តីពណ៌នា

នៅក្នុងថ្នាក់រៀនខ្ញុំមានក្តារខៀនមួយធ្វើអំពីឈើ។ វាមានបណ្តោយពីរម៉ែត្រហាសិប និងទទឹងមួយ ម៉ែត្រ ហាសិបដាក់ព្យួរជាប់ជញ្ជាំងក្នុងថ្នាក់រៀន។

ក្តារខៀននេះដាក់ព្យួរនៅចំពីមុខតុសិស្ស។ នៅផ្ទៃខាងមុខក្តារខៀន ជាឈើរលោងរាបស្មើ លាបពណ៌ ខៀវចាស់ ងាយស្រួលក្នុងការសរសេរដីសនិងងាយលុបឆាប់ជ្រះ។ លោកឪពុកខ្ញុំបាន ប្រាប់ថាក្តារខៀននេះ មានតាំងពីជំនាន់លោករៀននៅបឋមសិក្សាមកម្ល៉េះ។ ឥឡូវ ក្តារខៀនដដែល នេះនៅតែឈរចាំសិស្សឱ្យកត់ ត្រាខ្លឹមសារគ្រប់មេរៀនដែលសិស្សត្រូវការសរសេរ គ្រប់ព័ត៌មាន ដែលសិស្សចាំបាច់ត្រូវដឹង។ ខ្ញុំនិងមិត្តរួម ថ្នាក់ទាំងអស់ចូលចិត្តសរសេរអក្សរនៅលើក្តារខៀននេះ ណាស់ ព្រោះវាសរសេរអក្សរបានច្បាស់ ប្រើយូរ ហើយនៅតែស្អាតដដែល។ រៀងរាល់ឆ្នាំ ក្តារខៀន នេះត្រូវបានលាបពណ៌ម្តង។ ក្តារខៀននេះផ្តល់ប្រយោជន៍ ឱ្យខ្ញុំនិងសិស្សទាំងអស់បានរៀនចេះ ដឹង និងសរសេរអក្សរបានស្អាតត្រឹមត្រូវ។

ក្តារខៀនជាវត្ថុមានតម្លៃបំផុតសម្រាប់អ្នកសិក្សាដែលមិនអាចខ្វះបាន។ ខ្ញុំស្រឡាញ់ក្តារខៀន នេះណាស់ ព្រោះខ្ញុំបានរៀនសូត្រចេះចាំដោយសារវា។ ខ្ញុំបានជួយថែរក្សាវាឱ្យ បានល្អដោយមិន យកវត្ថុរឹងគូសវាសឱ្យដាច់ ឬមានស្នាមអ្វីឡើយ។

**៧.៣.២- ឧទាហរណ៍ទី២** (ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនរៀបរាប់ពីវត្ថុដែលមាននៅក្នុងថ្នាក់រៀនរបស់ប្អូន។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ប្រាប់ឈ្មោះវត្ថុ
- ទីកន្លែង។

**ខ- តួសេចក្តី**

- រៀបរាប់ទីតាំងនិងវត្ថុក្នុងថ្នាក់រៀនៈ នៅពីមុខ ចំហៀង និងនៅពីក្រោយ មានដូចជា បាវចនា ជាតិ ព្រះឆាយាលក្ខណ៍ តារាងផ្សេងៗ ផ្ទាំងរូបភាព ពាក្យស្លោក សុភាសិត ស្នាដៃសិស្ស ជាដើម
- សារប្រយោជន៍នៃវត្ថុទាំងនោះ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃៈ បង្ហាញពីតម្លៃនៃវត្ថុទាំងនោះ
- ចំណាប់អារម្មណ៍ៈ ការសម្តែងពីមនោសញ្ចេតនាចំពោះវត្ថុទាំងនោះ។

## សេចក្តីពណ៌នា

ខ្ញុំរៀននៅថ្នាក់ទី៣«ក»នៃសាលាបឋមសិក្សា២ធ្នូស្ថិតនៅក្នុងភូមិកំពង់ក្របី សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។ ថ្នាក់រៀនខ្ញុំមានបរិយាកាសសិក្សាល្អបន្ទប់ធំទូលាយហើយមាន សម្ភារៈ សិក្សាជាច្រើនសមជាសាលា កុមារមេត្រី។

ពេលចូលដល់ថ្នាក់ដំបូងគេឃើញនៅលើតុគ្រូមានកម្រាលស្អាត សៀវភៅសិក្សាគោល បញ្ជី ពិន្ទុសិស្ស បញ្ជីហៅឈ្មោះសិស្ស សៀវភៅស្រង់វត្តមានសិស្ស សៀវភៅកត់ត្រាអត្ថបទបង្រៀន ព្រមទាំងថូផ្កាមួយមានផ្កាចម្រុះ ពណ៌យ៉ាងស្រស់ស្អាតដាក់នៅចំហៀងតុ។ នៅពីមុខតុគ្រូគឺមានតុ

សិស្សរៀបជាជួរៗ ហើយនៅលើតុសិស្សមានសម្ភារៈ សៀវភៅសរសេរ សៀវភៅសិក្សាគោល ប៊ិកខ្មៅដៃ ដីស ក្ដារឆ្នួន ជាដើម។ នៅលើជញ្ជាំងខាងក្រោយតុគ្រូមានព្យួរ តារាងជាច្រើនដូចជា តារាងវេនសម្អាត ថ្នាក់ តារាងពិន្ទុប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ តារាងកិត្តិយស តារាងកម្មវិធីសិក្សា បទបញ្ជាផ្ទៃក្នុង បញ្ជីសារពើភ័ណ្ឌ តារាង ព័ត៌មាននិងតារាងផ្សេងៗ។ នៅចំកណ្ដាលជញ្ជាំងពីមុខតុសិស្សមាន ក្ដារខៀនមួយយ៉ាងធំ ហើយនៅពីលើក្ដារខៀនមានដាក់តាំងព្រះឆាយាលក្ខណ៍ ព្រះមហាក្សត្រ និងបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ។ បើក្រឡេកមើល នៅលើជញ្ជាំងម្ខាងនៃក្ដារខៀន គេឃើញមានតារាងព័ត៌មានទាក់ទងនឹង គ្រោះថ្នាក់ ចរាចរណ៍ តារាងវាយតម្លៃទំនិញ តារាងឧត្តមនិយម ខ្សែម៉ែត្រសម្រាប់វាស់កម្ពស់សិស្ស តុតូចមួយ ដែលមាន ចានជ័រ ដាក់ទឹកលាងដៃ និងកន្សែងជូតដៃតូចមួយ។ នៅតាមបង្អួចទាំងសងខាង លម្អ ដោយវាំងននបង្អួចខ្លីៗ រំលេចដោយពណ៌ផ្កាឈូកយ៉ាងស្រស់ត្រកាល ព្រមទាំងថូរុក្ខជាតិបៃតង មើលទៅ យ៉ាងស្រស់ស្អាត ដែលធ្វើឱ្យថ្នាក់រៀនកាន់តែមានសម្រស់ និងផាសុកភាព។ នៅតាមជញ្ជាំងសងខាង ថ្នាក់រៀនមានព្យួរ ផ្ទាំងទេសភាព ផ្ទាំងគំនូរស្នាដៃសិស្ស ពាក្យស្លោក សុភាសិតទាក់ទងនឹងការអប់រំដូចជា ចេះមកពីរៀន តក់ៗ ពេញបំពង់ អានច្រើនចម្រើនចំណេះ កូនល្អស្ដាប់ម៉ែសិស្សពូកែស្ដាប់គ្រូជាដើម។ លើសពីនេះទៀត នៅលើជញ្ជាំងខាងក្រោយតុ សិស្សគេឃើញមានតុដាក់តាំងស្នាដៃហត្ថកម្មសិស្ស ដូចជា កាំបិត ពូថៅ កញ្ច្រែង កន្ត្រងប្រហុក បង្គី រនាស់ ជាច្រើនដែលរៀបចំឡើងយ៉ាងល្អប្រណិត។ នៅចំពីលើតុតាំង ស្នាដៃ ហត្ថកម្ម ស្នាដៃសិស្ស គេក៏ឃើញមានផ្ទាំងទេសភាពប្រាសាទអង្គរវត្តមួយផ្ទាំងយ៉ាងធំ។ នៅជ្រុងខាងក្រោយនៃតុសិស្សផ្នែកខាងឆ្វេង ជាជ្រុងបណ្ណាល័យដែលមានទូដាក់សម្ភារៈនិងសៀវភៅសិក្សា ព្រមទាំងសៀវភៅអំណានផ្សេងៗជាច្រើន អមជាមួយនឹងភូគោល រូបផែនទីពិភពលោក និងសម្ភារឧបទេសដទៃទៀតសម្រាប់គ្រូប្រើប្រាស់ជាជំនួយក្នុងការបង្រៀន។

វត្ថុនិងសម្ភារៈដែលមាននៅក្នុងថ្នាក់រៀនទាំងអស់មានសារៈសំខាន់ណាស់សម្រាប់ការដាក់តាំង លម្អផង និងសម្រាប់ជាសម្ភារៈសិក្សាដ៏សំខាន់មិនអាចខ្វះបានផង។ វត្ថុទាំងនេះជាគ្រឿងតាំងលម្អផងនិងមានប្រយោជន៍សម្រាប់សិក្សាផង។ ខ្ញុំស្រឡាញ់ថ្នាក់រៀនខ្ញុំណាស់ ព្រោះវាមានសម្ភារៈសិក្សាគ្រប់ប្រភេទ បរិយាកាសសិក្សាល្អ ហើយធ្វើឱ្យខ្ញុំនិងមិត្តភក្តិទាំងអស់ចង់មករៀននៅទីនេះជារៀងរាល់ថ្ងៃ។

**៧.៣.៣- ឧទាហរណ៍ទី៣** (ថ្នាក់ ទី៥ និងទី៦)

**ប្រធាន** : ចូរប្អូនពណ៌នាអំពីបន្ទប់គេងរបស់ប្អូន។

## គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- ទីតាំងបន្ទប់គេង។

**ខ- តួសេចក្ដី**

- លក្ខណៈបន្ទប់: ទំហំ ទ្វារ បង្អួច ជញ្ជាំង រូបភាព...
- របស់ប្រើប្រាស់ដែលមាននៅក្នុងបន្ទប់: គ្រែ កន្ទេល ពូក កម្រាល ខ្នើយ ភួយ ទូដាក់ខោអាវ កៅអីសម្រាប់អង្គុយ សៀវភៅផ្សេងៗនៅលើតុ
- ការថែទាំ ការបោសសម្អាត រៀបចំ ...។

**គ- សេចក្ដីបញ្ចប់**

- ការវាយតម្លៃ: បន្ទប់គេង
- ចំណាប់អារម្មណ៍: សម្ដែងមនោសញ្ចេតនាចំពោះបន្ទប់គេង។

## សេចក្ដីពណ៌នា

ខ្ញុំមានបន្ទប់គេងផ្ទាល់ខ្លួនមួយ។ រៀងរាល់ថ្ងៃមុនពេលមកសាលារៀន ខ្ញុំតែងតែរៀបចំបន្ទប់គេងនោះឱ្យមានសណ្ដាប់ធ្នាប់ជានិច្ច។

បន្ទប់គេងរបស់ខ្ញុំមានទំហំប្រហែលបីម៉ែត្របួនជ្រុង ដែលមានការតុបតែងលម្អ លាបពណ៌ជញ្ជាំង បង្អួច និងទ្វារយ៉ាងស្រស់ប្រណិត។ នៅក្នុងបន្ទប់មានគ្រែពូកមួយនិងកម្រាលពណ៌ផ្កាឈូកលាយរូបសត្វដែលជាឆ្នាំកំណើតរបស់ខ្ញុំថែមទៀតផង។ លើសពីនេះទៀតមានភួយ ខ្នើយកើយ ខ្នើយគង និងខ្នើយឱប ខ្ញុំរៀបបត់ទុកដាក់ត្រូវតាមទីកន្លែង។ នៅតាមបង្អួចមានលម្អដោយវាំងននប៉ាក់រំលេចរូបភាពដែលជាស្នាដៃរបស់ម៉ាក់ខ្ញុំ។ រាល់ពេលខ្យល់បក់ម្ដងៗ រូបលើវាំងននមានចលនារស់រវើកគួរចង់គយគន់។ នៅជាប់ជញ្ជាំង បន្ទប់មានទូកញ្ចក់មួយសម្រាប់ដាក់សម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ខ្ញុំ។ នៅអែបមាត់បង្អួចមានតុមួយសម្រាប់សិក្សានៅផ្ទះ។ តុនោះលម្អដោយថូមានផ្កាចម្រុះពណ៌ ហើយស្រស់ស្អាត និងខ្មៅដៃ ប៊ិករៀបដាក់តាមផ្នែកៗ។ នៅជិតតុក៏មានធ្នើរសៀវភៅមួយដែរ។ ខ្ញុំបោសសម្អាតបន្ទប់គេងជាប្រចាំ ដើម្បីឱ្យមានអនាម័យ មានសោភណភាព និងមានផាសុកភាពសម្រាប់ខ្លួនខ្ញុំផ្ទាល់ផង និងសមាជិកគ្រួសារខ្ញុំផង។

បន្ទប់គេងខ្ញុំតូចល្មមទេ ប៉ុន្តែខ្ញុំរៀបចំយ៉ាងមានរបៀបគួរឱ្យចង់រស់នៅ។ ខ្ញុំស្រឡាញ់បន្ទប់គេងនេះណាស់ ព្រោះជាបន្ទប់មានអនាម័យនិងមានខ្យល់អាកាសបរិសុទ្ធងាយ ស្រួលក្នុងការរស់នៅ។ ខ្ញុំតែងតែថែរក្សានិងបោសសម្អាតវាជារៀងរាល់ថ្ងៃ។

**៧.៣.៤- ឧទាហរណ៍ទី៤** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនរៀបរាប់ពីត្បាល់បុកគ្រឿងនិងអង្រែនៅក្នុងផ្ទះបាយរបស់ប្អូន។

## គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- ប្រាប់ឈ្មោះវត្ថុ (ឈ្មោះ? ធ្វើអំពីអ្វី?)
- ទីកន្លែង(នៅកន្លែងណា?)

**ខ- តួសេចក្ដី**

- លក្ខណៈរូបរាងត្បាល់: ទំហំធំ ឬតូចល្មម រូបរាង ពណ៌
- លក្ខណៈរូបរាងអង្រែ: រាង តូចឬធំ វែងឬខ្លី ប្រវែងប៉ុន្មាន
- ផលប្រយោជន៍: សម្រាប់បុក អំបិល ម្ទេស ម្រេច គល់ស្លឹកគ្រៃជាដើម។

**គ- សេចក្ដីបញ្ចប់**

- ការវាយតម្លៃ: ត្បាល់បុកគឿងនិងអង្រែ
- ចំណាប់អារម្មណ៍: បង្ហាញពីមនោសញ្ចេតនា។

## សេចក្តីពណ៌នា

នៅផ្ទះខ្ញុំមានត្បាល់បុកគ្រឿងមួយធ្វើអំពីឈើធ្នង់ក្រឡឹងមានក្បាច់រចនាលម្អបែបខ្មែរ។

ត្បាល់បុកគ្រឿងនេះ មានតួត្បាល់និងអង្រៃសម្រាប់បុក។ តួត្បាល់មានរាងរីកមាត់និងជើង ហើយចង្កេះវា រៀវតូច។ ត្បាល់បុកគ្រឿងនោះមានសម្បុរក្រហមរលោង។ កម្ពស់ត្បាល់ប្រហែលបីតឹក ទទឹងមាត់ ប្រហែលមួយតឹក កន្លះ និងអមជាមួយអង្រៃរាងតូចមូលទ្រវែងមានប្រវែងបួនតឹក។ នៅខាងក្រៅត្បាល់ផ្នែកខាងមាត់លើមានឆ្លាក់ក្បាច់ត្របកផ្កាឈូក ផ្នែកខាងក្រោមគឺជើងត្បាល់មានឆ្លាក់ក្បាច់ពងត្រី។ កណ្តាលត្បាល់គេចោះយកសាច់ឈើចេញអស់ វាមានរាងមូលទ្រវែងសម្រាប់ដាក់គ្រឿងសម្ភារៈដែលត្រូវបុកលម្អិត។ ឯអង្រៃគេក្រឡឹងឱ្យមូលរលោងងាយចាប់កាន់ក្នុងពេលប្រើប្រាស់។ ត្បាល់ និងអង្រៃបុកគ្រឿង ទុកនៅផ្ទះ បាយសម្រាប់បុកគ្រឿងសម្លស្លក្នុងផ្ទះ មានបុកអំបិល ម្ទេស ម្រេច ខ្ទឹមមើម ស្លឹកម្ទូរផ្សេងៗ រំដេង ខ្ចាយ រមៀត គល់ស្លឹកគ្រៃ។ ត្បាល់នេះងាយប្រើប្រាស់ងាយបុកគ្រឿងបាន ឆាប់ល្អិតម៉ដ្ឋព្រោះវាធ្ងន់ និងមិនស្រូវ ពុំរំខាននោះទេ។ គ្រួសារខ្ញុំចូលចិត្តប្រើត្បាល់បុកគ្រឿងធ្វើពីឈើនេះណាស់ព្រោះ ធ្វើឱ្យគ្រឿងដែលបុកដោយដៃមានក្លិនឈ្ងុយឈ្ងប់បង្កើនរសជាតិម្ហូបអាហារ និងធ្វើឱ្យអ្នកទទួលទានឆ្ងាញ់។

ត្បាល់និងអង្រៃ គឺជាសម្ភារៈផ្ទះបាយរបស់ខ្មែរចាំបាច់សម្រាប់បុកគ្រឿងធ្វើម្ហូប។ ខ្ញុំពេញចិត្តត្បាល់និងអង្រៃនេះណាស់ ព្រោះវាជាឧបករណ៍ឬសម្ភារៈផ្ទះបាយចាំបាច់ ដែលជួយសម្រួលដល់ការផ្សំគ្រឿង និងការធ្វើម្ហូបខ្មែរបានច្រើនយ៉ាង។

**៧.៣.៥- ឧទាហរណ៍ទី៥** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនរៀបរាប់ពីសម្ភារៈប្រើប្រាស់នៅក្នុងផ្ទះបាយរបស់ប្អូន។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ប្រាប់ឈ្មោះវត្ថុ
- ទីកន្លែង។

**ខ- តួសេចក្តី**

- រៀបរាប់សម្ភារៈ ឬវត្ថុសម្រាប់ប្រើប្រាស់និងគ្រឿងចម្អិនម្ហូបអាហារនៅក្នុងផ្ទះបាយដូចជា ចង្ក្រានធ្វើពីដីឥដ្ឋដុត ចង្ក្រានហ្គាស ឆ្នាំងអគ្គិសនី ទូដាក់ម្ហូប ទូដាក់ចាន ស្លាបព្រា សម ចង្កឹះ វែក កែវ ក្រឡអំបិល ស្ករ ផ្អក ប្រហុក ទឹកត្រី ទឹកស៊ីអ៊ីវ ប្រេងឆា ឆ្នាំខ្ទះ ជ្រុញ កាំបិតតូចធំ ត្បាល់បុកគ្រឿង
- ប្រយោជន៍នៃវត្ថុទាំងនោះ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: សម្ភារៈផ្ទះបាយ
- ចំណាប់អារម្មណ៍: សម្តែងមនោសញ្ចេតនាចំពោះវត្ថុទាំងនោះ។

## សេចក្តីពណ៌នា

នៅក្នុងគេហដ្ឋានរបស់ខ្ញុំ មានផ្ទះបាយមួយសម្រាប់ចម្អិនអាហារដែលស្ថិតនៅខាងក្រោយផ្ទះធំ។

នៅក្នុងផ្ទះបាយនោះមានសម្ភារៈប្រើប្រាស់និងគ្រឿងផ្សំសម្រាប់ធ្វើម្ហូបអាហារប្រចាំគ្រួសារ។ នៅពីមុខឃើញមានជើងក្រានបីប្រភេទគឺ ចង្ក្រានហ្គាសសម្រាប់ចម្អិនសម្ល ឆ្នាំងអគ្គិសនីសម្រាប់ដាំបាយ និងចង្ក្រានដុតធ្យូងសម្រាប់អាំងត្រី សាច់។ ខាងស្តាំដៃមានទូធំទូលាយមួយចែកជាបីថ្នាក់ នៅថ្នាក់ខាងក្រោមដាក់ឆ្នាំងបាយ ឆ្នាំងសម្ល កំសៀវដាំទឹក ឆ្នាំងខ្ទះ កញ្ជ្រែង និងចានដែកតូចធំ។ ថ្នាក់កណ្តាលដាក់ចានបាយ សម្ល ស្លាបព្រា សម ចង្កឹះ វែកបាយ វែកសម្ល វែកឆា និងកែវ។ នៅថ្នាក់លើដាក់ក្រឡអំបិល ស្ករ ម្រេច ប្រហុក ផ្អក ដបទឹកត្រី ទឹកស៊ីអ៊ីវ ប្រេងឆា។ នៅជិតទូមានធុងសម្រាប់ដាក់អង្ករមួយ។ ឯខាងឆ្វេងដៃជាកន្លែងលាងចាន ឆ្នាំង បន្លែ ត្រីសាច់ និងមានដាក់ដបសាប៊ូកន្សែងសម្រាប់ជូតសម្អាត ព្រមទាំងសម្ភារៈផ្សេងៗមួយចំនួនទៀតដូចជាជ្រុញ កាំបិតតូចធំ និងត្បាល់បុកគ្រឿង។ សម្ភារៈក្នុងផ្ទះបាយទាំងអស់នេះទុកសម្រាប់ប្រើប្រាស់ក្នុងការចម្អិនអាហារក្នុងគ្រួសារជាប្រចាំ។ ផ្ទះខ្ញុំមិនអាចអត់ សម្ភារៈទាំងនោះបានឡើយ ព្រោះវាជាអ្នកទ្រទ្រង់សុខភាពនិងផ្តល់ថាមពលដល់សមាជិកទាំងអស់គ្នាក្នុងគ្រួសារ។

សម្ភារៈផ្ទះបាយទាំងអស់នេះជាវត្ថុប្រើប្រាស់ក្នុងផ្ទះបាយរបស់គ្រួសារខ្មែរទូទៅ ដែលមិនអាចខ្វះបាន។ ខ្ញុំស្រឡាញ់និងឧស្សាហ៍លាងជូតសម្អាតសម្ភារៈផ្ទះបាយឱ្យមានអនាម័យរៀងរាល់ពេលប្រើប្រាស់រួច។ ដូច្នេះខ្ញុំស្រឡាញ់ពេញចិត្តនឹងសម្ភារៈទាំងនេះណាស់ ព្រោះខ្ញុំមានម្ហូបអាហារបរិភោគដោយសារវា។

## អត្រាកំណែ

### អត្រាពិន្ទុតែងសេចក្តីពណ៌នាអំពីវត្ថុ

អត្រាពិន្ទុតែងសេចក្តី ពណ៌នាអំពីវត្ថុមានអត្រាពិន្ទុ១០/១០។ លោកគ្រូអ្នកគ្រូ គួរណែនាំសិស្សឱ្យដឹងផងដែរអំពីការសរសេររបស់សិស្សដែលត្រូវទទួលពិន្ទុតាមផ្នែកនីមួយៗដូចជាសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ ដើម្បីជាការលើកទឹកចិត្តសិស្សនិងជំរុញសិស្សឱ្យខិតខំយកចិត្តទុកដាក់សរសេរឱ្យបានផ្ចិតផ្ចង់ ល្អត្រឹមត្រូវតាមគម្រោងដែលបានណែនាំ។

ការដាក់ពិន្ទុ គឺជាចំណុចសំខាន់ដែលធ្វើឱ្យសិស្សសប្បាយរីករាយចង់សរសេរនិងចង់បានពិន្ទុច្រើន អាស្រ័យលើភាពទាក់ទាញនិងវិធីបង្រៀនរបស់គ្រូផងដែរ។ ខាងក្រោមនេះជាអត្រាដាក់ពិន្ទុតាមផ្នែកនីមួយៗ។

## គម្រោងតែង

**ក- សេចក្តីផ្តើម** (១,៥០ពិន្ទុ)

- ប្រាប់ឈ្មោះវត្ថុ (១,០០ពិន្ទុ)
- ទីកន្លែង (០,៥០ពិន្ទុ)

**ខ- តួសេចក្តី** (៦,០០ពិន្ទុ)

- រៀបរាប់វត្ថុនៅជុំវិញខ្លួនៈ មុខថ្នាក់រៀន ចំហៀងថ្នាក់រៀន ពីក្រោយថ្នាក់រៀន ពីក្រោយតុគ្រូ ពីក្រោយតុសិស្ស...ដែលព្យួរនៅតាមជញ្ជាំងមានដូចជាតារាងផ្សេងៗ រូបភាព ទេសភាព ស្នាដៃសិស្ស (៥,០០ពិន្ទុ)
- ផលប្រយោជន៍ៈ សម្រាប់ប្រើប្រាស់រៀននិងបង្រៀនឬលម្អ (១,០០ពិន្ទុ)

**៣- សេចក្តីបញ្ចប់** (១,៥០ពិន្ទុ)

- ការវាយតម្លៃៈ មានភាពចាំបាច់ក្នុងការប្រើប្រាស់មិនអាចខ្វះបាន (១,០០ពិន្ទុ)
- សម្តែងមនោសញ្ចេតនាដោយស្រឡាញ់ ថែរក្សាការពារ (០,៥០ពិន្ទុ)

**រចនាបថៈ** អក្សរស្អាត សរសេរមានរបៀប មានឃ្លាល្បះត្រឹមត្រូវ និងគ្មានកំហុសអក្ខរាវិរុទ្ធ (១,០០ពិន្ទុ)

## ៧.៤- ប្រធានពណ៌នាអំពីរុក្ខជាតិនិងផ្លែឈើ

ការពណ៌នាអំពីរុក្ខជាតិនិងផ្លែឈើ អ្នកសរសេរត្រូវយកចិត្តទុកដាក់សង្កេតមើលៈ

- ជាដំបូងអំពីទិដ្ឋភាពរួមដែលមើលឃើញពីចម្ងាយ (ដោយប្រៀបប្រដូចទៅនឹងអ្វីមួយ បើប្រៀបបាន)។ បន្ទាប់មកគឺពិនិត្យឱ្យបានជិតរុក្ខជាតិនោះដោយបង្ហាញពីចំណែកសំខាន់ៗដូចជាស្លឹក ធាង តួ ដើម គល់ដោយបញ្ជាក់អំពីរូបរាងពណ៌សម្បុរ ខ្នាត...។ បញ្ជាក់ពីលក្ខណៈសំខាន់ចាំបាច់ៈ ក្រាស់ ស្តើង ធំ តូច ទាបខ្ពស់ មានបន្លាឬគ្មានតំហែទាំ ផលប្រយោជន៍។
- ទីបំផុតបង្ហាញអំពីចំណង់ចំណូលចិត្តរបស់អ្នកចំពោះរុក្ខជាតិនោះ។

**៧.៤.១- ឧទាហរណ៍ទី១** (ថ្នាក់ទី៥ និងទី៦)

---

**ប្រធាន**: ចូរប្អូនពណ៌នាអំពីដើមចេកណាំវ៉ាដែលដាំនៅក្នុងចម្ការនិងផលប្រយោជន៍របស់វា។

---

### គម្រោងតែង

**ក- សេចក្តីផ្តើម**

បង្ហាញរុក្ខជាតិនោះដោយប្រាប់ពី : ឈ្មោះ ទីកន្លែងដែលគេអាចដាំបាន ...។

**ខ- តួសេចក្តី**

- លក្ខណៈ: ដើម រាងវៅ ទំហំ កម្ពស់ រុក្ខជាតិ ស្លឹក ធាង ពណ៌ ដំណាំយកផ្លែ ដើម និងស្លឹក
- ផលប្រយោជន៍៖
  - ✓ ផ្លែៈ ខ្ចីធ្វើជាអន្លក់ ជាបន្លែ ទុំធ្វើជាបង្អែមជាដំណាប់។
  - ✓ ដើមៈ កូតធ្វើចំណង ចំណីសត្វ សម្រាប់ស្ល ដើមនិងស្លឹកសម្រាប់ប្រើក្នុងពិធីសែនព្រេន
  - ✓ ស្លឹកៈ សម្រាប់វេចនំអន្សម នំគម នំស្លឹកបត់ ខ្ចប់បាយ ម្ហូប ត្រីអាំងឬដុត ស្លឹកងាប់ផ្តល់ជាឱសថសម្រាប់កែរោគ
  - ✓ ត្រយូងៈ ធ្វើជាអន្លក់ ជាបន្លែ
  - ✓ ធាង ស្រទបៈ ធ្វើជាចំណងនិងខ្សែចងផ្សេងៗ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃៈ ជាដំណាំឆាប់ផលនិងរកប្រាក់ចំណូលបានច្រើន

- ចំណាប់អារម្មណ៍: ការស្រឡាញ់ ចូលចិត្ត និងចូលរួមដាំដុះ។

## សេចក្ដីពណ៌នា

គ្រួសារខ្ញុំមានចម្ការចេកមួយស្ថិតនៅក្រោយផ្ទះ។ ចម្ការនោះដាំពូជចេកណាំវ៉ាបានមួយឆ្នាំមកហើយ ។

ចេកណាំវ៉ាជារុក្ខជាតិដែលអាចដាំបានស្ទើរគ្រប់ទីកន្លែង។ ដើមចេកជារុក្ខជាតិគ្មានខ្លឹម។ បើយើងមើលពីចម្ងាយ ឃើញដើមចេកណាំវ៉ាមានរាងមូលស្រឡូនដូចសសរ មានពណ៌បៃតងលាយស។ បើយើងចូលជិតនិងបានកាន់ស្ទាបដើមចេក អារម្មណ៍យើងដឹងថាត្រជាក់ស្រេបតែម្តង។ កាលណាយើងកាត់ដើមចេកជាទទឹងនោះ យើងនឹងឃើញមានទឹក មានសំបក ដែលស្នបលើគ្នាជាស្រទាប់ៗ ដែលស្នបឱបពីក្រៅហៅថាស្រទបចេក។ ដើមចេកណាំវ៉ានៅក្នុងចម្ការរបស់ខ្ញុំមានកម្ពស់ពីមួយម៉ែត្រទៅបីម៉ែត្រងណោះ។ វាមានស្លឹកជាប់នឹងធាងហើយមានពណ៌បៃតង។ ស្លឹកចេកមានសណ្ឋានជាបន្ទះវែងដូចផ្លិតពណ៌បៃតង។ ផ្លែរបស់វាពេលនៅខ្ចីមានពណ៌ខៀវនិងមានរសជាតិចត់។ នៅពេលទុំផ្លែចេក មានពណ៌លឿងហើយមាន រសជាតិផ្អែម។ ដើមចេកមានប្រយោជន៍ច្រើនយ៉ាងដូចជាផ្តល់ជាម្លប់សម្រាប់មនុស្សជាជម្រកសត្វស្លាបផ្សេងៗជាចំណីសត្វជ្រូក គោ សេះ និងសត្វដទៃទៀតផងដែរ។ ដើមឬស្រទប និងធាងចេកអាចបកយកទៅក្តួត ច្រៀកធ្វើជាខ្សែចំណងសម្រាប់ចងសំណាប នំអន្សមឬសម្ភារ:ផ្សេងៗ។ បណ្តូលដើមចេកខ្ចីនិងត្រយូងចេក គេយកទៅធ្វើជាបន្លែសម្ល ម្ជូរនិងបន្លែម្ហូបញាំ ភ្លា។ ផ្លែចេកខ្ចីអាចយកធ្វើជាអន្លក់ បន្លែសម្ល កកូរ និងធ្វើជាឱសថព្យាបាលក្រពះ។ល។ ផ្លែចេកទុំ អាចបរិភោគឆៅ ស្ងោរ ធ្វើជាបង្អែម ដំណាប់ចេក ស្ករ ចេក និងប្រើជារណ្តាប់ក្នុងពិធីបុណ្យផ្សេងៗផងដែរ។ ស្លឹកចេកស្រស់គេអាចយកទៅវេចនំអន្សម នំគម ខ្ចប់បាយ ម្ហូប ខ្ចប់ត្រីដុតឬអាំងបានទៀតផង។ មួយវិញទៀតធាងចេកអាចច្នៃជារូបសេះ ឱ្យក្មេងៗជិះលេង ជាល្បែងបានដែរ។ គ្រួសារខ្ញុំចូលចិត្តដាំចេកណាំវ៉ាក្នុងដីចម្ការដើម្បីបរិភោគនិងលក់។ ដំណាំចេកមានអត្ថប្រយោជន៍ច្រើនណាស់សម្រាប់មនុស្ស សត្វ។ ចេកជាដំណាំងាយស្រួលដាំឆាប់ទទួលផល។ លក្ខណៈពិសេសរបស់វានៅពេលទុំគឺពុំមានសត្វដង្កូវ ស៊ីដូចផ្លែឈើដទៃទៀតឡើយ។

ចេកណាំវ៉ាជាប្រភេទចេកម្យ៉ាងងាយដាំដូចចេកដទៃទៀតដែរ។ ខ្ញុំចូលចិត្តដាំចេកនិងញ៉ាំវាណាស់ពីព្រោះវាមានរសជាតិផ្អែមឆ្ងាញ់។ យើងទាំងអស់គ្នាត្រូវនាំគ្នាដាំចេកឱ្យបាន ច្រើនដើម្បីបានបរិភោគនិងលក់បានប្រាក់សម្រាប់ ផ្គត់ផ្គង់ជីវភាពគ្រួសារឱ្យបានសម្បូររុងរឿង។

**៧.៤.២- ឧទាហរណ៍ទី២** (ថ្នាក់ ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីដើមត្នោតនិងអត្ថប្រយោជន៍របស់វាឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ប្រាប់ពេលវេលា
- ប្រាប់ពីកន្លែងនៃដើមត្នោតនោះ។

**ខ- តួសេចក្តី**

- បង្ហាញទិដ្ឋភាពពីចម្ងាយ

- ទិដ្ឋភាពទូទៅៈ រូបរាង កម្ពស់ ពណ៌ ...
- ផ្នែកផ្សេងៗៈ ឫស គល់ ដើម ស្លឹក ផ្លែ ... ។

**ផលប្រយោជន៍៖**

- ម្លប់ជាជម្រកសម្រាប់មនុស្ស សត្វ
- ដើម ស្លឹក សម្រាប់ធ្វើផ្ទះ
- ឫស ផ្កាធ្វើជាឱសថ
- ផ្លែជាបង្អែម ជាចំណីសត្វ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃៈ ដើមត្នោតជានិមិត្តរូបនៃជាតិខ្មែរក្នុងចំណោមរុក្ខជាតិដទៃទៀតដែរ។
- ចំណាប់អារម្មណ៍ៈ សម្តែងពីមនោសញ្ចេតនារបស់អ្នកចំពោះដើមត្នោត។មិនកាប់បំផ្លាញ ចូលរួមថែរក្សានិងដាំបន្ថែម។

## សេចក្តីពណ៌នា

នៅជិតផ្ទះខ្ញុំមានដើមត្នោតមួយដើម។ ដើមត្នោតនេះមានអាយុប្រហែលជាងដប់ឆ្នាំហើយ។

ដើមរបស់វាមានរាងមូលវែង គល់រីកធំ ហើយដុះត្រង់ទៅលើសម្បុរក្រមៅ សម្បកវារឹង គគ្រាត។ ដើមត្នោតគ្មានមែកទេ មានតែធាងដែលមានស្លឹកនៅខាងចុងជាកញ្ចុំ។ ធាងត្នោតនីមួយៗ មានពណ៌បៃតង មានផ្នែកខាងក្រោមមូលរលីងហៅថាខ្នងត្នោត។ នៅចំហៀងមានបន្លាដូចធ្មេញ រណារ។ នៅខាងលើធាងមានរាងផតហៅថាពោះត្នោត។ នៅចុងធាងមានតួស្លឹកមួយធំរាងដូចឆត្រ កើតឡើងពីបន្ទះស្លឹកតូចៗជាប់គ្នា។ នៅគល់ធាងបែកជាបន្ទះពីររឹងមាំភ្ជាប់ទៅនឹងដើមហៅថាគាវ ត្នោត។ ដើមត្នោត មានឫសដុះប្រទាក់គ្នាចុះទៅក្នុងដីសម្រាប់ស្រូបជញ្ជក់ទឹកជាអាហារនិងទប់ដើម ឱ្យឈររឹងមាំ។ ដើមត្នោតមានផ្លែរាងមូលប៉ុនចានចង្កឹះ។ ផ្លែត្នោតខ្ចីមានពណ៌ក្រមៅហើយផ្លែត្នោត ទុំមានពណ៌លឿងក្រមៅ។ ដើមត្នោតមានពីរភេទគឺ ត្នោតញីនិងត្នោតឈ្មោល។ គេអាចស្គាល់ត្នោត ញីឬត្នោតឈ្មោលបានតាមរយៈផ្ការបស់វា។ យើងស្គាល់ត្នោតញីដោយសារវាមានផ្កាពកតូចៗខ្លី ពេលវារីកធំបង្កើតបានជាផ្លែ។ ឯដើមត្នោតឈ្មោលសម្គាល់ដោយសារផ្កាមូលវែងព័ទ្ធដោយលម្អង លឿងៗនៅពាសពេញនិងមិនមានផ្លែនោះទេ។ម៉្យាងទៀតដើមត្នោតមិនទាន់មានផ្កាគេអាចសម្គាល់ ថាញីឬឈ្មោលដោយសារស្លឹកនិងធាង។ ត្នោតញីមានធាងធំ ស្លឹកធំ ហើយខ្លី ឯត្នោតឈ្មោលមាន ធាង និងស្លឹកតូចវែង។ លើសពីនេះទៅទៀតដើមត្នោតមានច្រើនប្រភេទដូចជា ត្នោត អាចម៍សេះ មានផ្លែតូចៗ ត្នោតភ្លុកមានផ្លែធំៗដែលមាននៅតាមតំបន់ខុសៗគ្នា។ ត្នោតមានប្រយោជន៍ ច្រើន ណាស់សម្រាប់បម្រើតម្រូវការផ្សេងៗរបស់មនុស្ស ពិសេសប្រជាកសិករ។ ត្នោតផ្តល់ទឹកសម្រាប់ ហូបជាភេសជ្ជៈ ធ្វើជាបង្អែម ស្ករ ទឹកខ្មេះ ស្រាជាដើម។ ស្លឹកសម្រាប់ប្រក់ផ្ទះ ធ្វើជញ្ជាំងផ្ទះ កន្ទេល សំពៀត ផ្លិត មួក ស្មុក ក្បាប សម្រាប់ដេរស្លឹកប្រក់ផ្ទះនិង កន្ត្រំ។ ផ្នែកខាងក្នុងនៃកំពូលត្នោតដែលគេ ហៅថាគមត្នោតអាចយកទៅស្លបាន។ ផ្លែខ្ចីសម្រាប់ស្ល គ្រាប់ត្នោតខ្ចីហូប និងធ្វើបង្អែម។ ផ្លែត្នោតទុំ សម្រាប់ធ្វើនំចាហួយ។ រីឯគ្រាប់ទុំដុះបានជាកំពីងនិងកូនត្នោតតូចៗអាចហូបបាន។ ដើមត្នោតគេ អាចផលិតបានជាម្សៅត្នោតសម្រាប់ធ្វើនំម្សៅផ្សេងៗ។ ជាពិសេសដើមត្នោតអាចធ្វើជាទូក ក្តារ សសរ រនូត ឧស និងស្ពាន។ គាវត្នោតសម្រាប់ធ្វើជាអំបោស ខ្សែ ជក់ត្នោត ឧស និងក្បៀ។ ធាងត្នោត សម្រាប់ធ្វើជាខ្សែអំបោសជក់ត្នោត។ គេអាចយកត្នោតទៅប្រើប្រាស់ចាប់ពីវាមានអាយុម្ភៃឆ្នាំឡើង

ទៅ។ ត្នោតជារុក្ខជាតិនិមិត្តរូបនៃប្រទេសកម្ពុជា។ បើត្នោតត្រូវកាប់បំផ្លាញអស់ច្បាស់ជាមានផលវិបាកដល់ប្រជាកសិករក្នុងកំណៃប្រែជីវភាព ក៏ដូចជាសំណង់លំនៅដ្ឋានផ្សេងៗដែរ។

ដើមត្នោតក៏ជានិមិត្តរូបនៃជាតិខ្មែរក្នុងចំណោមរុក្ខជាតិដទៃទៀតដែរ។ ខ្ញុំចាប់អារម្មណ៍នឹងដើមត្នោតណាស់ព្រោះវាផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងដល់យើងគ្រប់គ្នាទាំងការហូបចុក និងប្រើប្រាស់គ្រប់បែបយ៉ាង។ យើងត្រូវនាំគ្នាដាំដើមត្នោតឱ្យបានច្រើនបន្ថែមទៀតដើម្បីបន្តរក្សា មរតកដ៏ល្អរបស់ដូនតាយើងឱ្យបានគង់វង្សជារៀងរហូត។

**៧.៤.៣- ឧទាហរណ៍ទី៣** (ថ្នាក់ទី៣ និងទី៤)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីផ្លែស្វាយទុំមួយនិងផលប្រយោជន៍របស់វាឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ប្រាប់ឈ្មោះផ្លែឈើ។

**ខ- តួសេចក្តី**

- លក្ខណៈផ្លែ: រាងវៅ មូល ឬទ្រវែង ទំហំតូច ធំ ពណ៌ ក្លិន និងរសជាតិ
- ផលប្រយោជន៍: ជាម្ហូប បង្អែម តំណាប់។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ផ្លែស្វាយទុំមានប្រយោជន៍ដល់សុខភាព
- ចំណាប់អារម្មណ៍: សម្តែងការចូលចិត្តនិងចូលរួមដាំបន្ថែម ។

## សេចក្តីពណ៌នា

កាលពីព្រឹកថ្ងៃអាទិត្យមួយ ម្តាយខ្ញុំបានទៅចម្ការស្វាយនៅខាងក្រោយផ្ទះ។ លុះពេលត្រឡប់មកវិញ គាត់បានបេះផ្លែស្វាយទុំមួយផ្លែផ្ញើឱ្យខ្ញុំ។

ផ្លែស្វាយទុំនោះជាពូជស្វាយខ្ទិះរកាកោងឬស្វាយកែវចិន។ ផ្លែស្វាយនេះមានទំហំប៉ុនកំភួនដៃ ហើយមានរាងទ្រវែង រីកប៉ោង កណ្តាល រួមស្តួចក្បាល និងគូទ។ ចំណែកនៅខាងក្បាលស្វាយនេះមានទងធំមានរាងជា រង្វង់ធំ ជុំវិញទង មានសណ្ឋានដូចជាត្រា។ ផ្លែស្វាយទុំមានពណ៌លឿងនិងមានក្លិនក្រអូបឈ្ងុយគួរឱ្យចង់ញ៉ាំ។ លើសពីនេះទៀតវាមានរសជាតិផ្អែមឆ្ងាញ់។ ផ្លែស្វាយទុំគេយកមកបរិភោគទាំងផ្លែស្រស់ជាបង្អែមជាមួយបាយស បាយដំណើប។ ម្យ៉ាងទៀតគេក៏អាចយកវាទៅកូរលើភ្លើងធ្វើជាផែនស្វាយ ឬហៅថាដំណាប់ស្វាយ បានថែមទៀតផង។

ខ្ញុំចូលចិត្តញ៉ាំផ្លែស្វាយទុំណាស់ ព្រោះវាជាផ្លែឈើមួយប្រភេទដែលជួយដល់សុខភាពរាងកាយនិងសុខភាពភ្នែក។ ខ្ញុំនឹងដាំវាឱ្យបានច្រើនក្នុងដីភូមិក្រោយផ្ទះខ្ញុំ។

៧.៤.៤- ឧទាហរណ៍ទី៤ (ថ្នាក់ទី៣ និងទី៤ )

**ប្រធាន**: ចូររៀបរាប់ពណ៌នាអំពីផ្លែចេកអំបូងទុំមួយស្ទង និងផលប្រយោជន៍របស់វាឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**១- សេចក្តីផ្តើម**

- ប្រាប់ឈ្មោះ
- ទីកន្លែង។

**២- តួសេចក្តី**

- លក្ខណៈរូបរាង: ផ្លែ មូល ឬទ្រវែង ទំហំតូច ធំ ពណ៌ ក្លិន និងរសជាតិ
- ផលប្រយោជន៍: ជាអាហារក្នុងគ្រួសារ ពិធីផ្សេងៗ និងដើម្បីសុខភាព។

**៣- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ចំពោះចេកអំបូងមានប្រយោជន៍ចំពោះសុខភាព លក់បានថ្លៃ
- ចំណាប់អារម្មណ៍: ចូលចិត្តដាំ និងបរិភោគ។

## សេចក្តីពណ៌នា

នៅក្នុងចម្ការខាងក្រោយផ្ទះរបស់ខ្ញុំមានដាំចេកអំបូងជាច្រើនគុម្ព។ ដើមខ្លះតូច ដើមខ្លះធំកំពុងទម្លាក់ ត្រយូង ហើយខ្លះទៀតកំពុងមានផ្លែខ្ចី ចាស់ និងទុំ។ ដោយឡែកមានដើមមួយនោះកំពុងមានផ្លែទុំទាំងស្ទង គួរឱ្យចង់បរិភោគ។

ចេកអំបូងទុំមួយស្ទងនោះមានរាងទ្រវែងជាកញ្ចុំដូចម្រាមដៃត្រួតបន្តគ្នាជាស្រទាប់ៗដែលហៅថាស្និត ហើយសណ្តូកវែងជិតដល់គល់។ ចេកអំបូងមួយស្ទងនេះមានចំនួនដប់ស្និត។ ក្នុងស្និតនីមួយៗមានផ្លែពី ដប់ប្រាំទៅម្ភៃ ផ្លែ ប៉ុន្តែផ្លែនៅចុងស្ទងមានរាងតូចៗ ហើយក៏មានចំនួនផ្លែតិចជាងគេដែរ។ ផ្លែចេកអំបូងមានរាងកោង មូល ធំទ្រវែង ប្រវែងប្រហែលជាងមួយចំអាមដៃ។ ផ្លែចេកអំបូងទុំ មានពណ៌ខៀវលាយលឿងតិចៗ ហើយមានសភាពរលោងដែលខុសពីចេកទុំដទៃទៀតតែងតែមានពណ៌លឿង។ ទោះបីវាទុំមានពណ៌ខៀវយ៉ាងនេះក្តីតែវាមានក្លិនក្រអូបប្រហើរឈ្ងុយ។ ចេកអំបូងទុំមានរសជាតិផ្អែមលាយជូរតិចៗខុសពីចេកទុំដទៃទៀតដែលមានរសជាតិផ្អែមមុត។ ចេកអំបូងទុំ ផ្តល់ប្រយោជន៍ច្រើនដូចជាប្រជាជនខ្មែរយើងនិយមយកចេកអំបូងទុំទៅបរិភោគជាបង្អែម ហើយចាស់ៗមួយចំនួននិយមបរិភោគលាយជាមួយអំបុក។ ជាពិសេសគេយកចេកអំបូងទៅធ្វើជាបង្អែមក្នុងអាពាហ៍ពិពាហ៍និងពិធីបុណ្យផ្សេងៗ។ លើសពីនេះទៀត ការបរិភោគចេកអំបូងជួយដល់សុខភាពរាងកាយ ស្បែក ជាពិសេសជំនួយដល់ភ្នែក និងការរំលាយអាហារ។

ចេកអំបូងជាពពួករភេទចេកងាយដាំ ឆាប់បានផលក៏បានថ្លៃ មានប្រយោជន៍ចំពោះសុខភាព។ ខ្ញុំចូល ចិត្តញ៉ាំ ចេកអំបូងទុំណាស់ ព្រោះវាមានរសជាតិផ្អែមឆ្ងាញ់និងមានប្រយោជន៍ចំពោះសុខភាព។ ខ្ញុំតែងតែជួយដាំ ស្រោចទឹក និងបោចស្មៅជាមួយពុកម៉ែរបស់ខ្ញុំ ត្បិតវាផ្តល់ចំណូលថវិកាច្រើន ដល់គ្រួសារខ្ញុំ។

### ៧.៤.៥- ឧទាហរណ៍ទី៥ (ថ្នាក់ទី៣ និងទី៤)

**ប្រធាន**: ចូររៀបរាប់ពណ៌នាអំពីផ្លែក្រូចឃ្វិចទុំ និងផលប្រយោជន៍របស់វាឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- ប្រាប់ឈ្មោះផ្លែឈើ។

**ខ- តួសេចក្ដី**

- លក្ខណៈរូបរាង: ផ្លែ មូល ឬទ្រវែង ទំហំ ពណ៌ ក្លិន និងរសជាតិ
- ផលប្រយោជន៍: ជាអាហារក្នុងគ្រួសារ ពិធីផ្សេងៗ និងដើម្បីសុខភាព។

**គ- សេចក្ដីបញ្ចប់**

- ការវាយតម្លៃ: ផ្លែក្រូចឃ្វិចមានរសជាតិឆ្ងាញ់ មានប្រយោជន៍ចំពោះសុខភាព
- ចំណាប់អារម្មណ៍: ចូលចិត្ត និងផលប្រយោជន៍។

## សេចក្ដីពណ៌នា

កាលពីព្រឹកថ្ងៃអាទិត្យជីតាខ្ញុំបានឱ្យផ្លែក្រូចឃ្វិចទុំមួយផ្លែមកខ្ញុំ។

ផ្លែក្រូចឃ្វិចមានរាងមូលរលោងនិងមានសម្បុរពណ៌លឿងទុំ។ ខ្ញុំបានបកក្រូចឃ្វិច ដោយដៃមិនប្រើកាំបិតឡើយ ព្រោះសម្បកវាស្ដើង។ លុះពេលបករួចខ្ញុំឃើញសម្បកក្រូចនៅផ្នែកខាងក្នុងមានសណ្ឋានគ្រើមៗនិងជាប់សសៃសៗ។ សម្បកក្រូចឃ្វិចមានក្លិនឈ្ងុយឆ្ងល។ គេអាចយកសម្បកក្រូចឃ្វិចដែលហាលស្ងួតទៅដុតដេញកម្ចាត់សត្វល្អិតបានយ៉ាងងាយ។ បន្ទាប់ពីសម្បកទៅខ្ញុំឃើញសាច់ក្រូចឃ្វិចមានសណ្ឋានជាក្លែបតូចៗនៅបន្តជាស្នូបជាប់ៗគ្នារាងមូល។ ខ្ញុំបានញ៉ាំក្រូចឃ្វិចនោះហើយទើបដឹងថាក្រូចឃ្វិចមានរសជាតិផ្អែមលាយជូរបន្តិច។ គេនិយមហៅថារសជាតិជូរអែមដែលគួរឱ្យចង់ញ៉ាំ។ ផ្លែក្រូចឃ្វិចគេយកទៅញ៉ាំជាបង្អែមផ្លែឈើឬច្របាច់យកទឹកញ៉ាំ។ លើសពីនេះទៅទៀតគេនិយមយកផ្លែក្រូចឃ្វិចទុំទៅប្រើប្រាស់ក្នុងពិធីបុណ្យផ្សេងៗនិងពិធីរៀបអាពាហ៍ពិពាហ៍។ គេជឿថា ក្រូចឃ្វិចជាផ្លែឈើលើករាសីដល់មនុស្ស និងអាចកម្ចាត់ភាពមិនល្អបាន។

ក្រូចឃ្វិចក៏ជាក្រូចមានរសជាតិឆ្ងាញ់និងមានតម្លៃនៅលើទីផ្សារផងដែរ។ ខ្ញុំចូលចិត្តញ៉ាំផ្លែក្រូចឃ្វិចទុំណាស់ ព្រោះវាជំនួយដល់សុខភាពជាពិសេសភ្នែក និងជំនួយដល់ការរំលាយអាហារទៀតផង។

## អត្រាកំណែ

### អត្រាពិន្ទុតែងសេចក្ដីពណ៌នាអំពីរុក្ខជាតិនិងផ្លែ

តែងសេចក្ដីពណ៌នាអំពីរុក្ខជាតិក៏មានអត្រាពិន្ទុ១០/១០ដែរ។ ក្រោយពីបញ្ចប់ការសិក្សាតែងសេចក្ដីគំរូ ឬឧទាហរណ៍ សិស្សឆ្លើយនឹងសំណួរ ដើម្បីពង្រីកការយល់ដឹងលើខ្លឹមសារតាមផ្នែកនីមួយៗ។ លោកគ្រូ អ្នកគ្រូនឹងបង្រៀនពីគម្រោងតែងសេចក្ដីថែមទៀត។ នៅក្នុងគម្រោងតែងលោកគ្រូ អ្នកគ្រូ ត្រូវតែពន្យល់សិស្សឱ្យ ច្បាស់លាស់អំពីខ្លឹមសារសំខាន់ៗដែលសិស្សត្រូវសរសេរ

រៀបចំតាក់តែងឱ្យបានពីរោះក្បោះក្បាយនិងមានខ្លឹមសារសមស្របតាមប្រធាន ដែលបានលើកឡើង។ ពិសេសគ្រូត្រូវណែនាំពីចំណុចដែលត្រូវបានពិន្ទុតាមផ្នែកនីមួយៗនៅក្នុងគម្រោងដើម្បីឱ្យសិស្សយល់ហើយខំសរសេរឱ្យបានពិន្ទុខ្ពស់ ហើយគ្រូក៏ត្រូវមានការលើកទឹកចិត្តឬជំរុញសិស្សឱ្យសរសេរបានរហូតដល់ចប់ផងដែរ។

ដូច្នេះ ក្នុងគម្រោងគ្រូត្រូវកំណត់នូវអត្រាពិន្ទុឱ្យច្បាស់តាមលំនាំដូចខាងក្រោម។

### អត្រាពិន្ទុ

**១- សេចក្តីផ្តើម** (១,៥០ពិន្ទុ)

- ប្រាប់ឈ្មោះ: រុក្ខជាតិឬផ្លែឈើ ១,០០ពិន្ទុ)
- ទីកន្លែង: ដាំដុះ (០,៥០ពិន្ទុ)

**ខ- តួសេចក្តី** (៦,០០ពិន្ទុ)

- លក្ខណៈរូបរាង: ផ្លែ មូល ឬទ្រវែង ទំហំតូច ធំ ពណ៌ ក្លិន និងរសជាតិ (៣,០០ពិន្ទុ)
- ផលប្រយោជន៍: ជាអាហារក្នុងគ្រួសារ ពិធីផ្សេងៗ និងដើម្បីសុខភាព (៣,០០ពិន្ទុ)

**គ- សេចក្តីបញ្ចប់** (១,៥០ពិន្ទុ)

- ការវាយតម្លៃ: ផលប្រយោជន៍ចំពោះសុខភាព លក់បានថ្លៃ (១,០០ពិន្ទុ)
- ចំណាប់អារម្មណ៍: ចូលចិត្តដាំ និងបរិភោគ (០,៥០ពិន្ទុ)

## ៧.៥- ប្រធានពណ៌នាអំពីទេសភាព

ការពណ៌នា គឺការថ្លែងរៀបរាប់ជាហូរហែយ៉ាងរស់រវើក ហើយពិតជាក់ស្តែងដូចឃើញផ្ទាល់ទេសភាពត្រង់ណាមួយ ដែលយើងបានឃើញច្បាស់ៗ។ ដើម្បីធ្វើយ៉ាងណាឱ្យអ្នកអានហាក់មើលឃើញឬស្តាប់ និងចាប់អារម្មណ៍ជាមួយនឹងការពណ៌នានេះ។ ការពណ៌នាបានល្អ គឺការអាស្រ័យលើអ្នកសរសេរចេះរៀបចំឃ្លាល្បះ តាមលំដាប់លំដោយគំនិតនិងអ្វីដែលបានឃើញហើយមានន័យគ្រប់គ្រាន់ច្បាស់លាស់។

៧.៥.១- ឧទាហរណ៍ទី១ (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីសួនបន្លែក្នុងសាលារៀនរបស់ប្អូន។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

- ទីតាំងដែលស្ថិតនៅ: ខាងក្រោយ ចំហៀង ឬខាងមុខសាលារៀន
- ទំហំ: គិតជាម៉ែត្រ រាងការេ ឬចតុកោណកែង ឬចតុកោណព្នាយ ឬត្រីកោណ។

**ខ- តួសេចក្តី**

- ទិដ្ឋភាពមើលពីចម្ងាយ: ពណ៌ រង ជួរត្រង់ត្រឹមស្មើគ្នា បន្លែ រត់រមេញត្រង់ដូចបន្ទាត់ សម្រស់បន្លែមានពណ៌ខៀវស្រងាត់ឬបៃតងស្រស់
- ទិដ្ឋភាពមកដល់ជិត: ឃើញច្បាស់ ដើម ស្លឹក ផ្លែ ផ្កា មើម... នៅក្នុងសួនបន្លែ

- សកម្មភាព: បោចស្មៅ ជ្រួយដី ចាប់ដង្កូវ ស្រោចទឹកដំណាំ ដាក់ជី យកចិត្តទុកដាក់ ថែទាំដាំដុះ ដដែកគ្នានៅក្បែរសួន ឬច្រៀងកម្សាន្ត
- -ផលប្រយោជន៍: សួនបន្លែមានសោភណភាពល្អ ផ្តល់ឱ្យយគ្រូសិស្សនូវប្រភេទបន្លែ ធម្មជាតិគ្រប់មុខ សម្រាប់បរិភោគនិងលក់នៅទីផ្សារ បានថវិកាជួយ ទ្រទ្រង់សាលាថែមទៀតផង។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: សួនបន្លែផ្តល់សោភណភាព បរិស្ថានសាលាពណ៌បៃតងស្រស់
- មនោសញ្ចេតនា: សួនបន្លែសាលារៀនខ្ញុំគួរឱ្យស្រឡាញ់ ខ្ញុំចូលចិត្ត ចង់ដាំនិងថែទាំ។

## សេចក្តីពណ៌នា

សាលារៀនខ្ញុំមានសួនបន្លែមួយ។ សួនបន្លែនោះស្ថិតនៅពីក្រោយថ្នាក់រៀនរបស់ខ្ញុំ។ វាមានរាងបួន ជ្រុងទ្រវែង ទទឹងប្រហែលដប់ម៉ែត្រ និងបណ្តោយប្រហែលដប់ប្រាំម៉ែត្រប៉ុណ្ណោះ។

ពេលមើលពីចម្ងាយ ខ្ញុំឃើញដំណាំក្នុងសួនមានពណ៌ខៀវស្រស់បំព្រង មានបន្លែច្រើនប្រភេទដូចជា ស្ពៃ ឆៃថាវ ត្រកួន ផ្ទី ស្លឹកគ្រៃ ម្ទេស និងដំណាំល្ពៅលូតលាស់គួរគយគន់។ ពេលដើរទៅជិតសួនខ្ញុំឃើញដំណាំនិងបន្លែទាំងអស់ដាំក្នុងរងនិងរត់ជាជួរៗរមេញយ៉ាងមានសណ្តាប់ធ្នាប់។ នៅកណ្តាលសួនមានបន្លែស្ពៃលូតលាស់បែកគុម្ពធំៗមានស្លឹក ក្របជិត ពេញផ្ទៃដី ឯឆៃថាវក៏លូតមើមផុសចេញផុតពីដីមានសម្បុរសស្គុសគួរឱ្យស្រឡាញ់។ ចំណែកត្រកួនវិញមាន ស្លឹកវែងលូតខ្ចីល្វក់ហើយរេរាំតាមកម្លាំងខ្យល់ជារលកៗ និងមានពណ៌បៃតងដូចកម្រាលព្រំជិតត្រកួន ខ្ញុំឃើញមានរងដើមខ្ទឹមដែលដុះស្លឹករាងមូលត្រង់ភ្លឹងទៅលើជាគុម្ពៗ។ បន្ទាប់ពីរងបន្លែខ្ញុំឃើញមានរងផ្ទី ស្លឹកគ្រៃម្ទេសដុះជិតដើមល្ហុងជាប់របងសួន។ បន្លែក្នុងសួនលូតលាស់ល្អទៅបានក៏ដោយសាស្នាដៃសិស្សទាំងអស់ នាំគ្នាដាំ ស្រោចទឹក និងថែរក្សា បោចស្មៅ ដាក់ជី ជ្រោយដីចាប់ដង្កូវរាល់ថ្ងៃ។ ដូចនេះហើយបានជាសួនបន្លែសាលារៀនខ្ញុំមានពណ៌បៃតងជានិច្ច។ សួនបន្លែសាលារៀនខ្ញុំបានផ្តល់ប្រយោជន៍ដល់សាលារៀននូវសោភ័ណភាព បរិស្ថានបៃតងស្រស់ មានភាពទាក់ទាញគួរឱ្យចង់ទស្សនានិងផ្តល់បន្លែដែលមិនមានជាតិគីមីដល់អ្នកបរិភោគថែមទៀត។ សិស្សានុសិស្សទាំងអស់ស្រឡាញ់និងចូលរួមដាំដុះថែទាំស្រោចទឹករហូតទទួលផលបានគ្រប់គ្នា។

សួនបន្លែក្នុងសាលារៀនខ្ញុំមានសោភណភាពស្រស់បំព្រងដើម្បីឱ្យសាលារៀនមានបរិស្ថាន។ ខ្ញុំ ចូលចិត្តញុំាបន្លែគ្រប់ប្រភេទ ព្រោះវាផ្តល់ជីជាតិដល់រាងកាយបានល្អ។ ខ្ញុំក៏ចូលចិត្តដាំបន្លែផងដែរ ព្រោះវាកាត់បន្ថយការចំណាយថវិកានៅក្នុងគ្រួសារដោយមិនបាច់ទិញនៅទីផ្សារ និងអាចយកទៅលក់បានថវិកា ជួយទ្រទ្រង់សាលារៀននិងគ្រួសារបានថែមទៀតផង។

**៧.៥.២- ឧទាហរណ៍ទី២** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីទេសភាពសួនបន្លែនៅផ្ទះរបស់ប្អូន។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ទីតាំងដែលស្ថិតនៅ: ខាងមុខ ខាងក្រោយ ចំហៀងផ្ទះ...
- ទំហំ: គិតជាម៉ែត្រ រាងចតុកោណកែង ការេ ឬត្រីកោណ។

**ខ- តួសេចក្ដី**

- ទិដ្ឋភាពមើលពីចម្ងាយ: ពណ៌រងត្រឹមស្មើគ្នា បន្លែរត់ជាជួរត្រង់ដូចបន្ទាត់សម្រស់បន្ថែមពណ៌ខៀវឬបៃតងស្រស់
- ទិដ្ឋភាពពេលមកដល់ជិត: ឃើញច្បាស់ ដើមស្លឹក ផ្លែផ្កា មើម...នៅក្នុងសួន
- សកម្មភាព: បោចស្មៅ ជ្រោយដី ដាក់ជី ចាប់ដង្កូវ ស្រោចទឹក ថែទាំ ដាំដុះ ជជែកគ្នាឬច្រៀងកម្សាន្ត
- ផលប្រយោជន៍: មានសោភណភាពល្អ បន្លែធម្មជាតិ សម្រាប់លក់និងបរិភោគ។

**គ- សេចក្ដីបញ្ចប់**

- ការវាយតម្លៃ: សោភណភាព បរិស្ថានបៃតងស្រស់
- ចំណាប់អារម្មណ៍: ការសម្ដែងមនោសញ្ចេតនា ស្រឡាញ់ ចូលចិត្តចង់ដាំ ថែទាំ ព្រោះសួនបន្លែផ្ដល់ផលប្រយោជន៍ក្នុងជីវភាពរស់នៅផ្ដល់សោភ័ណភាពបរិស្ថានល្អស្អាត។

## សេចក្ដីពណ៌នា

សព្វថ្ងៃ ខាងក្រោយផ្ទះខ្ញុំមានសួនបន្លែមួយរាងចតុកោណ ដែលមានបណ្ដោយម្ភៃម៉ែត្រ និងទទឹងដប់ពីរម៉ែត្រ។

ថ្ងៃនេះ ខ្ញុំបានទៅលេងសួនបន្លែជាមួយឪពុកម្ដាយនិងបងប្អូនធ្វើឱ្យចិត្តខ្ញុំសប្បាយរីករាយជាខ្លាំង។ ពេលមើលពីចម្ងាយ ខ្ញុំឃើញដំណាំក្នុងសួនមានពណ៌ខៀវស្រងាត់ហើយមានបន្លែច្រើនមុខដូចជាស្ពៃ ខាត់ណា ត្រកួន ឆៃថាវ និងណាំល្ហុងត្រឿលូតលាស់ស្រស់បំព្រងគួរជាទីគយគន់។ ពេលដើរទៅជិតសួនបន្លែ ខ្ញុំឃើញបន្លែទាំងអស់ដាំលើរងជាជួរៗយ៉ាងមានរបៀបរៀបរយ។ នៅកណ្ដាលសួនបន្លែស្ពៃ ខាត់ណាលូតលាស់បែកគុម្ពធំៗគួរជាទីពេញចិត្ត។ ឯឆៃថាវក៏ល្អណាស់ដែរ មើមពណ៌សក្បុសផុសផុតពីដីគួរឱ្យចង់បរិភោគ។ ចំណែកត្រកួនវិញក៏មិនចាញ់គេដែរ ស្លឹកវែងៗខ្ចីល្វក់ពេលត្រូវកម្លាំងខ្យល់រេរាំទៅមកប្រៀបដូចទឹករលកនិងមានពណ៌បៃតងស្រស់ដូចកម្រាលព្រំដែលក្រាលលើផ្ទៃដី។ នៅតាមរបងសួនបន្លែមានល្ហុងត្រឿដាំជាជួរបង្គួរបរាង បញ្ចេញផ្លែយ៉ាងច្រើនស្ទើរដល់ដីផ្លែខ្លះខ្ចី ខ្លះចាស់ ខ្លះទុំ មើលទៅគួរឱ្យចង់បរិភោគ។ គ្រួសារខ្ញុំនាំគ្នាថែរក្សាស្រោចទឹក បោចស្មៅជ្រួយដី ដាក់ជី ចាប់ដង្កូវ បេះស្លឹកណាមិនល្អចេញជារៀងរាល់ថ្ងៃ។ ធ្វើការបណ្ដើរឪពុកម្ដាយខ្ញុំគាត់ជជែកគ្នាពីដំណាំដុះលូតលាស់បានល្អបណ្ដើរទឹកមុខប្រកបដោយក្ដីរីករាយ។ ឯខ្ញុំនិងបងប្អូនខ្ញុំនាំគ្នាច្រៀងលេងកម្សាន្តកំដរបរិយាកាសភ្លេចអស់ការនឿយហត់។ សួនបន្លែគ្រួសារខ្ញុំបានផ្ដល់ផលប្រយោជន៍ជាច្រើនដូចជាសម្រាប់បរិភោគ លក់ និងផ្ដល់នូវសោភ័ណភាពបរិស្ថានបៃតងស្រស់មានភាពទាក់ទងគួរឱ្យចង់ទស្សនានិងផ្ដល់នូវបន្លែគ្មានជាតិគីមីសម្រាប់គ្រួសារខ្ញុំយកមកបរិភោគថែមទៀត។

សួនបន្លែនៅផ្ទះខ្ញុំមានទិដ្ឋភាពបៃតងស្រស់គួរគយគន់។ ខ្ញុំស្រឡាញ់ពេញចិត្តនឹងសួនបន្លែនេះណាស់ ហើយខ្ញុំនឹងខិតខំដាំបន្លែមទៀត ដើម្បីបានបន្លែកាន់តែច្រើនសម្រាប់ធ្វើជាម្ហូបនិងយកទៅលក់បានថវិកាជួយទ្រទ្រង់ជីវភាពគ្រួសារខ្ញុំថែមទៀតផង។

### ៧.៥.៣- ឧទាហរណ៍ទី៣ (ថ្នាក់ ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីទេសភាពវាលស្រែនៅពេលប្រជាកសិករកំពុងដកស្ទូង។

## គម្រោងតែង

**១- សេចក្តីផ្តើម**

- ទីកន្លែង: វាលស្រែក្រោយភូមិ ឆ្ងាយពីភូមិ
- ពេលវេលា: រដូវវស្សាពេលព្រលឹម ឬថ្ងៃរសៀល។

**២- តួសេចក្តី**

- ទិដ្ឋភាពពីចម្ងាយ: ឃើញវាលស្រែ ទឹកក្នុងស្រែ ដើមត្នោត ដុះតាមវាលស្រែដើមឈើតូចៗ លើភ្លឺស្រែ ព្រៃគុម្ពោត ដំបូក
- ទិដ្ឋភាពជុំវិញខ្លួន: វាលស្រែស្ទូងហើយ តិចឬច្រើន ពណ៌សន្ទូង កម្ពស់សន្ទូង... វាលស្រែមិនទាន់ស្ទូង ទឹក ដីអាចម៍បំណះ ស្មៅមួយៗ
- វាលស្រែកំពុងស្ទូង: ទឹកល្អក់ សន្ទូងថ្មី ពណ៌លឿង ភ្លឺស្រែមាន អាចម៍បំណះ កណ្តាប់តម្រៀបគ្នាជាជួរក្រោយអ្នកស្ទូង
- សកម្មភាពមនុស្សនិងសត្វ: ប្រុសៗកំពុងភ្ជួររាស់ សម្លៀកបំពាក់កសិករ ស្នូរទឹក សំឡេងដេញសត្វ ស្រីៗសម្លៀកបំពាក់ ទឹកត្រឹមកំភួនជើង ស្ទូងទន្ទឹមគ្នា ស្ទូងផង និយាយគ្នាផង ច្រៀងលេងផង។
- សត្វគោ ក្របី: អូសទាញ គ្រវីស្នែងពេលត្រូវរំពាត់ ខ្សែតី
- បរិយាកាសពេលស្ទូង: ខ្លះស្ទូងប្រណាំងគ្នា ដើម្បីដាក់ "ទ្រុង ឬទម្លាក់អណ្តូង" ខ្លះជជែកចំអែចំអន់គ្នាលេង ច្រៀងលេង
- សកម្មភាពប្អូនៗ: ជួយស្ទូង ជួយជញ្ជូនកណ្តាប់ចុះក្នុងស្រែ ជួយបោចស្មៅ។

**៣- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ទេសភាពនិងសកម្មភាពវាលស្រែនារដូវដកស្ទូងដែលមានភាពរស់រវើក ស្រស់បំព្រង
- ចំណាប់អារម្មណ៍: មនោសញ្ចេតនាប្អូនចំពោះទេសភាពនិងសកម្មភាពទាំងនោះ (ប្អូនសប្បាយចិត្ត ព្រោះបានទស្សនាផ្ទាល់ភ្នែកឬបានចូលរួមសកម្មភាពស្ទូងជាមួយកសិករ ...)។

## សេចក្តីពណ៌នា

នៅវិស្សមកាលកន្លងផុតទៅថ្មីៗនេះ ខ្ញុំបានទៅលេងផ្ទះជីតាខ្ញុំនៅឯស្រុកស្រែ។ ពេលនោះជារដូវដែលប្រជាកសិករយើងកំពុងដកស្ទូង ហើយជារដូវដែលនាំឱ្យចិត្តខ្ញុំនឹកឃើញជានិច្ចនូវទេសភាពដ៏ត្រកាលគ្មានពីរ។

ពេលព្រឹកព្រលឹម ព្រះអាទិត្យបញ្ចេញពន្លឺក្រហមព្រឿងៗពីទិសបូព៌ សកម្មភាពនិងសម្រស់ធម្មជាតិដែលបានលង់លក់ស្កប់ស្កល់ក្នុងរាត្រីកាលក៏មានជីវិតរស់រវើកឡើងវិញ។ នៅតាមផ្លូវវាលស្រែដែលមានទឹកល្អល្អាច សន្ទូងពណ៌បៃតងចាស់លាតសន្ធឹងល្វឹងល្វើយដាច់កន្ទុយភ្នែក។ ដំណក់ទឹកភ្លៀងពីពេលយប់បានដក់ជាប់នឹងស្លឹកស្រូវមើលទៅហាក់ដូចជាគ្រាប់ពេជ្ររាប់ម៉ឺនសែនដេញ

ជាមួយនឹងរស្មីព្រះអាទិត្យ។ ដើមត្នោតរៀងរាវឈរបង្អួតរាងយ៉ាងសង្ហាជាជួរ តាមភ្លឺស្រែនានាដូចជាក្លស់ជួយការពារសន្ទូងដែលទើបនឹងស្ទូងរួចមិនឱ្យត្រូវកំដៅព្រះអាទិត្យ។ គយគន់ទៅឆ្ងាយបន្តិចយើងឃើញស្រែខ្លះមានសន្ទូងកំពុងបែកគុម្ពនិងលាស់មានពណ៌ខៀវស្រងាត់។ ស្រែដែលមិនទាន់បានស្ទូងមានទឹកព្រៀបភ្លឺ ហើយមានវារីជាតិដុះជាច្រើនដូចជា ដើមផ្ទក់ទឹក ដើមប្រាច់ ស្គន់អំបោះព្រលឹតជាដើមបណ្តែតខ្លួនលើផ្ទៃទឹកហាក់គ្មានបារម្ភឡើយ។ សត្វកុក ក្រសារ រនាល សារិកាកែវ គ្រលីង គ្រលោងហើររកចំណីទាំងហ្វូងៗពីស្រែមួយទៅស្រែមួយទៀតគួរឱ្យចង់ទស្សនា។ សំឡេងស្រែកដេញសត្វពាហនៈរបស់ពូៗដែលកំពុងភ្ជួររាស់ក្នុងស្រែឮមិនដាច់សូរឡើយ។ ចំណែកមីងៗវិញខ្លះកំពុងទូលបាយយកទៅស្រែ។ ខ្លះទៀតកំពុងស្ទូងឱនងើបៗយ៉ាងសកម្មនិងយកចិត្តទុកដាក់បំផុត។ ពួកគាត់ស្ទូងបណ្តើរនិយាយគ្នាលេងបណ្តើរពីអតីតកាល។ ជួនកាលចំអែចំអន់គ្នាលេង ឬនិយាយកំប្លែងពីនេះពីនោះដើម្បីបំបាត់ការនឿយហត់ប្រកបដោយភាពរីករាយ។ យូរៗម្តងគេឮសំឡេងសើចក្អាកក្អាយ របស់កសិករយើងពេញវាលស្រែ។

ទេសភាពវាលស្រែនៅរដូវដកស្ទូងមានសកម្មភាពរស់រវើកនិងស្រស់ល្អគ្រាកាល។ ទិដ្ឋភាពនេះធ្វើឱ្យខ្ញុំចងចាំ ហើយមានទឹកចិត្តគោរពស្រឡាញ់ពូមីងជាប្រជាកសិករយើង ព្រោះគាត់ជាអ្នកចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានភាពរីកចម្រើន។

**៧.៥.៤- ឧទាហរណ៍ទី៤** (ថ្នាក់ ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីទេសភាពវាលស្រែនៅរដូវចម្រូត។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ទីកន្លែង: វាលស្រែក្បែរភូមិ
- ពេលវេលា: រដូវប្រាំង ពេលព្រលឹមឬពេលរសៀល ...។

**ខ- តួសេចក្តី**

- ទេសភាព: ទេសភាពពេលព្រឹក រសៀល វាលស្រែពណ៌លឿងទុំ ព្រៃព្រឹក្សា អូរ ប្រឡាយជុំវិញ
- សកម្មភាព: កសិករ ក្មេងចាស់ ប្រុសស្រី កំពុងច្រូតកាត់ បោកបែន ដឹកជញ្ជូនសត្វចាបខ្លះចុះស៊ីស្រូវ គោក្របីទឹមរទេះ ដឹកជញ្ជូនកណ្តាប់ និងស្រូវទៅភូមិធម្មជាតិនិងពន្លឺព្រះអាទិត្យ ដើមឈើតាមភ្លឺស្រែ ខ្យល់ជំនោរបក់រហើយប្រហើរក្លិន ស្រូវទុំ
- បរិយាកាស: សប្បាយរីករាយ ពេញចិត្តនឹងទេសភាពវាលស្រែពេលរដូវចម្រូតបានទទួលផលស្រូវជាទីពេញចិត្ត។

**គ- សេចក្តីបញ្ចប់**

- វាយតម្លៃ: ទេសភាពវាលស្រែនៅរដូវចម្រូត
- ចំណាប់អារម្មណ៍: មនោសញ្ចេតនាចំពោះទេសភាពរដូវចម្រូតសប្បាយរីករាយជាមួយកសិករដែលប្រមូលផលច្រើន បំពេញតម្រូវការជីវភាពក្នុងគ្រួសារប្រកបដោយភាពសម្បូរសប្បាយ។

## សេចក្តីពណ៌នា

កាលពីថ្ងៃអាទិត្យមុន ខ្ញុំនិងគ្រួសារបានធ្វើដំណើរទៅកម្សាន្តនៅស្រុកស្រែចំពេលរដូវរំហើយមានស្រូវទុំពេញវាលស្រែ។

ទេសភាពវាលស្រែធំល្វឹងល្វើយដាច់កន្ទុយភ្នែក ខ្ញុំឃើញស្រូវទុំដេរដាស មានពណ៌លឿងឆ្អិនឆ្អៅដូចកម្រាលព្រំមាស។ កសិករក្មេងចាស់ ប្រុសស្រីខ្លះកំពុងច្រូតកាត់ ខ្លះទៀតកំពុងរៀបជញ្ជូនកណ្តាប់ស្រូវចូលក្នុងរទេះដើម្បីដឹកទៅភូមិទុកបែននាពេលរាត្រី។ ពួកគាត់ច្រូតស្រូវបណ្តើរច្រៀងលេងបណ្តើរនិងនិយាយចំអែចំអន់គ្នាបណ្តើរធ្វើឱ្យបរិយាកាសមានភាពសប្បាយរីករាយភ្លេចការនឿយហត់ក្នុងការធ្វើការងារដែលស្ថិតក្រោមកម្តៅព្រះអាទិត្យ។ នៅវាលស្រែយូរៗម្តងមានខ្យល់បក់រំភើយៗ នាំមកនូវក្លិនប្រហើរ របស់ស្រូវទុំ និងក្លិនម្អមឈ្ងុយឈ្ងប់ជាប់នាសាធ្វើឱ្យខ្ញុំស្រូបមិនជិនណាយនិងសប្បាយរីករាយនឹងទេសភាពវាលស្រែនៅរដូវចម្រូតជាមួយកសិករក្នុងពេលប្រមូលផលនេះដែរ។

ទេសភាពវាលស្រែនារដូវចម្រូតពិតជាមានភាពទាក់ទាញគួរឱ្យចាប់អារម្មណ៍និងចង់ឃើញទិដ្ឋភាពនេះម្តងទៀត។ ខ្ញុំស្រឡាញ់ទេសភាពវាលស្រែនារដូវចម្រូតនេះណាស់។ វាពិតជាធ្វើឱ្យខ្ញុំដក់ជាប់ក្នុង អារម្មណ៍នូវសកម្មភាពច្រូតកាត់និងការប្រមូលផលរបស់កសិករ ព្រោះផលស្រូវទាំងនោះបានបំពេញតម្រូវការក្នុងជីវភាពគ្រួសារប្រជាកសិករឱ្យសម្បូរសប្បាយ។

**៧.៥.៥- ឧទាហរណ៍ទី៥** (ថ្នាក់ទី៥ និងទី៦)

លំហាត់សម្រាប់សិស្សអនុវត្តដោយហ្វឹកហាត់ដោយធ្វើសេចក្តីអធិប្បាយតាមគម្រោងដូចខាងក្រោម។

**ប្រធាន**: ចូរប្អូនពណ៌នាអំពីទេសភាពនៅមាត់ទន្លេដែលប្អូនៗបានទៅស្ងួចត្រី

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ទីកន្លែង: នៅមាត់ទន្លេ ក្បែរផ្ទះ ឬទន្លេមុខវាំង ...
- ពេលវេលា: ព្រឹកឬល្ងាច រដូវទឹកតំឡើង ឬរដូវទឹកសម្រក។

**ខ- តួសេចក្តី**

- ទេសភាព: បង្ហាញពីសភាពនៃរស្មីឬពន្លឺ ព្រះអាទិត្យ ចលនាទឹក ផ្ទៃមេឃ ផ្ទៃទឹក ខ្យល់ជំនោរពេល រសៀល ល្ងាច ទឹករលក ព្រៃព្រឹក្សា ដុះប្របមាត់ទឹក ...
- សកម្មភាពមនុស្ស: អ្នកនេសាទ អ្នកងូតទឹក អ្នកទេសចរ... នៅតាមមាត់ទន្លេ...ទូកល្បាត... ទូកទំនិញ
- បរិយាកាស: អារម្មណ៍ធូរស្រាល សប្បាយរីករាយ លំហែអារម្មណ៍ កម្សាន្តក្នុងការស្ទូចត្រី។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ទេសភាពនៅមាត់ទន្លេដែលប្អូនៗបានទៅស្ទូចត្រីមានភាពទាក់ទាញ
- ចំណាប់អារម្មណ៍: សម្តែងមនោសញ្ចេតនានៅពេលទៅស្ទូចត្រីនិងទស្សនីយភាពនៅមាត់ទន្លេធ្វើឱ្យអារម្មណ៍សប្បាយរីករាយ។

### ៧.៥.៦- ឧទាហរណ៍ទី៦ (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: សាលារៀនរបស់ប្អូនបានរៀបចំកម្មវិធីមួយដើម្បីចូលរួមអបអរសាទរទិវាកុមារអន្តរជាតិមួយមិថុនា។ ចូរប្អូនពណ៌នាឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- ឈ្មោះពិធី
- ពេលវេលានិងទីកន្លែងរៀបចំពិធី។

**ខ- តួសេចក្ដី**

- មុនពេលរៀបចំពិធីសកម្មភាពអ្នកចូលរួម
- ពេលដំណើរការកម្មវិធីសកម្មភាពអនុវត្តលំដាប់លំដោយដែលបានព្រាងទុកក្រោយពីចប់កម្មវិធី។

**គ- សេចក្ដីបញ្ចប់**

- ការវាយតម្លៃ: ទិវាកុមារអន្តរជាតិមួយមិថុនា
- ចំណាប់អារម្មណ៍: សម្ដែងមនោសញ្ចេតនាចូលរួមក្នុងសកម្មភាពនោះ។

## សេចក្ដីពណ៌នា

នៅសាលាបឋមសិក្សាពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម បានរៀបចំនូវពិធីមួយមានឈ្មោះថា ទិវាកុមារអន្តរជាតិមួយមិថុនា។ ទិវានេះបានរៀបចំឡើងក្នុងថ្ងៃទីមួយខែមិថុនានេះតែម្ដង។ បើតាមប្រសាសន៍លោកនាយកដែលបានប្រជុំប្រាប់ទាំងលោកគ្រូ អ្នកគ្រូ គណៈកម្មការទ្រទ្រង់សាលារៀននិងសិស្សានុសិស្សកាលពីថ្ងៃចន្ទសប្ដាហ៍មុនបានឱ្យដឹងថា ការរៀបចំពិធីទិវាកុមារអន្តរជាតិមួយមិថុនានេះឡើង គឺដើម្បីរំលឹកនូវអំពើព្រៃផ្សៃ កាច ឃោរឃៅរបស់ពួកអ៊ីត្លែរនៅប្រទេសអាល្លឺម៉ង់ និងពួកប៉ុលពតនៅប្រទេសកម្ពុជាដែលបានសម្លាប់ប្រជាជន ក្នុងនោះមានកុមារអស់រាប់លាននាក់ផងដែរ។

មុនថ្ងៃចាប់ផ្ដើមកម្មវិធីរយៈពេលពីរថ្ងៃ យើងឃើញនៅតាមដងផ្លូវនានាមានការរៀបចំចងបដាពាក្យ ស្លោក ទង់ជាតិព្រោងព្រាត។ ដោយឡែកសាលាបឋមសិក្សាយើងខ្ញុំក៏មានការចូលរួមរៀបចំតុបតែងនៅតាមរបង ក្លោងទ្វារ ដូចជាផ្កាភ្ញី ទង់ជ្វាលា ទង់ជាតិ ផ្ទាំងកំណាត់សរសេរឈ្មោះពិធី រោងគណៈអធិបតី ភ្ញៀវកិត្តិយស និងភ្ញៀវចូលរួម ការតុបតែងភ្លើងពណ៌ មេក្រូ ក្រុមកុមារច្រៀងចម្រៀងគោរពទង់ជាតិ ហ្វឹក ហាត់ក្រុមរបាំ ក្រុមកុមារ លេងល្បែងប្រជាប្រិយ និងក្រុមកុមារកាន់កម្មវិធី។ ជាមួយនេះក្រុមកុមារដែល ស្រោចផ្កា និងបោសសម្អាត ពិនិត្យឃើញមានភាពសកម្មតាមមុខការរៀងៗខ្លួនតាមការបែងចែក។ ក្នុងពិធីនេះ ខ្ញុំឃើញមានភ្ញៀវ អ្នកមុខអ្នកការអញ្ជើញមកចូលរួមជាបន្តបន្ទាប់។ ពួកគាត់ស្លៀកពាក់ស្អាតបាតសមរម្យ។ ម៉ោងប្រាំពីរកន្លះអ្វីៗដែលបានគ្រោង ទុកជាមុនមានសភាពរៀបរយល្អណាស់។ ម៉ោងប្រាំបីគត់ ខ្ញុំឃើញក្រុមកុមារដែលត្រូវឈរអមផ្លូវគណៈអធិបតី ឈរតំរៀបជាពីរជួរត្រង់ល្អ និងឮសូរសំឡេងទះដៃអបអរសាទរ។ ខ្ញុំក្រឡេកទៅក្លោងទ្វារសាលាឃើញលោកនាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សទាំងអស់ សម្ដែងការស្វាគមន៍ ចំពោះ

គណៈអធិបតីនិងភ្ញៀវកិត្តិយសដែលអញ្ជើញចូលរួមក្នុងពិធីនេះយ៉ាងអធិកអធម។ មកដល់មុខរោងវេទិកា ខ្ញុំឃើញគាត់ញញឹម សំពះ សម្តែងការគោរពស្វាគមន៍ដល់សមាជិកទាំងអស់យ៉ាងក្រៃលែង។ ស្របជាមួយនោះ អ្នកកាន់កម្មវិធីក៏ចាប់ផ្តើម។ ពេលនេះទើបខ្ញុំដឹងថា សាលារៀនរបស់ខ្ញុំមានកិត្តិយសខ្លាំងណាស់ ព្រោះថាគ្រាន់តែរៀបចំពិធីក្នុងសាលាសោះ មានរហូតលោក អភិបាល ស្រុក លោកមេឃុំ លោកប្រធានអង្គភាពកងកម្លាំង ប្រដាប់អាវុធទាំងបី និងលោកប្រធាន ការិយាល័យអប់រំ ស្រុក លោកប្រធានភូមិ មន្ត្រីសុខាភិបាល មាតាបិតា យ៉ាងច្រើនកុះករ។ តាមការសរុបចំនួនអ្នកចូលរួមរបស់អ្នកកាន់កម្មវិធីមានរហូតដល់ប្រាំមួយរយហាសិបនាក់។ ក្នុងពេលដំណើរការកម្មវិធីជាបន្តបន្ទាប់ដែលមានប្រកាសហេតុ ប្រកាសប្រធានគណៈអធិបតី គោរពទង់ជាតិ....។ល។ ចំពោះកម្មវិធីទាំងអស់ ខ្ញុំចាប់អារម្មណ៍និងរន្ធត់ចិត្តខ្លាំងជាងគេគឺក្នុងកម្មវិធីរបស់អ៊ំអភិបាលស្រុកដែលលោកថ្លែងថា មនុស្សត្រូវបានគេដុតទាំងរស់កុមារត្រូវបានគេចាប់បោកសម្លាប់។ គេឱ្យមនុស្សធ្វើការធ្ងន់ដូចគោ ក្របី តែគេឱ្យហូបចុកមិនគ្រប់គ្រាន់ និងជូនកាលបង្អត់អាហារថែមទៀតផង។ ខ្ញុំស្រមៃថា ប្រសិនបើខ្ញុំកើតក្នុងរបបទាំងនោះម្ល៉េះសមខ្ញុំត្រូវបានទទួលរងនូវអំពើទាំងនោះដែរហើយ។ កំពុងតែស្លុងអារម្មណ៍ស្រាប់ តែដល់កម្មវិធី កុមារឡើងសូត្រកំណាព្យ។ គួរឱ្យកោតសរសើរបំផុតនៅពេលដែលខ្ញុំបានឮសំឡេងសូត្រកំណាព្យដ៏ពិរោះរបស់ប្អូនៗកុមារក្នុងទិវានេះ។ លើសពីនេះទៀត ក៏ឃើញមានការសម្តែងរបាំ និងចម្រៀង ផ្សេងៗយ៉ាងជក់ចិត្តចាប់អារម្មណ៍។

កម្មវិធីកុមារអន្តរជាតិមួយមិថុនា បានបញ្ចប់នៅម៉ោងដប់សាមសិបនាទី។ ទិវាអន្តរជាតិមួយមិថុនា ពិតជាមានអត្ថន័យបំផុតសម្រាប់កុមារនៅកម្ពុជាក៏ដូចជាកុមារទាំងអស់លើពិភពលោក។ ក្រោយបញ្ចប់ទិវាកុមារអន្តរជាតិមួយមិថុនានេះរួច ខ្ញុំមានអារម្មណ៍សប្បាយរីករាយជាមួយកុមារទាំងអស់។ ទិវានេះបានធ្វើឱ្យយើងមានការចងចាំនិងនឹកឃើញជានិច្ចដល់ការលើកស្ទួយកុមារឱ្យរួចផុតពីអំពើជិះជាន់កេងប្រវ័ញ្ចនិងការជួញដូរកុមារ។ សូមឱ្យទិវាកុមារអន្តរជាតិមួយមិថុនាស្ថិតនៅជាអមតៈជាមួយកុមារទាំងអស់។

**៧.៥.៧- ឧទាហរណ៍ទី៧** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាឱ្យបានគ្រប់ជ្រុងជ្រោយអំពីទិដ្ឋភាពនិងសកម្មភាពនៅចំណតរថយន្តក្រុង។

## គម្រោងតែង

**ក.សេចក្តីផ្តើម**

- ឈ្មោះទីកន្លែង
- ពេលវេលា ដែលបានទៅដល់ទីកន្លែងនោះ។

**ខ.តួសេចក្តី**

- ទិដ្ឋភាពសកម្មភាពអ្នកដំណើរដែលមកកាន់ចំណតរថយន្តក្រុងមុនពេលចេញដំណើរ
- ទិដ្ឋភាពនិងសកម្មភាពអ្នកដំណើរពេលនៅក្នុងរថយន្តក្រុង
- ទិដ្ឋភាពនិងសកម្មភាពពេលរថយន្តក្រុងមកដល់គោលដៅ។

**គ.សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ទិដ្ឋភាពនិងសកម្មភាពនៅចំណតរថយន្តក្រុងទាំងពេចេញដំណើរនិងពេលទៅដល់គោលដៅ
- ចំណាប់អារម្មណ៍: ការសម្តែងមនោសញ្ចេតនាផ្ទាល់ខ្លួនចំពោះទីកន្លែងនោះ។

## សេចក្តីពណ៌នា

វេលាម៉ោងប្រាំពីរសាមសិបនាទីដល់ម៉ោងប្រាំបីនាថ្ងៃអាទិត្យមួយខ្ញុំបានមកដល់ចំណតរថយន្តក្រុងដើម្បីធ្វើដំណើរទៅរាជធានីភ្នំពេញ។

ខ្ញុំនិងឪពុកខ្ញុំបានអង្គុយរង់ចាំជិះរថយន្តក្រុងនៅចំណតរថយន្តក្រុង ដែលមានទីតាំងមុខស្ពានច្បារផ្លូវឆ្ពោះ ក្រុងកំពង់ចាមដើម្បីធ្វើដំណើរទៅសួរសុខទុក្ខលោកយាយខាងពុកនៅភ្នំពេញ។ ការរង់ចាំនៅចំណតរថយន្តក្រុង ខ្ញុំបានឃើញអ្នកដំណើរខ្លះជិះយានយន្តច្រើនប្រភេទទៅមកមិនឈប់និងខ្លះទៀតធ្វើដំណើរដោយថ្មើរជើងតាមដងផ្លូវ។ រីឯអ្នកដំណើរដែលត្រូវជិះរថយន្តក្រុង ខ្លះក៏បានមកដល់មុន ឯអ្នកខ្លះទៀតមកដល់ក្រោយបន្តគ្នាជាបណ្តើរៗដើម្បីបន្តដំណើរតាមគោលដៅរៀងខ្លួន។ ចំពោះភ្ញៀវណាដែលបានមកដល់ចំណតមុនហើយមិនទាន់ដល់ម៉ោងរថយន្តចេញដំណើរគេក៏មានពេលទៅស្រស់ស្រូបអាហារពេលព្រឹកនៅភោជនីយដ្ឋានជិតៗចំណត។ ចំពោះអ្នកដំណើរណាមានរបស់ទ្រព្យឬសម្ភារៈច្រើន គេបានយកទៅទុកដាក់នៅក្នុងឃ្លុបដាក់អីវ៉ាន់របស់រថយន្តនិងកត់លេខកៅអីតាមលេខសំបុត្រដែល ឥបានទិញរួចទុកចំណាំនៅលើអីវ៉ាន់នោះដើម្បីងាយផ្ទៀងយកអីវ៉ាន់ពេលប្រគល់។ កន្លែងអង្គុយរង់ចាំក្នុងចំណតរថយន្តក្រុងនេះពុំមានទីធ្លាធំទូលាយទេ តែភ្ញៀវអាចសម្រាករង់ចាំមួយរយៈពេលខ្លីបាន។ ក្នុងចំណោមភ្ញៀវទាំងអស់ ខ្ញុំឃើញមានជនបរទេសខ្លះក៏បានរង់ចាំជិះរថយន្តក្រុងដែរ។ ពួកគាត់ភាគច្រើនជាភ្ញៀវទេសចរណ៍ដែលមានសម្លៀតធំៗ។ ខ្ញុំបានញញឹមទាក់ទងជាមួយពួកគាត់យ៉ាងស្និទ្ធស្នាលតាមទម្លាប់ប្រពៃណីខ្មែរ ពួកគាត់ភាគច្រើនមានកាន់សៀវភៅអានតាមទម្លាប់របស់គាត់ គ្រប់ពេលធ្វើដំណើរទៅណាមកណាតែងអានសៀវភៅជានិច្ច។ ម៉ោងប្រាំបីគត់ ខ្ញុំ និងលោកឪពុករួមទាំងអ្នកដំណើរឯទៀតបានចេញចាកពីចំណតកំពង់ចាមតម្រង់ដំណើរឆ្ពោះទៅរាជធានីភ្នំពេញ។ ពេលនៅក្នុងរថយន្ត អ្នកដំណើរខ្លះកំពុងជជែកគ្នាលេង ខ្លះអានកាសែត ទស្សនាវដ្តី សៀវភៅរឿង និងមើលទេសភាពតាមដងផ្លូវ។ មិនយូរប៉ុន្មានរថយន្តបានមកដល់រាជធានីភ្នំពេញ។ ខ្ញុំនិងឪពុកខ្ញុំក៏បានចុះពីរថយន្តនិងបន្តដំណើរតាមស៊ីក្លូទៅផ្ទះលោកយាយខ្ញុំ។

ចំណតរថយន្តក្រុងដែលខ្ញុំបានឃើញទាំងនៅក្នុងខេត្តនិងរាជធានីភ្នំពេញ ថ្វីត្បិតពុំសូវមានបរិវេណធំទូលាយសម្រាប់ទទួលភ្ញៀវរង់ចាំក៏ពិតមែន ប៉ុន្តែសេវាដឹកអ្នកដំណើរទៅមកមានលក្ខណៈល្អប្រសើរអាចទទួលយកបានដូចជា ការរាក់ទាក់ អនាម័យ បន្ទប់ទឹកស្អាតគ្រប់គ្រាន់ សម្រាប់ភ្ញៀវប្រើប្រាស់ជាដើម។ ខ្ញុំពេញចិត្តនឹងការរៀបចំសេវានេះណាស់។ សេវានេះជាសេវាឆាប់រហ័សទាន់ចិត្ត តម្លៃសមរម្យ និងមានសុវត្ថិភាពធ្វើឱ្យអ្នកជិះតាមរថយន្តសុរិយាមាន ជំនឿនិងទំនុកចិត្តក្នុងការធ្វើដំណើរគ្រប់ពេលវេលាគ្រប់ទីកន្លែង។

៧.៥.៨-ឧទាហរណ៍ទី៨ (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរអ្នកសរសេរពណ៌នាអំពីទេសភាពវត្តឯកភ្នំ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ឈ្មោះ
- ទីកន្លែង។

**ខ- តួសេចក្តី**

- ទិដ្ឋភាពមើលពីឆ្ងាយ: ព្រះវិហារ ដើមឈើតូចធំ
- ទិដ្ឋភាពពេលចូលជិត: ពេលបុណ្យទាន មានភាពអ៊ូរអរ បរិយាកាសល្អ
- ផលប្រយោជន៍: ជាទីសក្ការៈ រមណីយដ្ឋានប្រវត្តិសាស្ត្រ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ : ពីទេសភាពវត្តឯកភ្នំ
- ចំណាប់អារម្មណ៍: ការសម្តែងមនោសញ្ចេតនាផ្ទាល់ខ្លួនចំពោះទីកន្លែងនោះ។

## សេចក្តីពណ៌នា

វត្តឯកភ្នំស្ថិតនៅក្នុងស្រុកឯកភ្នំខេត្តបាត់ដំបង។ វត្តនេះតាំងនៅទីខ្ពង់រាបក្បែរប្រាសាទឯកភ្នំ។

បើមើលពីចម្ងាយគេឃើញកំពូលព្រះវិហារខ្ពស់ត្រដែតផុតចុងព្រឹក្សានានា។ នៅរដូវវស្សា ព្រះវិហារអណ្តែតឡើងទៅលើផ្ទៃទឹកដ៏ធំល្វឹងល្វើយ។ ទេសភាពនៅពេលនោះមិនខុសប្លែកពីសមុទ្រដ៏ធំធេងនោះឡើយ។ រុក្ខជាតិទាំងឡាយត្រូវផ្ទៃទឹកសង្កត់យ៉ាងដំណំ។ ពេលចូលដល់ក្នុងវត្តនៅរាល់ពេលបុណ្យទាន ពិសេសពេលបុណ្យភ្ជុំបិណ្ឌ វត្តឯកភ្នំមានសភាពអ៊ូអរ និងមានបរិយាកាសរីករាយប្លែកលើសធម្មតា។ នៅរដូវទឹកស្រកទេសភាពជុំវិញបានប្រែក្លាយទៅជាវាលស្រែខៀវស្រងាត់លាតសន្ធឹងធំវែងមើលទៅឆ្ងាយសន្លឹមជាប់នឹងជើងមេឃ។ វត្តឯកភ្នំជារមណីយដ្ឋានដ៏សែនមនោរម្យ។ ធាតុអាកាសល្អបរិសុទ្ធប្រៀបបាននឹងឱសថទិព្វបំបាត់កង្វល់និងការនឿយហត់។ មិនតែប៉ុណ្ណោះ សព្វថ្ងៃវត្តឯកភ្នំបានក្លាយទៅជារមណីយដ្ឋានប្រវត្តិសាស្ត្រមួយដែលមានភ្ញៀវទេសចរជាច្រើននិយមទៅលេងកម្សាន្តពុំដែលខាន ព្រោះនៅទីនោះក៏មានប្រាសាទបុរាណមួយមានឈ្មោះថា ប្រាសាទឯកភ្នំ។

វត្តឯកភ្នំមិនត្រឹមជាកន្លែងកម្សាន្តប៉ុណ្ណោះទេថែមទាំងជារមណីយដ្ឋានដែលផ្សារភ្ជាប់នឹងប្រវត្តិសាស្ត្រ វប្បធម៌ពីបុរាណដែលជាស្នាដៃរបស់បុព្វបុរសបានកសាងទុកជាទីសក្ការៈ និងប្រកបដោយតម្លៃសាសនា។ ខ្ញុំស្រឡាញ់វត្តឯកភ្នំនេះណាស់រាល់ពេលមានពិធីបុណ្យទានផ្សេងៗខ្ញុំតែងទៅចូលរួមជាមួយគ្រួសារខ្ញុំនិងអ្នកភូមិពុំដែលខាន។

## អត្រាកំណែ

**អត្រាពិន្ទុតែងសេចក្ដីពណ៌នាអំពីទេសភាព**

អត្រាពិន្ទុពណ៌នាអំពីទេសភាពក៏ដូចជាតែងសេចក្ដីពណ៌នាពីទីកន្លែងឬព្រឹត្តិការណ៍ដែរ គឺមានអត្រាពិន្ទុ១០/១០។ លោកគ្រូ អ្នកគ្រូត្រូវណែនាំអំពីអត្រាពិន្ទុនៅក្នុសំណេររបស់សិស្សតាមរយៈគម្រោងតែងដូចខាងក្រោម៖

## គម្រោងតែង

**ក- សេចក្ដីផ្ដើម** (១,៥០ពិន្ទុ)
- បង្ហាញពីទេសភាពដោយប្រាប់: ឈ្មោះ ពេលវេលា (១,០០ពិន្ទុ)
- ទីកន្លែង: ដែលបានទៅឃើញ (០,៥០ពិន្ទុ)

**ខ- តួសេចក្ដី** (៦,០០ពិន្ទុ)
- ការរៀបរាប់ទេសភាពនិងទិដ្ឋភាព
- **ទិដ្ឋភាពពេលមើលពីចម្ងាយ**: សម្រស់ធម្មជាតិ ស្រែ ស្រូវ ទឹកក្នុងស្រែពន្លឺព្រះអាទិត្យប៉ះនិងស្លឹកស្រូវ ដើមត្នោតតាមភ្លឺស្រែ ពណ៌សន្ទូងឬវាលស្រែពេលស្រូវទុំ ដើមឈើ តូចធំ វត្ត ឬទីកម្សាន្ត (២,០០ពិន្ទុ)
- **ទិដ្ឋភាពពេលមកដល់ជិត**: គុម្ពសន្ទូង ស្រែទើបស្ទូង រុក្ខជាតិនានា(ស្មៅ កំពីងពួយ ដើមផ្ទក់ទឹក ដើម ប្រាច់ ស្លន់ ...) សត្វស្លាបក្នុងស្រែ (ចាប កុក ក្រសារ រនាល...) ក្នុងរដូវដកស្ទូងឬវាលស្រែពេលស្រូវទុំ ភ្ជួររាស់ ដកស្ទូង ច្រូតកាត់ ដាំដុះ ថែទាំ (២,០០ពិន្ទុ)
- ផលប្រយោជន៍:ទេសភាពនិងទិដ្ឋភាពដែលបានរៀបរាប់... (២,០០ពិន្ទុ)

**គ- សេចក្ដីបញ្ចប់** (១,០០ពិន្ទុ)
- ការវាយតម្លៃ: ទេសភាពនិងទិដ្ឋភាពដែលបានរៀបរាប់ (០,៥០ពិន្ទុ)
- ចំណាប់អារម្មណ៍: ការសម្ដែងមនោសញ្ចេតនារបស់អ្នកចំពោះទេសភាព (០,៥០ពិន្ទុ)

**រចនាបថ**: អក្សរស្អាត សរសេរមានរបៀប មានឃ្លាល្បះត្រឹមត្រូវ និងគ្មានកំហុសអក្ខរាវិរុទ្ធ (១,០០ពិន្ទុ)

## ៧.៦- ប្រធានពណ៌នាអំពីទីកន្លែង

តែងសេចក្ដីពណ៌នាអំពីទីកន្លែងមានបំណងឱ្យអ្នកសរសេរចេះរៀបរាប់ទីកន្លែងណាមួយដែលខ្លួនបានស្គាល់ហើយលើកយកមករៀបរាប់ឡើងវិញបានច្បាស់លាស់។ នៅក្នុងសេចក្ដីផ្ដើមតម្រូវឱ្យអ្នកសរសេរប្រាប់ឱ្យបានច្បាស់អំពីពេលវេលានិងឈ្មោះទីកន្លែងដែលត្រូវរៀបរាប់។ នៅតួសេចក្ដីតម្រូវឱ្យបង្ហាញពីទិដ្ឋភាពរួមនិងទិដ្ឋភាពខាងក្នុងដែលបានទៅឃើញផ្ទាល់សកម្មភាពផ្សេងៗរបស់មនុស្ស ព្រមទាំងសកម្មភាពនិងអ្នកទៅទស្សនានៅទីនោះ។ ចំណែកនៅក្នុងបញ្ចប់សេចក្ដី អ្នកសរសេរត្រូវសម្ដែងពីអារម្មណ៍ឬមនោសញ្ចេតនារបស់ខ្លួនចំពោះទីកន្លែងនោះ សរុបទៅនឹងគំនិតប្រធានដែលបានលើកឡើង។

៧.៦.១- **ឧទាហរណ៍ទី១** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីសារមន្ទីរជាតិដែលប្អូនបានទៅទស្សនា។

## គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- ពេលវេលា
- ឈ្មោះទីកន្លែង។

**ខ- តួសេចក្ដី**

- ទិដ្ឋភាពខាងក្រៅ: បង្ហាញពីលក្ខណៈទូទៅនៃសារមន្ទីរ
- ទិដ្ឋភាពខាងក្នុង: រៀបរាប់ពីអ្វីដែលមើលឃើញនៅទីនោះមានដូចជាការដាក់តាំងវត្ថុមានតម្លៃនានារបស់ជាតិ
- ផលប្រយោជន៍: កន្លែងដែលបានឃើញឬទៅទស្សនាជាទុកដាក់វត្ថុបុរាណរបស់ប្រទេសគ្រប់សម័យកាលតាមលំដាប់ជាប្រវត្តិសាស្ត្រ។

**គ- សេចក្ដីបញ្ចប់**

- ការវាយតម្លៃ : សារមន្ទីរជាតិជាកេរដំណែលដែលបុព្វបុរសខ្មែរបានបង្កើតឡើងដើម្បីទុកឱ្យកូនខ្មែរគ្រប់ជំនាន់បានដឹង បានស្គាល់នូវសម្បត្តិវប្បធម៌របស់ប្រទេសខ្លួនឯង
- ចំណាប់អារម្មណ៍: ការបង្ហាញមនោសញ្ចេតនាគោរពនិងកោតសរសើរដល់ស្នាដៃបុព្វបុរសខ្មែរ ដែលបង្កើតសារមន្ទីរជាតិដើម្បីអភិរក្សសម្បត្តិវប្បធម៌និងអត្តសញ្ញាណជាតិ។

## សេចក្ដីពណ៌នា

កាលពីថ្ងៃអាទិត្យមុន ខ្ញុំបានទៅទស្សនាសារមន្ទីរជាតិនៅរាជធានីភ្នំពេញជាមួយឪពុកម្ដាយខ្ញុំ។

សារមន្ទីរជាតិមានទីតាំងស្ថិតនៅទិសខាងជើងព្រះបរមរាជវាំងនៃរាជធានីភ្នំពេញ។ សារមន្ទីរនេះជាកន្លែងប្រមូលផ្ដុំនិងដាក់តាំងវត្ថុបុរាណដ៏មានតម្លៃរបស់ជាតិ។ នៅក្នុងសារមន្ទីរនេះមានដាក់បង្ហាញវត្ថុបុរាណដូចជារូបចម្លាក់បុព្វបុរសជំនាន់ដើម ព្រះពុទ្ធរូប បដិមាតំណាងទេវៈផ្សេងៗនៅក្នុងសាសនា ដែលជនជាតិខ្មែរចាត់ទុកជាទីគោរព។ ពិសេសមានដាក់តាំងសម្ភារៈប្រើប្រាស់របស់មនុស្សសម័យមុនដែលមានអាយុកាលច្រើនឆ្នាំដូចជាដាវ លំពែង កាំបិត ក្អម ឆ្នាំង គោកនិងគ្រឿងអលង្ការធ្វើពីមាស ប្រាក់ សំរិទ្ធ លង្ហិន ស្ពាន់ជាដើម។នៅតាមជ្រុងខ្លះ មានដាក់តាំង និងរក្សាទុកឈុតសម្លៀកបំពាក់របាំ ផ្ទះបុរាណ ទូក គ្រែស្នែង របស់ស្ដេច និងវត្ថុបុរាណជាច្រើនទៀតដាក់តម្រៀបតាំងក្នុងទូដោយមានរបៀបរៀបរយ។ ទន្ទឹមនេះខ្ញុំក៏ឃើញមានភ្ញៀវទេសចរជាតិនិងអន្តរជាតិបានចូលទស្សនាយ៉ាងច្រើនកុះករ។ សារមន្ទីរជាតិដែលខ្ញុំបានទៅទស្សនានេះឃើញថា ពិតជាកន្លែងទុកដាក់វត្ថុបុរាណដ៏មានតម្លៃរបស់ប្រទេសគ្រប់សម័យកាលតាមលំដាប់ជា ប្រវត្តិសាស្ត្រគួរឱ្យចាប់អារម្មណ៍បំផុត។

ខ្ញុំមានការចាប់អារម្មណ៍និងកោតសរសើរដល់បុព្វបុរសខ្មែរ ដែលមានគំនិតបង្កើតសារមន្ទីរនេះឡើង ដែលជាឃ្លាំងផ្ទុកមរតកវប្បធម៌ដ៏មានតម្លៃរបស់ជាតិ។ ខ្ញុំសប្បាយចិត្តណាស់ដែលបានទៅទស្សនាសារមន្ទីរជាតិ ព្រោះទីនោះសម្បូរវត្ថុបុរាណរបស់ខ្មែរយើង ព្រមទាំងធ្វើឱ្យយើងបានរៀនសូត្រអំពីប្រវត្តិសាស្ត្ររបស់ជនជាតិខ្មែរយើងក្នុងអតីតកាលផង។ យើងនឹងរួមគ្នាការពារនិងអភិរក្សសម្បត្តិវប្បធម៌ជាតិខ្មែរឱ្យបានគង់វង្ស។

### ៧.៦.២- ឧទាហរណ៍ទី២ (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនរៀបរាប់អំពីរមណីយដ្ឋានគិរីរម្យដែលបានទៅកម្សាន្តកាលពីថ្ងៃអាទិត្យមួយ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ពេលវេលាទៅកម្សាន្ត
- ទីកន្លែងឬទីតាំង: ឈ្មោះ នៅភូមិ ឃុំ ស្រុក ខេត្ត។

**ខ- តួសេចក្តី**

- ទិដ្ឋភាពមើលពីចម្ងាយ: ទេសភាពភ្នំ ដើមឈើ វាលស្រែ ចម្ការដំណាំ
- ទិដ្ឋភាពពេលចូលទៅជិត: ទេសភាពធម្មជាតិ ព្រៃព្រឹក្សា លតាវល្លិ ជ្រោះជ្រលងដងអូរ កន្លែងអង្គុយកម្សាន្ត ដំណាក់ចាស់ ឧទ្យានជាតិគិរីរម្យជាទីរមណីយដ្ឋាន
- ផលប្រយោជន៍: ជាកន្លែងកម្សាន្ត ទេសចរណ៍។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: រមណីយដ្ឋានគិរីរម្យជាកន្លែងទាក់ទាញទេសចរណ៍និងជារមណីយដ្ឋានប្រវត្តិសាស្ត្រ
- ចំណាប់អារម្មណ៍: បង្ហាញពីមនោសញ្ចេតនាឬចំណាប់អារម្មណ៍ចំពោះទីកន្លែងដែលបានឃើញ និងធ្វើឱ្យយើងចង់ទៅកម្សាន្តម្តងហើយម្តងទៀត។

## សេចក្តីពណ៌នា

កាលពីថ្ងៃអាទិត្យមុន ខ្ញុំនិងគ្រួសារខ្ញុំបានទៅកម្សាន្តនៅរមណីយដ្ឋានគិរីរម្យដែលស្ថិតនៅក្នុងភូមិត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

បើយើងធ្វើដំណើរតាមផ្លូវជាតិលេខបួន ហួសពីទីរួមខេត្តកំពង់ស្ពឺប្រមាណជាងសាមសិបគីឡូម៉ែត្រយើងនឹងឃើញជួរភ្នំមួយលាតសន្ធឹងយ៉ាងវែងនៅខាងស្តាំដៃនោះគឺជាជួរភ្នំគិរីរម្យ។ កាលណាយើងធ្វើដំណើរដល់ផ្សារត្រែងត្រយឹង យើងនឹងឃើញផ្លូវមួយនៅខាងស្តាំដៃចុះពីផ្លូវជាតិលេខបួនឆ្ពោះទៅកាន់រមណីយដ្ឋានគិរីរម្យ។ នៅអមសងខាងផ្លូវចូលរមណីយដ្ឋានមានចម្ការចេក ខ្នុរ ស្វាយ ផ្ទៀវ ក្រូចត្លុង បំពេញរាជជាច្រើន។ នៅពេលឆ្លងកាត់ខ្នងភ្នំឆ្ពោះទៅរមណីយដ្ឋាន ខ្ញុំឃើញព្រៃព្រឹក្សា លតាវល្លិ ជ្រោះជ្រលងភ្នំ ដំណាក់ចាស់ដែលសាងសង់ពីសម័យសង្គមរាស្ត្រនិយម។ មិនយូរប៉ុន្មានខ្ញុំក៏មកដល់ក្នុងបរិវេណឧទ្យានជាតិគិរីរម្យ។ ពេលចុះពីរថយន្តមកដល់រមណីយដ្ឋាននេះភ្លាមខ្ញុំទទួលអារម្មណ៍នឹងខ្យល់អាកាសដ៏ត្រជាក់ដែលបក់ផាត់ពីព្រៃឈើតូចធំ ពិសេសជំនោរបក់ពីចម្ការស្រល់។ នៅជុំវិញនេះ ខ្ញុំក៏ឃើញដើមស្រល់តូច ធំ ខ្ពស់ ទាបជាច្រើនដុះរៀងគ្នារត់ជួររមេញយ៉ាងខៀវស្រងាត់។ មិនតែប៉ុណ្ណោះមានវត្តយ៉ាងល្អប្រណីតសម្រាប់ពុទ្ធសាសនិកជនប្រារព្ធពិធីបុណ្យតាមប្រពៃណីពុទ្ធសាសនាទៀតផង។ នៅរមណីយដ្ឋានមានជ្រោះនិងមនុស្សជាច្រើនកំពុងងូតទឹកកម្សាន្ត។ នៅជិតជ្រោះនេះ មានកន្លែងលក់ម្ហូបអាហារ នំចំណី និងវត្ថុអនុស្សាវរីយ៍នានា។ លើសពីនេះទៀតខ្ញុំឃើញភ្ញៀវទេសចរណ៍ជាច្រើនបានមកកម្សាន្តនៅរមណីយដ្ឋានជាតិគិរីរម្យដូចគ្រួសារខ្ញុំដែរ ព្រោះទីនេះជាកន្លែងទេសចរណ៍ដ៏ល្អនិងមានភាពទាក់ទាញ។

រមណីយដ្ឋានគិរីរម្យដែលខ្ញុំបានទៅកម្សាន្តនេះមិនត្រឹមតែជាកន្លែងកម្សាន្តធម្មតាទេ វាគឺជាឧទ្យានជាតិសម្រាប់ភ្ញៀវទេសចរជាតិនិងអន្តរជាតិដែលទទួលស្គាល់ថាពិតជាល្អដាច់គេ គួរចង់ទៅកម្សាន្តក្រៃលែង។ ខ្ញុំមានអារម្មណ៍ជិតជាប់នឹងទេសភាពដ៏ស្រស់ត្រកាលនេះ។ ខ្ញុំមានអារម្មណ៍ធូរស្រាលសប្បាយរីករាយរាល់ពេលមកកម្សាន្តទីនេះម្តងៗ ហើយនៅចងចាំ អនុស្សាវរីយ៍នេះជានិច្ច។

**៧.៦.៣- ឧទាហរណ៍ទី៣** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនរៀបរាប់អំពីទិដ្ឋភាពវត្តមួយដែលអ្នកបានទៅឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**១- សេចក្តីផ្តើម**

- ឈ្មោះ
- ទីតាំងវត្ត។

**២- តួសេចក្តី**

- ទិដ្ឋភាពមើលពីឆ្ងាយ: ព្រះវិហារ ដើមឈើតូចធំ
- ទិដ្ឋភាពពេលចូលជិត: ព្រះវិហារ កុដិ សាលាធម្មសភា របងវត្ត ខ្លោងទ្វារ រូបចម្លាក់ គំនូរ សភាពអ៊ូអរពេលបុណ្យទាននិងបរិយាកាស
- ផលប្រយោជន៍: ជាកន្លែងប្រារព្ធពិធីបុណ្យជាទីសក្ការៈ។

**៣- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ទិដ្ឋភាពវត្តដែលបានរៀបរាប់ពិតជាគួរឱ្យសប្បាយរីករាយចង់ទៅកម្សាន្ត
- ចំណាប់អារម្មណ៍: ការសម្តែងមនោសញ្ចេតនាផ្ទាល់ខ្លួនចំពោះទីកន្លែងនោះ។

## សេចក្តីពណ៌នា

កាលពីថ្ងៃបុណ្យភ្ជុំបិណ្ឌកន្លងទៅនេះ ខ្ញុំនិងឪពុកម្តាយខ្ញុំបានយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្តមួយឈ្មោះវត្តសមិទ្ធិមុនីសោភ័ណស្ថិតនៅក្នុងភូមិស្វភី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

បើគេធ្វើដំណើរតាមផ្លូវលេខហាសិបប្រាំមួយ «អា» ហួសផ្សារចម្ការចេកប្រហែលពីររយម៉ែត្របត់ស្តាំរួចធ្វើដំណើរទៅទិសខាងកើតតាមផ្លូវក្រាលក្រួសក្រហមមួយ គេនឹងឃើញកំពូលព្រះវិហារខ្ពស់ត្រដែតផុតចុងព្រឹក្សានានា។ បន្តិចក្រោយមក គេនឹងទៅដល់ខ្លោងទ្វារមួយធ្វើអំពីឥដ្ឋ មានផ្លាក់អក្សរធំៗនៅពីលើថា«វត្តសមិទ្ធិមុនីសោភ័ណ» អមដោយចម្លាក់តាមរចនាបថខ្មែរយ៉ាងល្អប្រណីត។ នៅជាប់នឹងខ្លោងទ្វារសងខាងមានរបងឥដ្ឋកម្ពស់ពីរម៉ែត្រ ព័ទ្ធជុំវិញទីវត្តនេះ។ នៅតាមជញ្ជាំងរបងនេះមានផ្លាក់ឈ្មោះសប្បុរសជននិងពុទ្ធបរិស័ទជាច្រើននាក់ដែលបានចូលរួមបច្ច័យកសាងរបងវត្ត។ ពេលចូលទៅខាងក្នុង គេឃើញព្រះវិហារមួយដែលទើបនឹងសង់រួច រំលេចដោយក្បាច់ចម្លាក់និងរូបគំនូរបង្ហាញពីពុទ្ធប្រវត្តិនិងរូបគំនូរបង្ហាញពីកម្មផលនៃអ្នកធ្វើអំពើអាក្រក់ជាច្រើនផ្ទាំង។ ក្រៅពីព្រះវិហារ គេឃើញកុដិព្រះសង្ឃ ដូនជី តាជី សង់យ៉ាងមានរបៀបរៀបរយ និងសាលាធម្មសភាមួយសង់ខ្ពស់ផុតពីដី។ ចំណែកក្នុងទីធ្លាវិញមានរូបចម្លាក់ព្រះពុទ្ធចូលបរិនិព្វាននិងរូបចម្លាក់ព្រះពុទ្ធប្រទានប្រាំអង្គព្រមទាំងដើមឈើធំៗជាច្រើនបែកមែកសាខាចោលម្លប់ត្រឈឹងត្រឈៃ ដែលធ្វើឱ្យ

ធាតុអាកាសទីនោះត្រជាក់ស្រួល។ នៅពេលមានបុណ្យទាននិងថ្ងៃសីល ទីអារាមមួយនេះមានសភាពអ៊ូអរខុសប្លែកពីធម្មតា។

វត្តសមិទ្ធិមុនីសោភ័ណជាវត្តមានអាយុកាលច្រើនឆ្នាំ ក្លាយជាវត្តចាស់បុរាណដែលប្រជាជននៅទីនោះតែងទៅធ្វើបុណ្យទានជួយកសាងជួសជុលបន្ថែមនិងអភិរក្សទុកជាសម្បត្តិសាសនារបស់ខេត្ត។ ពេលត្រឡប់មកពីវត្តវិញ ខ្ញុំមានអារម្មណ៍ជ្រះថ្លាស្រស់ស្រាយ ដោយខ្ញុំបានទៅធ្វើបុណ្យកសាងកុសលដែលជាអំពើល្អជួយឱ្យក្រុមគ្រួសារខ្ញុំមានសេចក្តីសុខ។ យើងត្រូវចូលរួមថែរក្សាការពារវត្តអារាមជាទីសក្ការៈនិងជាជាតិដ៏ល្អផូរផង់។

**៧.៦.៤- ឧទាហរណ៍ទី៤** (ថ្នាក់ ទី៥ និងទី៦)

លំហាត់សម្រាប់សិស្សអនុវត្តដោយហ្វឹកហាត់ ធ្វើសេចក្តីអធិប្បាយតាមគម្រោងដូចខាងក្រោម។

---

**ប្រធាន**: ចូរប្អូនពណ៌នាអំពីសាលារៀន។

---

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ឈ្មោះសាលារៀន
- ទីតាំងសាលារៀន។

**ខ- តួសេចក្តី**

- ទិដ្ឋភាពសាលារៀនមើលពីចម្ងាយ: អគារ ដងទង់ជាតិ ដើមឈើ
- ទិដ្ឋភាពសាលារៀនពេលចូលជិត: ខ្លោងទ្វារ អគារសិក្សា បន្ទប់រៀន ទីចាត់ការ សួន ច្បារ តារាង បាល់ សួនបន្លែ បរិវេណជុំវិញសាលា ទីធ្លា ដើមឈើមានម្លប់ សួនជីវៈចម្រុះ
- ផលប្រយោជន៍: ជាកន្លែងបណ្តុះបណ្តាលចំណេះដឹងនិងអភិវឌ្ឍធនធានមនុស្ស។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: សាលារៀនជាថ្នាលបណ្តុះចំណេះដឹងនិងធនធានមនុស្សសម្រាប់អភិវឌ្ឍប្រទេស
- ចំណាប់អារម្មណ៍: បង្ហាញអារម្មណ៍ស្រឡាញ់សាលារៀន ខិតខំរៀនសូត្រ ចូលរួមថែរក្សាបរិស្ថានសាលារៀន មិនចោលសំរាមផ្តេសផ្តាស ថែរក្សាទ្រព្យសម្បត្តិសាលារៀន និងមិនបំផ្លិចបំផ្លាញ...។

## អត្រាកំណែ

### អត្រាពិន្ទុតែងសេចក្តីពណ៌នាអំពីទីកន្លែង

តែងសេចក្តីពណ៌នាអំពីទីកន្លែងក៏មានអត្រាពិន្ទុ១០/១០ដែរ។ ក្រោយពីបញ្ចប់ការសិក្សាតែងសេចក្តី និងផ្តល់ឧទាហរណ៍ រួចសិស្សឆ្លើយនឹងសំណួរដើម្បីពង្រីកការយល់ដឹងលើខ្លឹមសារតាមផ្នែកនីមួយៗ។ លោកគ្រូ អ្នកគ្រូនឹងបង្រៀនពីគម្រោងតែងសេចក្តីថែមទៀត។ នៅក្នុងគម្រោងតែងលោក គ្រូអ្នកគ្រូត្រូវតែពន្យល់សិស្សឱ្យច្បាស់លាស់ អំពីខ្លឹមសារសំខាន់ៗដែលសិស្សត្រូវសរសេររៀបចំតាក់តែងឱ្យបានពីរោះ ក្បោះក្បាយ និងមានខ្លឹមសារសមស្របតាមប្រធានដែល

បានលើកឡើង។ ពិសេសគ្រូត្រូវណែនាំពីចំណុចដែលត្រូវបានពិន្ទុតាមផ្នែកនីមួយៗនៅក្នុងគម្រោង ដើម្បីឱ្យសិស្សយល់ហើយខំសរសេរឱ្យបានពិន្ទុខ្ពស់ ហើយគ្រូក៏ត្រូវ មានការលើកទឹកចិត្ត ឬជំរុញសិស្សឱ្យសរសេរបានរហូតដល់ចប់ផងដែរ។

ដូច្នេះ ក្នុងគម្រោងតែងគ្រូត្រូវកំណត់នូវអត្រាពិន្ទុឱ្យច្បាស់លាស់តាមលំនាំដូចខាងក្រោម។

## គម្រោងតែង

**ក- សេចក្តីផ្តើម** (១,៥០ពិន្ទុ)

- ពេលវេលា (១,០០ពិន្ទុ)
- ទីកន្លែងដែលរៀបរាប់ និងឈ្មោះ (០,៥០ពិន្ទុ)

**ខ- តួសេចក្តី** (៦,០០ពិន្ទុ)

- ទិដ្ឋភាពមើលពីចម្ងាយៈ វត្ត សាលារៀន រមណីយដ្ឋាន សារមន្ទីរ (២,០០ពិន្ទុ)
- ទិដ្ឋភាពមើលពេលចូលជិតៈ រៀបរាប់ពីអ្វីដែលបានឃើញនៅទីនោះដូចជាទេសភាព ធម្មជាតិ ផ្ទះ អគារ បន្ទប់រៀន កន្លែងដាក់តាំងវត្ថុ ព្រមទាំងសកម្មភាពផ្សេងៗ (២,០០ពិន្ទុ)
- ផលប្រយោជន៍ៈ ជាកន្លែងកម្សាន្ត ទីសក្ការៈ ប្រារព្ធពិធីបុណ្យទាន រមណីយដ្ឋានប្រវត្តិសាស្ត្រ ជាកន្លែងផ្តល់ចំណេះដឹងនិងអភិវឌ្ឍធនធានមនុស្ស (២,០០ពិន្ទុ)

**គ- សេចក្តីបញ្ចប់** (១,៥០ពិន្ទុ)

- ការវាយតម្លៃៈទីកន្លែងដែលបានឃើញ ទស្សនា (១,០០ពិន្ទុ)
- ចំណាប់អារម្មណ៍ៈ ការសម្តែងមនោសញ្ចេតនា ស្រឡាញ់ពេញចិត្ត ខិតខំថែរក្សា អភិរក្ស (០,៥០ពិន្ទុ)

**រចនាបថៈ** អក្សរស្អាត សរសេរមានរបៀប មានឃ្លាល្បះត្រឹមត្រូវ និងគ្មានកំហុសអក្ខរាវិរុទ្ធ (១,០០ពិន្ទុ)

## ៧.៧- ប្រធានពណ៌នាអំពីព្រឹត្តិការណ៍

តែងសេចក្តីពណ៌នាអំពីព្រឹត្តិការណ៍តម្រូវឱ្យអ្នកសរសេររៀបរាប់អំពីដំណើររឿងរ៉ាវឬហេតុការណ៍ផ្សេងៗនៅក្នុងព្រឹត្តិការណ៍ឬពិធីណាមួយដែលប្រធានបានកំណត់ដូចជានៅសេចក្តីផ្តើមតម្រូវឱ្យអ្នកសរសេរបង្ហាញរៀបរាប់ពីពេលវេលា ទីកន្លែងនិងឈ្មោះព្រឹត្តិការណ៍ ឬពិធីណាមួយឱ្យបានត្រឹមត្រូវច្បាស់លាស់។ ចំណែកនៅតួសេចក្តីវិញ តម្រូវឱ្យអ្នកសរសេររៀបរាប់ពីសកម្មភាពមុនកើតហេតុ ពេលកំពុងកើតហេតុ ក្រោយពេលកើតហេតុ និងផលប៉ះពាល់។ ឧទាហរណ៍ ព្រឹត្តិការណ៍គ្រោះថ្នាក់ចរាចរណ៍ គ្រោះទឹកជំនន់ក្នុងភូមិ។ល។ឬក៏រៀបរាប់ពីសកម្មភាពមុនចាប់ផ្តើមពិធី ពេលពិធីកំពុងប្រព្រឹត្តទៅ និងក្រោយការបញ្ចប់ពិធី។ ឧទាហរណ៍ពិធីប្រកួតកីឡា ពិធីបុណ្យអុំទូក ពិធីបុណ្យចូលឆ្នាំខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌជាដើមមានការរៀបរាប់ទៅតាមលំណែនាំសរសេរពណ៌នាពីព្រឹត្តិការណ៍ឬពិធីនានាបានល្អក្បោះក្បាយ។ នៅសេចក្តីបញ្ចប់តម្រូវឱ្យអ្នកសរសេរបង្ហាញពីការវាយតម្លៃនិងចំណាប់អារម្មណ៍របស់ខ្លួនចំពោះព្រឹត្តិការណ៍ ឬពិធីណាមួយដែលបានរៀបរាប់រួចមកហើយប្រកបដោយអត្ថន័យ ខ្លឹមសារជ្រាលជ្រៅនិងមិនចាកប្រធាន។

ខាងក្រោមនេះជាគម្រោងនិងឧទាហរណ៍បញ្ជាក់លើប្រធានបទពណ៌នាអំពីព្រឹត្តិការណ៍ៈ

## គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- ពេលវេលា
- ទីកន្លែងនិងឈ្មោះព្រឹត្តិការណ៍។

**ខ- តួសេចក្ដី**

- មុនពេលកើតហេតុ៖ សកម្មភាពមនុស្សមុនពេលកើតហេតុ: ឃើញទិដ្ឋភាពមនុស្សនិងសកម្មភាពផ្សេងៗ
- ពេលកើតហេតុ៖
  - ✓ ព្រឹត្តិការណ៍ចាប់ផ្ដើមកើតឡើង: ហេតុដែលនាំឱ្យមានព្រឹត្តិការណ៍កើតឡើង
  - ✓ ព្រឹត្តិការណ៍កំពុងកើតឡើង: រៀបរាប់ព្រឹត្តិការណ៍ដែលប្រព្រឹត្តទៅ
- ក្រោយពេលកើតហេតុ: រៀបរាប់ពីអ្វីដែលកើតឡើងក្រោយពេលកើតហេតុ។

**គ- សេចក្ដីបញ្ចប់**

- ការវាយតម្លៃ: រៀបរាប់ពីការវាយតម្លៃលើព្រឹត្តិការណ៍នីមួយៗដែលកើតឡើង
- ចំណាប់អារម្មណ៍: បង្ហាញពីការចាប់អារម្មណ៍ចំពោះព្រឹត្តិការណ៍ដែលកើតឡើង គួរឱ្យសោកស្ដាយ មិនចង់ឱ្យកើតឡើង ត្រូវប្រុងប្រយ័ត្នដើម្បីចៀសវាងគ្រោះថ្នាក់។

**៧.៧.១- ឧទាហរណ៍ទី១** (ថ្នាក់ទី៣ ទី៤ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីគ្រោះថ្នាក់ចរាចរណ៍ដែលប្អូនបានឃើញ។

## គម្រោងតែង

កាលពីថ្ងៃអាទិត្យមុន ខ្ញុំបានឃើញគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើងត្រង់ចំណុចផ្លូវកោងក្បែរសាលារៀនខ្ញុំ។

មុនពេលកើតហេតុ មានភ្លៀងធ្លាក់យ៉ាងខ្លាំងហើយមានអ្នកដំណើរកំពុងធ្វើដំណើរស្រូតរូតទៅតាមគោលដៅរៀងខ្លួន។ ខ្ញុំកំពុងឈរនៅពីមុខសាលារៀនរង់ចាំឪពុកខ្ញុំមកទទួលទៅផ្ទះ។ ពេលនោះស្រាប់តែមាន បុរសម្នាក់បានបើកម៉ូតូតាមបណ្ដោយផ្លូវមុខសាលារៀនខ្ញុំក្នុងល្បឿនយ៉ាងលឿន។ លុះទៅដល់ចំណុច ផ្លូវកោងហើយរអិលផង ម៉ូតូក៏បានជ្រុលចង្កូតធ្លាក់ពីលើចិញ្ចើមផ្លូវទៅបុកនឹងដើមឈើមួយដើមដែលដុះ ប្របផ្លូវ ឮសូរដូចរន្ទះ។ សំឡេងប៉ះទង្គិចធ្វើឱ្យអ្នករស់នៅក្បែរនោះ រួមទាំងអ្នកដំណើរបានស្ទុះមកជួយ ទាំងភ្ញីរន្ធត់ និង អាណិតអាសូរក្រៃលែង។ សភាពពេលនោះមានអ្នកខ្លះជួយទូរស័ព្ទហៅប៉ូលីសចរាចរណ៍ អ្នកខ្លះហៅរថយន្តសង្គ្រោះឱ្យមកជួយសង្គ្រោះជនរងគ្រោះជាបន្ទាន់។ ក្រោយពេលកើតហេតុ ម៉ូតូត្រូវខូចខាតយ៉ាងដំណំ។ រីឯអ្នកបើកបរវិញរងរបួសធ្ងន់ សន្លប់ស្ដូកស្ដឹង។ គ្រោះថ្នាក់នេះបណ្ដាលមកពីអ្នកធ្វើដំណើរនោះបើកបរលឿន ក្នុងស្ថានភាពគ្រោះថ្នាក់ដោយខ្វះការប្រុងប្រយ័ត្ន។ មួយសន្ទុះក្រោយមក កម្លាំងសមត្ថកិច្ចក៏បានមកជួយធ្វើអន្តរាគមន៍ហើយរថយន្តសង្គ្រោះក៏មកដល់ រួចលើកអ្នករបួសដាក់ក្នុងរថយន្តទៅកាន់មន្ទីរពេទ្យ។

ព្រឹត្តិការណ៍គ្រោះថ្នាក់ចរាចរណ៍នេះធ្វើឱ្យខ្ញុំមានអារម្មណ៍ក្ដុកក្ដួល អាណិត សោកស្ដាយដល់ជនរងគ្រោះដែលទទួលរងការខូចខាតទ្រព្យរបស់និងរបួសស្នាម។ ដូច្នេះ យើងគ្រប់គ្នាត្រូវគោរព

ច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួនគ្រប់ពេលធ្វើដំណើរទោះជិតឬឆ្ងាយ។ អ្នកធ្វើដំណើរត្រូវបើកបរដោយមានការប្រុងប្រយ័ត្នមិនបើកបរលឿនហួសការកំណត់ មិនសេពគ្រឿងស្រវឹង ដើម្បីចៀសផុតពីគ្រោះថ្នាក់ហើយធ្វើដំណើរប្រកបដោយសុខសុវត្ថិភាព។

**៧.៧.២- ឧទាហរណ៍ទី២** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនពណ៌នាអំពីព្រឹត្តិការណ៍គ្រោះទឹកជំនន់នៅក្នុងភូមិមួយ។

## គម្រោងតែង

**ក- សេចក្ដីផ្ដើម**

- ពេលវេលា
- ទីកន្លែង: ភូមិ និងឈ្មោះព្រឹត្តិការណ៍ទឹកជំនន់។

**ខ- តួសេចក្ដី**

- មុនពេលកើតហេតុ: ភ្លៀងច្រើនមេ ជាប់ៗគ្នាជាច្រើនថ្ងៃ
- ពេលកើតហេតុ: ទឹកឡើងខ្លាំង លិចវាលស្រែ និងផ្ទះសម្បែង សកម្មភាពមនុស្ស សត្វ នៅតាមទីកន្លែងផ្សេងៗក្នុងភូមិ
- ក្រោយពេលកើតហេតុ: មានប៉ះពាល់និងខូចខាតទ្រព្យសម្បត្តិ ផ្ទះសម្បែង ផលដំណាំ ហេដ្ឋារចនា សម្ព័ន្ធផ្លូវ ស្ពាន និងសមិទ្ធផលផ្សេងៗ ព្រមទាំងសកម្មភាពចុះជួយអន្តរាគមន៍។

**គ- សេចក្ដីបញ្ចប់**

- ការវាយតម្លៃ: ព្រឹត្តិការគ្រោះទឹកជំនន់បង្កផលប៉ះពាល់ច្រើនដល់ជីវភាពរស់នៅរបស់ប្រជាជន
- ចំណាប់អារម្មណ៍: បង្ហាញអារម្មណ៍សោកស្ដាយចំពោះព្រឹត្តិការណ៍ដែលបានកើតឡើង។

## សេចក្ដីពណ៌នា

កាលពីប៉ុន្មានខែមុន នៅភូមិខ្ញុំមានព្រឹត្តិការណ៍ទឹកជំនន់មួយកើតឡើង។

ខ្ញុំនៅចាំបានថា មុនពេលកើតហេតុ ខ្ញុំឃើញមានភ្លៀងធ្លាក់ជាច្រើនមេនិងច្រើនថ្ងៃជាប់ៗគ្នាធ្វើឱ្យទឹកកើនឡើងពេញភូមិ។ បន្ទាប់មកខ្ញុំក៏បានឃើញទឹកចាប់ផ្ដើមលិចរហូតដល់វាលស្រែក្រោយភូមិ ហើយពេលនោះទឹកហូរលឿនខ្លាំងឡើងៗរហូតធ្វើឱ្យលិចផ្ទះប្រជាពលរដ្ឋមួយចំនួនថែមទៀត។ នៅពេលនោះអ្នកភូមិបាននាំគ្នារៀបចំទុកដាក់ស្បៀងអាហារហើយជន្លៀសកូនចៅ ព្រមទាំងសត្វពាហនៈទៅរកទីទួលសុវត្ថិភាពនៅវត្តក្បែរភូមិ។ ម្យ៉ាងវិញទៀតខ្ញុំក៏បានឃើញអាជ្ញាធរជាច្រើននាក់ហើយនាំកម្លាំងជំនាញមកចុះជួយដឹកជម្លៀសប្រជាជននិងសត្វពាហនៈទាន់ពេលវេលា។ ព្រឹត្តិការណ៍គ្រោះទឹកជំនន់នេះគឺជាគ្រោះមហន្តរាយដ៏អាក្រក់ដែលបានបំផ្លិចបំផ្លាញផ្ទះសម្បែងក្នុងភូមិខ្ញុំអស់ចំនួនបួនខ្នង ខូចខាតផលដំណាំនិងបន្លែបង្ការផ្សេងៗជាច្រើន។ សាលារៀនលិចទឹកនាំឱ្យសិស្សខកខានទៅរៀនអស់ពីរសប្ដាហ៍។ ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន ទំនប់លិចទឹកពិបាកធ្វើដំណើរឆ្លងកាត់។ នៅពេលនោះមានខាងកាកបាទក្រហម សប្បុរសជន និងស្ថាប័ន ពាក់ព័ន្ធ បានឧបត្ថម្ភជាស្បៀងអាហារ សម្ភារៈ ថវិកា ឱសថ និងគ្រាប់ពូជមួយចំនួន ដើម្បីជួយកាត់បន្ថយការលំបាករបស់ប្រជាពលរដ្ឋក្នុងភូមិខ្ញុំបានមួយកម្រិត។

គ្រោះមហន្តរាយទឹកជំនន់ជាគ្រោះមហន្តរាយធម្មជាតិមិនអាចឃាត់ឃាំងបានទេ។ ដូច្នេះខ្ញុំមានការ សោកស្តាយយ៉ាងខ្លាំងចំពោះព្រឹត្តិការណ៍នេះ។ ដូច្នេះយើងត្រូវមានផែនការត្រៀមបម្រុងឆ្លើយតបនឹងគ្រោះ អាសន្ន និងមានការប្រុងប្រយ័ត្នខ្ពស់នៅពេលមានគ្រោះទឹកជំនន់ ។

**៧.៧.៣- ឧទាហរណ៍ទី៣** (ថ្នាក់ទី៥ និងទី៦)

លំហាត់សម្រាប់សិស្សអនុវត្តដោយហ្វឹកហាត់ធ្វើសេចក្តីអធិប្បាយតាមគម្រោងដូចខាងក្រោម។

**ប្រធាន**: ចូរប្អូនពណ៌នាអំពីទឹកភ្លៀងដែលប្អូនបានឃើញឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- ពេលវេលា: ព្រឹក រសៀល
- ទីកន្លែង: នៅក្នុងភូមិ ឬនៅវាលស្រែ។

**ខ- តួសេចក្តី**

- មុនពេលភ្លៀង: ផ្ទៃមេឃពណ៌ខ្មៅ ខ្យល់បក់ ពពករសាត់ខ្មៅខ្ចួលខ្មាញ់ មនុស្សធ្វើដំណើរទៅទីជម្រកសត្វស្លាបហើរឆ្វាត់ឆ្វែងរកទ្រនំ សត្វទ្វេបាទ ចតុប្បាទរត់រកជម្រក...
- ពេលភ្លៀង: តំណក់ទឹកភ្លៀង បង្អុរមកដំបូងតិច បន្ទាប់មកកាន់តែខ្លាំង សកម្មភាពក្មេងៗរត់លេងទឹកភ្លៀងមុខផ្ទះ ចាស់ៗខ្លះនាំគ្នាត្រងទឹកភ្លៀង ខ្លះកាយប្រឡាយទឹកបង្ហូរទៅស្រែក្រោយផ្ទះ ខ្លះទៀត...
- ក្រោយពេលភ្លៀង:មេឃស្រឡះ ទឹកដក់ពេញភូមិនិងវាលស្រែ ទឹកភ្លៀងហូរពេញពាង ដំណាំរីក ស្រស់បំព្រង ឮសូរសំឡេងក្អុកក្អាត់កង្កែបហ៊ីងស្រែកឆ្លើយឆ្លងទ្រហឹងអឺងកងសប្បាយរីករាយនឹងទឹកភ្លៀងមាន អាកាសធាតុត្រជាក់
- ផលប្រយោជន៍: ទឹកភ្លៀងមានប្រយោជន៍ចំពោះជីវិតមនុស្ស សត្វ រុក្ខជាតិ ធម្មជាតិ។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: ទឹកភ្លៀងមានការរំខានខ្លះដល់ការធ្វើដំណើរនិងរកស៊ី ប៉ុន្តែមានប្រយោជន៍ចំពោះជីវិតមនុស្ស សត្វ រុក្ខជាតិ និងធម្មជាតិនៅលើផែនដី
- ចំណាប់អារម្មណ៍: ស្រឡាញ់ ចូលចិត្តទឹកភ្លៀង ព្រោះទឹកភ្លៀងផ្តល់ប្រយោជន៍ច្រើនដល់កសិករក្នុងការធ្វើស្រែចម្ការច្បារដំណាំនិងប្រើប្រាស់ក្នុងជីវភាពរស់នៅ។

## អត្រាគំណែ

### អត្រាពិន្ទុតែងសេចក្តីពណ៌នាអំពីព្រឹត្តិការណ៍

តែងសេចក្តីពណ៌នាអំពីព្រឹត្តិការណ៍ក៏មានអត្រាពិន្ទុ១០/១០ដែរ។ ក្រោយពីបញ្ចប់ការសិក្សាតែងសេចក្តីនិងផ្តល់ឧទាហរណ៍រួចសិស្សឆ្លើយនឹងសំណួរ ដើម្បីពង្រីកការយល់ដឹងលើខ្លឹមសារតាមផ្នែកនីមួយៗ។ លោកគ្រូ អ្នកគ្រូនឹងបង្រៀនពីគម្រោងតែងសេចក្តីថែមទៀត។ នៅក្នុងគម្រោងតែង លោកគ្រូ អ្នកគ្រូត្រូវតែពន្យល់សិស្សឱ្យច្បាស់លាស់អំពីខ្លឹមសារសំខាន់ៗដែលសិស្សត្រូវសរសេររៀបចំតាក់តែងឱ្យបានពីរោះក្បោះក្បាយ និងមានខ្លឹមសារសមស្របតាមប្រធានដែលបានលើកឡើង។ ពិសេសគ្រូត្រូវណែនាំពីចំណុចដែលត្រូវបានពិន្ទុតាមផ្នែកនីមួយៗនៅក្នុងគម្រោង ដើម្បីឱ្យ

សិស្សយល់ហើយខំសរសេរឱ្យបានពិន្ទុខ្ពស់ ហើយគ្រូក៏ត្រូវមានការលើកទឹកចិត្ត ឬជំរុញសិស្សឱ្យសរសេរបានរហូតដល់ចប់ផងដែរ។

ដូច្នេះក្នុងគម្រោងតែងគ្រូត្រូវកំណត់នូវអត្រាពិន្ទុឱ្យច្បាស់លាស់តាមលំនាំដូចខាងក្រោម។

**គម្រោងតែង**

**ក- សេចក្តីផ្តើម** (១,៥០ពិន្ទុ)

- ពេលវេលា (១,០០ពិន្ទុ)
- ទីកន្លែងនិងឈ្មោះព្រឹត្តិការណ៍ (០,៥០ពិន្ទុ)

**ខ- តួសេចក្តី** (៦,០០ពិន្ទុ)

- មុនពេលកើតហេតុ៖ សកម្មភាពមនុស្សមុនពេលកើតហេតុ: ទិដ្ឋភាពមនុស្សនិងសកម្មភាពផ្សេងៗ (២,០០ពិន្ទុ)
- ពេលកើតហេតុ៖
  - ✓ ព្រឹត្តិការណ៍ចាប់ផ្តើមកើតឡើង: ហេតុដែលនាំឱ្យមានព្រឹត្តិការណ៍កើតឡើង
  - ✓ ព្រឹត្តិការណ៍កំពុងកើតឡើង: រៀបរាប់ព្រឹត្តិការណ៍ដែលប្រព្រឹត្តទៅ (២,០០ពិន្ទុ)
- ក្រោយពេលកើតហេតុ: រៀបរាប់ពីអ្វីដែលកើតឡើងក្រោយពេលកើតហេតុ (២,០០ពិន្ទុ)

**គ- សេចក្តីបញ្ចប់** (១,៥០ពិន្ទុ)

- ការវាយតម្លៃ: រៀបរាប់ពីការវាយតម្លៃព្រឹត្តិការណ៍នីមួយៗដែលកើតឡើង (១,០០ពិន្ទុ)
- ចំណាប់អារម្មណ៍: បង្ហាញពីការចាប់អារម្មណ៍ចំពោះព្រឹត្តិការណ៍ដែលកើតឡើង (០,៥០ពិន្ទុ)

**រចនាបថ:** អក្សរស្អាត សរសេរមានរបៀប មានឃ្លាល្បះត្រឹមត្រូវ និងគ្មានកំហុសអក្ខរាវិរុទ្ធ (១,០០ពិន្ទុ)

## ៧.៨- ប្រធានពណ៌នាបែបនិទានរឿង

តែងសេចក្តីប្រធានបែបនិទានរឿង គឺតម្រូវឱ្យអ្នកសរសេររៀបរាប់អំពីរឿងរ៉ាវដែលមានស្រាប់ហើយបានកើតឡើងនៅកន្លែងណាមួយមកនិទានឱ្យភាគីម្ខាងស្តាប់តាមព្រឹត្តិការណ៍រឿងដដែល។ ដើម្បីសរសេរប្រធានបែបនេះបានល្អ គប្បីអនុវត្តដូចខាងក្រោម៖

១- ប្រើពាក្យសំដីរបស់អ្នកនិយាយតាំងពីដើមដល់ចប់។

២- សរសេររឿងនិទានតាមគម្រោងមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។

៣- ប្រើពាក្យប្រាប់លំដាប់កាលក្នុងសំណេររបស់អ្នកឱ្យបានត្រឹមត្រូវតាមលំដាប់នៃព្រឹត្តិការណ៍របស់រឿង។

៤- សរសេរឱ្យត្រឹមត្រូវតាមអក្ខរាវិរុទ្ធ។

៥- សរសេររៀបរាប់តាមព្រឹត្តិការណ៍ដែលមាននៅក្នុងរឿងឱ្យបានក្បោះក្បាយហើយច្បាស់លាស់។

៦- ប្រើពាក្យសំដីអ្នកនិទានផ្ទាល់ក្នុងការសរសេរ។

**៧.៨.១- ឧទាហរណ៍ទី១** (ថ្នាក់ ទី៥ និងទី៦)

**ប្រធាន**: កាលពីថ្ងៃអាទិត្យសប្តាហ៍មុនជីដូនរបស់ប្អូនបាននិទានរឿងមួយឱ្យប្អូនស្តាប់។
ចូរប្អូនសរសេររៀបរាប់ រឿងនិទាននោះឡើងវិញឱ្យបានក្បោះក្បាយ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

- បង្ហាញពេលវេលា
- ចំណងជើងរឿង និងអ្នកនិទានរឿង។

**ខ- តួសេចក្តី**

លើកយកសាច់រឿងទាំងស្រុងមកសរសេរដោយគោរពតាមលំដាប់លំដោយនៃព្រឹត្តិការណ៍រឿងនិងប្រើសម្តីអ្នកនិយាយតាំងពីដើមដល់ចប់៖

- ការដំណាលពីសេចក្តីផ្តើមនៃរឿង
- តួរឿង
- សេចក្តីបញ្ចប់នៃរឿង។

**គ- សេចក្តីបញ្ចប់**

- ការវាយតម្លៃ: បង្ហាញពីបរិយាកាសកម្សាន្តសប្បាយជាមួយរឿងនិទាននិងបង្កប់តម្លៃអប់រំរបស់រឿងនិទាន
- ចំណាប់អារម្មណ៍: សម្តែងចំណង់ចំណូលចិត្តនិងភាពសប្បាយរីករាយក្នុងការនិទានរឿងដោយផ្សារភ្ជាប់ទៅនឹងការអប់រំ។

## សេចក្តីពណ៌នា

នៅរាត្រីមួយដែលមានពន្លឺព្រះចន្ទភ្លឺត្រចះត្រចង់ ក្រោយសម្រាកពីការងារខ្ញុំនិងប្អូនៗរបស់ខ្ញុំបានមកអង្គុយជុំវិញជីដូនខ្ញុំនៅលើគ្រែខាងមុខផ្ទះដើម្បីស្តាប់គាត់និទានរឿង«ក្អែកនិងខ្វែក»។ ចៅៗបានស្តាប់កម្សាន្តគ្រប់គ្នា ហើយខ្ញុំបានចងចាំរឿងនេះទាំងស្រុង។

រឿងនេះមានសេចក្តីតំណាលថា៖ "កាលពីព្រេងនាយសត្វបក្សាបក្សីទាំងអស់សុទ្ធតែមានសម្បុរដូចគ្នា ខុសតែរូបរាងខ្លះប៉ុណ្ណោះ។ វេលាដែលវាហើរទៅលើអាកាសម្តងៗមនុស្សលោកពុំអាចសម្គាល់បានថាជាសត្វអ្វីឡើយ។ ដោយសារហេតុនេះហើយទើបពពួកសត្វស្លាបទាំងអស់បានបើកអង្គប្រជុំមួយ"។ លុះវេលាព្រឹកឡើង នៅលើដើមរាំងប្របមាត់ស្ទឹងពពួកបក្សាបក្សីជាច្រើនបានមកជួបជុំគ្នា។ ពេលនោះសត្វទាំងអស់បានគិតគ្នា៖ «ឥឡូវយើងទាំងអស់គ្នាគិតរចនារូបពួកយើងឱ្យមានសម្បុរខុសៗគ្នា។ យើងធ្វើយ៉ាងនេះដើម្បីកុំឱ្យមនុស្សលោកយល់ច្រឡំ»។ លុះជំនុំគ្នាអស់រយៈពេលយ៉ាងយូរមក ទើបពួកគេសម្រេចចិត្តថា អ្នកស្រឡាញ់ពណ៌សម្បុរយ៉ាងណា ចូរធ្វើយ៉ាងនោះចុះតែកុំឱ្យដូចគ្នា។ ជាមួយគ្នានោះដែរសត្វទាំងអស់ក៏បានពិភាក្សាគ្នារើសជាងគំនូរដោយពួកគេរើសខ្វែកនិងក្អែកឱ្យធ្វើជាជាងគំនូរ។ ខ្វែកបានដាក់ពណ៌ឱ្យសត្វទាំងអស់ទៅតាមចិត្តស្រឡាញ់របស់ពួកគេនៅសល់តែខ្វែកនិងក្អែកខ្លួនឯងផ្ទាល់មិនបានដាក់ពណ៌។ ខ្វែកបានសួរទៅកាន់ក្អែកថា៖ "បងក្អែកឯងចង់ដាក់ពណ៌ដូចម្តេចដែរ?" ក្អែកឆ្លើយថា"តាមតែចិត្តបងខ្វែកឯងទៅចុះ ព្រោះបងឯងជាជាងគំនូរស្រាប់គូរយ៉ាងណាឱ្យតែសមឱ្យតែស្អាត"។ ខ្វែកបានបញ្ជាក់បន្ថែម៖ «អើ! បើដូចនេះខ្ញុំគូរបានតែពេលយប់ទេទើបរំលេចពណ៌បានល្អ បើគូរពេលថ្ងៃមិនល្អទេ។ បើដូចនេះចូរបងឯងគូរឱ្យខ្ញុំជាមុនសិន ចាំខ្ញុំគូរឱ្យបងឯងជាក្រោយ»។ ក្អែកក៏គូរឱ្យខ្វែកមានពណ៌ក្រវេមក្រវាមទៅតាមចំណូលចិត្តខ្លួន។ ស្បៃងងឹតចូលមកដល់នៅលើខ្នងភ្នំខ្វែកបានហៅក្អែកទាំងអស់មកប្រជុំគ្នាហើយ

បានលាយធ្យូងមួយខ្ទះធំ ទើបវាបានយកកំណាត់ជ្រលក់លាបៗពេញសត្វទាំងអស់គ្នាគ្មានសល់សាច់ត្រង់ណាបន្តិចបន្តួចឡើយ។ លុះព្រឹកឡើងក្អែកទាំងអស់ឃើញខ្លួនខ្មៅនិលគ្រប់ៗគ្នាដូចនេះក៏កើតមានកំហឹងពេញទ្រូងនាំគ្នាហើរស្រែករំពងព្រៃតាមរកខ្វែកឱ្យឃើញនឹងចឹកសម្លាប់ឱ្យវិនាស។ ឯហ្វូងខ្វែកឮគ្រាន់តែព្រលឹមស្រាងៗឡើងនាំគ្នាហើរគេចខ្លួនពួនសម្ងំក្នុងព្រៃបាត់អស់។ ហេតុនេះហើយទើបសត្វខ្វែករកស៊ីពេលយប់សម្រាកនៅពេលថ្ងៃ ដើម្បីពួនសម្ងំគេចពីក្អែកដែលជាសត្រូវនឹងគ្នាតាំងពីពេលនោះមក។

រឿងនេះបានអប់រំយើងកុំឱ្យមានកំហឹងឈ្លោះប្រកែកគ្នា កុំឱ្យមានគំនុំគុំគួននឹងគ្នាចៀសវាងអំពើហិង្សា ត្រូវចេះសាងមិត្តប្រសើរជាងសត្រូវ។ ក្រោយពីស្តាប់រឿងនិទាននេះចប់ ខ្ញុំនិងប្អូនរបស់ខ្ញុំសប្បាយរីករាយយ៉ាងខ្លាំង ព្រោះរឿងនេះមានអត្ថន័យអប់រំល្អៗសម្រាប់យើងទាំងអស់គ្នាដែលរស់នៅក្រោមដំបូលតែមួយមិនត្រូវប្រើកំហឹងទល់កំហល់ ហើយចេះដោះស្រាយបញ្ហាដោយសន្តិវិធីស្រឡាញ់សន្តិភាព ដោយមិនប្រើហិង្សានៅក្នុងសង្គម។

## អត្រាកំណែ

### អត្រាពិន្ទុប្រធានពណ៌នាបែបនិទានរឿង

អត្រាពិន្ទុពណ៌នាអំពីនិទានរឿងមានអត្រាពិន្ទុដូចអត្រាពិន្ទុតែងសេចក្តីពណ៌នាពីមនុស្ស សត្វ វត្ថុ រុក្ខជាតិដែរគឺមានអត្រាពិន្ទុ១០/១០។ លោកគ្រូអ្នកគ្រូត្រូវណែនាំអំពីអត្រាពិន្ទុនៅក្នុងសំណេររបស់សិស្សតាមរយៈគម្រោងតែងដូចខាងក្រោម។

## គម្រោងតែង

**ក- សេចក្តីផ្តើម(១,៥០ពិន្ទុ)**

- បង្ហាញពេលវេលា:នៅពេលណា (១,០០ពិន្ទុ)
- ចំណងជើងរឿង និងអ្នកនិទានរឿង (០,៥០ពិន្ទុ)

**ខ- តួសេចក្តី(៦,០០ពិន្ទុ)**

លើកយកសាច់រឿងទាំងស្រុងមកសរសេរដោយគោរពតាមលំដាប់លំដោយនៃព្រឹត្តិការណ៍រឿង៖

- ការដំណាលពីសេចក្តីផ្តើមនៃរឿងនិទាន (២,០០ពិន្ទុ)
- តួរឿង (២,០០ពិន្ទុ)
- សេចក្តីបញ្ចប់រឿង (២,០០ពិន្ទុ)

**គ- សេចក្តីបញ្ចប់(១,៥០ពិន្ទុ)**

- ការវាយតម្លៃ: បង្ហាញពីការយកចិត្តទុកដាក់និទានរឿងដើម្បីឱ្យអ្នកស្តាប់បានដឹងនិងបង្ហាញតម្លៃ អប់រំរបស់រឿងនិទាន (១,០០ពិន្ទុ)
- សម្តែងអារម្មណ៍សប្បាយរីករាយជាមួយរឿងនិទានដោយផ្សារភ្ជាប់ទៅនឹងការអប់រំ (០.៥០ពិន្ទុ)

**រចនាបថ** : អក្សរស្អាត សរសេរមានរបៀប មានឃ្លាល្បះត្រឹមត្រូវ និងគ្មានកំហុសអក្ខរាវិរុទ្ធ (១,០០ពិន្ទុ)

## ៧.៩- ប្រធានសរសេរសំបុត្រសួរសុខទុក្ខ

ប្រធានសរសេរសំបុត្រតម្រូវឱ្យយើងប្រើរបៀបសរសេរខុសពីប្រធានបែបពណ៌នាផ្សេងៗ។ ប្រធាននេះមានគោលការណ៍ណែនាំក្នុងការសរសេរដោយគោរពលក្ខខណ្ឌមួយចំនួន ដែលជាបែបបទសម្រាប់សរសេរទៅតាមទម្រង់លិខិតឬសំបុត្រ។

ប្រធានបែបសរសេរសំបុត្ររួមមានច្រើនប្រភេទមានដូចជាសំបុត្រសួរសុខទុក្ខមិត្តភក្ដិ ឪពុកម្ដាយ មាមីង បងប្អូន លោកគ្រូ អ្នកគ្រូ។ សំបុត្រប្រភេទនេះគឺជាសំបុត្រផ្ទាល់ខ្លួនឬឯកជនសម្រាប់ផ្ញើទៅកាន់ពួកគេទាំងនោះ។ ជាទូទៅគេដាក់វានៅក្នុងស្រោម ទើបផ្ញើតាមប្រៃសណីយ៍ ឬតាមនរណាម្នាក់ដូចជាសំបុត្រទាក់ទងនឹងឪពុកម្ដាយ ប្ដីប្រពន្ធ កូន បង ប្អូន មិត្តភក្ដិ លោកគ្រូ អ្នកគ្រូ។ល។ ដែលនៅឆ្ងាយពីគ្នា។ នៅក្នុងទំនាក់ទំនងនេះគេប្រើសំណេរជំនួស ការនិយាយដើម្បីឆ្លើយឆ្លងគ្នានិងផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

ខាងក្រោមនេះជាគម្រោងសំបុត្រសួរសុខទុក្ខដែលជាឧទាហរណ៍៖

**គម្រោង**

តាមធម្មតា ការសរសេរសំបុត្រត្រូវចែកជាបីផ្នែកគឺ ក្បាលសំបុត្រ តួសំបុត្រ និងការបញ្ចប់សំបុត្រ៖

**ក- ក្បាលសំបុត្រ**

- ត្រូវចុះឈ្មោះ ទីកន្លែង និងកាលបរិច្ឆេទនៃការសរសេរ
- ចំណងជើងសំបុត្រ : «មកដល់...»។

**ខ- តួសំបុត្រ**

- ដំបូងត្រូវរៀបរាប់អំពីសុខទុក្ខផ្ទាល់ខ្លួនរបស់អ្នកសរសេរទៅអ្នកទទួល
- បន្ទាប់មកសួរសុខទុក្ខអ្នកដែលទទួលសំបុត្រនិងសរសេររៀបរាប់រឿងរ៉ាវផ្សេងៗមានដូចជាដំណឹង ដំបូន្មាន... ដែលអ្នកសរសេរនិងអ្នកទទួលមានទំនាក់ទំនងជាមួយគ្នាទៅតាមគោលបំណងរៀងៗខ្លួន។

**គ- ការបញ្ចប់សំបុត្រ**

- ត្រូវជូនពរ (ត្រូវប្រើពាក្យសមស្របនឹងកាលៈទេសៈ) និងជូនកាលអាចភ្ជាប់ឃ្លាបញ្ចប់សំបុត្រដូចជា «ពីកូនសម្លាញ់ចិត្តរបស់ម៉ែឬនឹកជានិច្ច...)
- ទីបញ្ចប់ត្រូវចុះហត្ថលេខានិងឈ្មោះអ្នកសរសេរ។

**កំណត់សម្គាល់:** នៅក្នុងកិច្ចការប្រឡងឬកិច្ចការក្នុងថ្នាក់ពុំតម្រូវឱ្យមានហត្ថលេខានិងឈ្មោះអ្នកសរសេរទេ។

### ៧.៩.១- ឧទាហរណ៍ទី១ (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនសរសេរសំបុត្រមួយច្បាប់ ដើម្បីសួរសុខទុក្ខមិត្តរបស់ប្អូនដែលបានទៅសិក្សានៅឆ្ងាយពីប្អូន។

# គម្រោងតែង

ថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំរកា ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨

**មកដល់ចិន្ដាសម្លាញ់ជាទីនឹករឭក**

ចិន្ដា! អស់រយៈពេលជាងមួយឆ្នាំមកហើយដែលសម្លាញ់បានឃ្លាតពីខ្ញុំទៅបន្ដការសិក្សានៅភ្នំពេញ។ នៅក្នុងរយៈពេលនេះខ្ញុំមិនបានដឹងពីសុខទុក្ខរបស់សម្លាញ់យ៉ាងណានោះទេ។ ខ្ញុំតែងរឭកមកដល់សម្លាញ់ ជានិច្ច។ តើសម្លាញ់មានសេចក្ដីសុខទុក្ខយ៉ាងណាដែរ?

ចំណែកខ្ញុំឯនេះវិញមានសេចក្ដីសុខជាធម្មតាទេ។ សព្វថ្ងៃខ្ញុំរៀននៅថ្នាក់ទីប្រាំមួយហើយ។ ជីវភាពរបស់ខ្ញុំក៏បានល្អប្រសើរបន្ដិចហើយ ព្រោះគ្រួសារខ្ញុំខិតខំបង្កបង្កើនផលមិនទុកឱ្យដីនៅទំនេរគ្រប់រដូវ និងបង្កើនការចិញ្ចឹមសត្វថែមទៀត។ សព្វថ្ងៃខ្ញុំខិតខំរៀនសូត្រណាស់រហូតទទួលឰតបានរង្វាន់ប្រចាំសាលាជាសិស្សរៀនពូកែ ព្រោះខ្ញុំរៀននៅសាលាមិនដែលឈប់។ ពេលខ្លះខ្ញុំរៀននៅក្លឹបសិក្សាជាមួយក្រុមសិស្សឯទៀត ហើយពេលទំនេរខ្ញុំឆ្លៀតជួយធ្វើការក្នុងផ្ទះជាមួយឪពុកម្ដាយ។ លោកគ្រូ ម៉ែពុក មិត្តភក្ដិសរសើរខ្ញុំមិនដាច់ពីមាត់ថាខ្ញុំជាកូនល្អ ជាសិស្សគំរូម្នាក់ក្នុងសាលារៀននិងក្នុងគ្រួសារ។ ចុះសម្លាញ់វិញតើការសិក្សា ឆ្នាំនេះយ៉ាងណាដែរ? ឆ្នាំនេះជាការប្រឡងបញ្ចប់បឋមសិក្សា។ ខ្ញុំជឿជាក់ថាសម្លាញ់ពិតជាខំសិក្សាអស់ពីសមត្ថភាពព្រោះថាសម្លាញ់ក៏ជាអ្នកស្រឡាញ់ការសិក្សាដែរ ហើយសម្លាញ់មានឪពុកម្ដាយជាអ្នកបីបាច់ថែរក្សានិងជួយលើកទឹកចិត្តក្នុងការសិក្សា។ ព្រមជាមួយគ្នានេះដែរ ខ្ញុំក៏សូមផ្ញើជូនសេចក្ដីនឹករឭកនិងសួរសុខទុក្ខពីចម្ងាយដល់ក្រុមគ្រួសាររបស់ចិន្ដាផង ជាពិសេសលោកពូ អ្នកមីងដោយសេចក្ដីគោរព និងក្ដីនឹករឭកដ៏លើសលប់ក្រៃលែងអំពីខ្ញុំ។ សព្វថ្ងៃតើគាត់មានសេចក្ដីសុខឬទុក្ខយ៉ាងណាដែរ? បើសម្លាញ់បានទទួលសំបុត្រនេះហើយសូមសម្លាញ់សរសេរតបមកខ្ញុំវិញផង។ ដោយពេលវេលាពុំអនុញ្ញាត ខ្ញុំលាសម្លាញ់ត្រឹមនេះសិនចុះ យើងនឹងជួបគ្នានៅពេលក្រោយ។

ជាបញ្ចប់ សូមសម្លាញ់និងក្រុមគ្រួសារជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដោយក្ដីនឹករឭកជាពន់ពេក
ពីខ្ញុំដែលនៅឆ្ងាយ
**ហត្ថលេខា**

**នារីរត្ន**

### ៧.៩.២- ឧទាហរណ៍ទី២ (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរអ្នកសរសេរសំបុត្រសួរសុខទុក្ខនិងផ្តល់ដំណឹងជូនឪពុកម្តាយរបស់អ្នកនៅស្រុកកំណើត។

## គម្រោងតែង

ថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំរកា ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨

**គោរពជូនចំពោះអ្នកមានគុណទាំងពីរ**

សូមគោរពប្រណិប័តន៍ជម្រាបមកលោកឪពុក អ្នកម្តាយជាទីស្រឡាញ់និងជាទីនឹករឭកអំពីកូន។ កូននៅឯនាយបានទទួលសេចក្តីសុខនិងទុក្ខជាធម្មតាទេ សូមលោកឪពុក និងអ្នកម្តាយកុំព្រួយបារម្ភអ្វី។

តើពេលនេះលោកឪពុកនិងអ្នកម្តាយមានសេចក្តីសុខទុក្ខយ៉ាងណា? តើស្រែចម្ការយើងបានទទួលផលយ៉ាងណាដែរ? សូមលោកឪពុកអ្នកម្តាយផ្តល់ដំណឹងឱ្យកូនបានដឹងផង។ សព្វថ្ងៃកូននៅឯនាយខំព្យាយាមរៀនសូត្រដោយស្តាប់និងគោរពតាមដំបូន្មានរបស់លោកទាំងពីរឥតធ្វេសប្រហែសម្តងឡើយ។ សូមអ្នកមានគុណទាំងពីរកុំធ្វើការហួសកម្លាំងឱ្យសោះ ត្រូវព្យាយាមថែរក្សាសុខភាពឱ្យល្អ ជាពិសេសកុំពិសាចំណីអាហារដែលប៉ះពាល់ដល់សុខភាព។ នៅពេលវិស្សមកាលខាងមុខនេះកូននឹងទៅលេងនិងសួរសុខទុក្ខលោកឪពុកអ្នកម្តាយដោយផ្ទាល់និងជួយធ្វើការងារខ្លះៗដល់អ្នកមានគុណទាំងពីរ។

ជាទីបញ្ចប់ កូនសូមជូនពរលោកទាំងពីរឱ្យមានសុខភាពបរិបូរ អាយុយឺនយូរ និងកម្លាំងខ្លាំងក្លាឈ្នះអស់មាសត្រូវគ្រប់ទិសទី។ លើសពីនេះទៀតកូនសូមផ្ញើសេចក្តីនឹករឭកដល់ មីង មា យាយ តាទាំងអស់គ្នា ផង។ កូនសូមជម្រាបលាអ្នកមានគុណទាំងពីរ ដោយក្តីអាឡោះអាល័យជាទីបំផុត។ សេចក្តីគួរពុំគួរសូមលោកទាំងពីរមេត្តាអភ័យទោស។

ដោយការស្រឡាញ់និងគោរពដ៏ខ្ពង់ខ្ពស់បំផុតពីកូន
ហត្ថលេខានិងឈ្មោះ

**ដារ៉ា**

**៧.៩.៣-ឧទាហរណ៍ទី៣** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនសរសេរសំបុត្រមួយច្បាប់ដើម្បីសួរសុខទុក្ខសត្យាមិត្តរបស់ប្អូន។

**គម្រោងតែង**

ថ្ងៃសុក្រ ១២រោច ខែមាឃ ឆ្នាំរកា ព.ស.២៥៦១
រតនគិរី ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨

មកដល់សត្យាជាទីនឹករឭក

សត្យា! រយៈពេលជាច្រើនខែមកហើយដែលខ្ញុំបានឃ្លាតឆ្ងាយពីមិត្ត។ ក្នុងរយៈពេលនេះខ្ញុំតែងតែនឹកមមៃមកដល់សម្លាញ់ជានិច្ច។ រាត្រីនេះខ្ញុំគេងមិនលក់សោះទើបខ្ញុំខិតខំផ្ចង់អារម្មណ៍រិះរកពាក្យពេចន៍មកសរសេរជាសំបុត្រនេះ។

សម្លាញ់! តើឯងនឹករលឹកមកដល់ខ្ញុំទេ? តើឯងមានសេចក្តីសុខដែរឬយ៉ាងណា? បើឯងបានសេចក្តីសុខ ខ្ញុំពិតជាត្រេកអររកអ្វីមកប្រៀបផ្ទឹមគ្មាន។ ចំណែកខ្ញុំវិញ នៅឯនេះមានសេចក្តីសុខជាធម្មតាទេ ហើយតែងនឹកមកឯងជានិច្ច។ ខ្ញុំមិនអាចរកពាក្យអ្វីមកសរសេររៀបរាប់ឱ្យត្រូវនឹងទំហំនៃសេចក្តីនឹករឭករបស់ខ្ញុំចំពោះឯងបានឡើយ។ សត្យា!អនុស្សាវរីយ៍របស់យើងទាំងពីរកំពុងដិតនៅជាប់នឹងដួងចិត្តខ្ញុំជានិច្ច។ យើងធ្លាប់អានសៀវភៅជាមួយគ្នា ធ្វើលំហាត់ជាមួយគ្នា។ យើងទៅណាមកណាពីរនាក់ជានិច្ច។ ឯងឆ្លាតណាស់ ឆាប់ចេះ ឆាប់យល់ រហ័សចាំ ហើយឧស្សាហ៍ទៀតផង។ ខ្ញុំមិនដឹងថាសម្លាញ់នៅចាំរឿងរ៉ាវទាំងនេះដែរឬអត់? អូ! ខ្ញុំភ្លេចនិយាយប្រាប់ឯង សព្វថ្ងៃក្រៅពីរៀននៅសាលារដ្ឋ ខ្ញុំរៀនភាសាអង់គ្លេសនិងកុំព្យូទ័របន្ថែមទៀត។ ឥឡូវខ្ញុំចេះប្រើអ៊ីនធឺណិតបានខ្លះៗហើយ។ ខ្ញុំជឿថាឯងក៏ចេះប្រើប្រាស់វាដែរ នៅនៅពេលខាងមុខ ហើយឆាប់ចេះប្រើជាងខ្ញុំផង ប្រសិនឯងបានរៀន។ យប់ជ្រៅណាស់ហើយខ្ញុំសូមបញ្ចប់អក្ខរាតែត្រឹមនេះចុះ។ តាមរយៈសំបុត្រដ៏ខ្លីនេះ ខ្ញុំសូមផ្ញើសេចក្តីនឹករឭកដល់មិត្តភក្តិទាំងអស់ និងអ្នកភូមិយើងផង។

ចុងបញ្ចប់ សូមជូនពរនិងក្រុមគ្រួសារបានជួបតែសេចក្តីសុខគ្រប់ទិវារាត្រី។

ពីខ្ញុំសម្លាញ់របស់អ្នក
ហត្ថលេខា

**នាសា**

**៧.៩.៤-ឧទាហរណ៍ទី៤** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនសរសេរសំបុត្រសួរសុខទុក្ខមិត្តរបស់ប្អូនម្នាក់ដែលមានទុក្ខដោយសារគ្រោះខ្យល់ព្យុះប៉ះពាល់គេហដ្ឋានដែលកំពុងរស់នៅសព្វថ្ងៃ។

## គម្រោងតែង

ថ្ងៃសុក្រ ១១រោច ខែពិសាខ ឆ្នាំច ព.ស.២៥៦២
កំពង់ឆ្នាំង ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨

**មកដល់សុខារី ជាទីនឹករឭក**

សុខារី មិត្តសម្លាញ់ ! ខ្ញុំទើបតែបានទទួលដំណឹងថ្មីៗនេះថា គ្រួសារឯងបានរងគ្រោះដោយខ្យល់ព្យុះកាលពីយប់ម្សិលមិញ ធ្វើឱ្យផ្ទះឯងដួលរលំ ព្រមទាំងខូចខាតទ្រព្យសម្បត្តិមួយចំនួនទៀតផង។

នៅពេលដែលខ្ញុំបានទទួលដំណឹងនេះភ្លាម ខ្ញុំមានចិត្តរន្ធត់និងសោកស្ដាយខ្លាំងណាស់ ចំពោះគ្រោះមហន្តរាយដែលបានបំផ្លាញផ្ទះសម្បែងនិងទ្រព្យសម្បត្តិរបស់គ្រួសារមិត្ត។ ខ្ញុំសូមចូលរួមសោកស្ដាយមិត្ត ព្រមទាំងគ្រួសារទាំងអស់ដោយទឹកចិត្តស្មោះអស់ពីដួងចិត្តហើយសង្ឃឹមថា ក្រុមគ្រួសាររបស់មិត្តនឹងបានរៀបចំផ្ទះសម្បែងបានល្អប្រសើរឡើងវិញ។ សូមឯងកុំបារម្ភអីពួកយើងទាំងអស់គ្នានឹងទៅចូលរួមជួយនិងលើកទឹកចិត្តដល់ឯងនិងក្រុមគ្រួសារ។ ពួកយើងមានថវិកាមួយចំនួនដើម្បីជួយមិត្តគ្រាន់នឹងដោះស្រាយបញ្ហាបានមួយគ្រាផងដែរ។ សូមមិត្តទទួលដោយរីករាយអំពីពួកយើងដែលជាអតីតមិត្តរួមថ្នាក់ ហើយតែងតែជួយឈឺឆ្អាលគ្នាទៅវិញទៅមកពេលមានទុក្ខធុរៈឬគ្រោះអាសន្នផ្សេងៗ។

សូមមិត្ត និងគ្រួសារបានជួបប្រទះតែសេចក្ដីសុខគ្រប់ប្រការ។

ពីខ្ញុំសម្លាញ់របស់ឯង
ហត្ថលេខា

**កុសល**

**៧.៩.៥- ឧទាហរណ៍ទី៥** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនសរសេរសំបុត្រមួយច្បាប់ទៅសួរសុខទុក្ខបងស្រីរបស់ប្អូនដែលបានបែកគ្នាពីស្រុកកំណើតមកសិក្សានៅរាជធានីភ្នំពេញ។

## គម្រោងតែង

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨

**បងស្រីជាទីគោរពនិងជាទីនឹករលឹក!**

បងស្រី! អស់រយៈពេលជាយូរថ្ងៃមកហើយ ដែលខ្ញុំបានឃ្លាតពីបងស្រី និងភូមិកំណើតមករស់នៅភ្នំពេញជាមួយលោកអ៊ំ។ ក្នុងរយៈពេលដ៏យូរនេះ ខ្ញុំពុំបានដឹងសុខទុក្ខរបស់បងស្រីទេ។ ខ្ញុំមានក្ដីនឹករលឹកបងស្រីជានិច្ច។

តើបងស្រីមានចិត្តនឹករឭកប្អូនទេ? សព្វថ្ងៃខ្ញុំនិងលោកអ៊ំនៅឯភ្នំពេញមានសេចក្ដីសុខធម្មតាទេ។ តើបងស្រីមានសេចក្ដីសុខដែរឬយ៉ាងណា? ឯការសិក្សារបស់បងវិញយ៉ាងណាដែរ?

បងស្រីជាទីនឹករលឹក! ខ្ញុំសូមជម្រាបបងងថា កាលពីមកដល់ភ្នំពេញដំបូង ខ្ញុំឃើញចរាចរណ៍តាមផ្លូវណែនតាន់តាប់ ខ្ញុំពុំហ៊ានដើរចេញពីផ្ទះទេ។ ខ្ញុំមានអារម្មណ៍ថា ភ្នំពេញមានមនុស្សរស់នៅកុះករ តែឥឡូវនេះខ្ញុំមានទម្លាប់រស់នៅធម្មតាដូចគេដូចឯងដែរ។ សព្វថ្ងៃនៅសាលារៀន ខ្ញុំយកចិត្តទុកដាក់រៀនសូត្រណាស់។ នៅផ្ទះខ្ញុំខិតខំមើលមេរៀនធ្វើលំហាត់ និងរៀនភាសាអង់គ្លេសបន្ថែមទៀត។ ការសិក្សារបស់ខ្ញុំទទួលបានលទ្ធផលល្អជារៀងរាល់ខែ។ ខ្ញុំប្រាកដជាប្រឡងជាប់មិនខាន។ ក្រៅពីការសិក្សាខ្ញុំឆ្លៀតជួយបោសសម្អាតស្រោចផ្កាជាដើម។ ខ្ញុំនឹងខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានពូកែធ្វើខ្លួនជាប្អូនដ៏របស់បងនិងធ្វើឱ្យបងសប្បាយចិត្ត។ សូមបងស្រីកុំព្រួយបារម្ភឱ្យសោះ។

នៅចុងបញ្ចប់នេះ ខ្ញុំក៏សូមផ្ញើនូវសេចក្ដីនឹករឭកដ៏លើសលប់ក្រៃលែងនិងការសួរសុខទុក្ខពីចម្ងាយផងចំពោះលោកពូ អ្នកមីង ញាតិមិត្តជិតខាង អ្នកភូមិទាំងអស់គ្នា ជាពិសេសមិត្តភក្ដិរបស់ខ្ញុំ។ សូមបងស្រីជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

ពីប្អូនប្រុសសម្លាញ់ចិត្តរបស់បង
ហត្ថលេខា
**មាស ចន្ទដែន**

## អត្រាគំណែ

### អត្រាពិន្ទុប្រធានសរសេរសំបុត្រ

ទោះបីទម្រង់ប្រធានពណ៌នាអំពីសំបុត្រមានលក្ខណៈខុសពីប្រធានពណ៌នាដទៃទៀតដូចជាតែង សេចក្ដីពណ៌នាពីមនុស្ស សត្វ វត្ថុ រុក្ខជាតិដែរក៏ដោយ ក៏អត្រាពិន្ទុសំណេរសំបុត្រមានអត្រាពិន្ទុ ១០/១០ដែរ។ លោកគ្រូ អ្នកគ្រូត្រូវរៀបចំអត្រាពិន្ទុនៅក្នុងសំណេររបស់សិស្សទៅតាមលំនាំគម្រោងតែងដូចខាងក្រោម។

**គម្រោងតែង**

**ក- សេចក្តីផ្តើម(២,០០ពិន្ទុ)**

- ក្បាលសំបុត្រ ឈ្មោះ ទីកន្លែង និងកាលបរិច្ឆេទនៃការសរសេរ (១,០០ពិន្ទុ)
- ចំណងជើងសំបុត្រៈការគោរព «មកដល់...» (១,០០ពិន្ទុ)

**ខ- តួសេចក្តី(៦,០០ពិន្ទុ)**

- រៀបរាប់សុខទុក្ខផ្ទាល់ខ្លួនរបស់អ្នកសរសេរទៅអ្នកទទួល (២,០០ពិន្ទុ)
- សួរសុខទុក្ខដល់អ្នកទទួលសំបុត្រនិងសរសេររៀបរាប់រឿងរ៉ាវផ្សេងៗ (២,០០ពិន្ទុ)
- ប្រាប់សុខទុក្ខអ្នកសរសេរទៅអ្នកទទួល (២,០០ពិន្ទុ)

**គ- សេចក្តីបញ្ចប់(១,៥០ពិន្ទុ)**

- ពាក្យជូនពរ (០,៥០ពិន្ទុ)
- ការចុះហត្ថលេខានិងដាក់ឈ្មោះ (០,៥0ពិន្ទុ)

**រចនាបថ:** អក្សរស្អាត សរសេរមានរបៀប មានឃ្លាល្បះត្រឹមត្រូវនិងគ្មានកំហុសអក្ខរាវិរុទ្ធ (១,០០ពិន្ទុ)

## ៧.១០- សំណេរពាក្យសុំផ្សេងៗ

ពាក្យសុំច្បាប់គឺជាប្រភេទលិខិតផ្លូវការមួយក្នុងចំណោមប្រភេទលិខិតដទៃទៀត។ ពាក្យសុំច្បាប់ត្រូវរៀបចំឡើងក្នុងគោលបំណងប្រើប្រាស់សម្រាប់ជាលក្ខណៈបុគ្គលផ្ទាល់ ប៉ុន្តែអ្នកសរសេរត្រូវសរសេរទៅតាមទម្រង់បែបបទរដ្ឋបាលដូចលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែរ។ ពាក្យសុំច្បាប់នេះ ជាទូទៅសិស្សគ្រាន់តែបំពេញខ្លឹមសារសំខាន់ៗក្នុងចន្លោះពាក្យសុំច្បាប់តែប៉ុណ្ណោះ។ ខាងក្រោមនេះជាគម្រោងពាក្យសុំច្បាប់សម្រាប់សិស្សសាលាបឋមសិក្សា។

៧.១០.១- ឧទាហរណ៍ទី១ (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនសរសេរបំពេញពាក្យសុំអនុញ្ញាតច្បាប់ដូចគំរូខាងក្រោមឱ្យបានត្រឹមត្រូវ។

**គម្រោងតែង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាបឋមសិក្សា**..................

ពាក្យសុំអនុញ្ញាតច្បាប់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ............................ភេទ...... អាយុ.......ឆ្នាំ......... ជាសិស្សរៀនថ្នាក់ទី.... នៃសាលាបឋមសិក្សា........................រាជធានីខេត្ត........................។

សូមគោរពជូន

លោកគ្រូ/អ្នកគ្រូប្រចាំថ្នាក់ទី..................

តាមរយៈ : ប្រធានថ្នាក់ទី......

កម្មវត្ថុ : សំណើសុំអនុញ្ញាតច្បាប់ចំនួន......ថ្ងៃ

មូលហេតុ : ...................................................

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងមូលហេតុខាងលើនេះ សូមលោកគ្រូ/អ្នកគ្រូ មេត្តាពិនិត្យនិងអនុញ្ញាតច្បាប់ដល់ខ្ញុំបាទ/នាងខ្ញុំបានឈប់សម្រាកដោយក្ដីអនុគ្រោះ។

សូមលោកគ្រូ/អ្នកគ្រូ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ.............. ខែ.......... ឆ្នាំ....... ព.ស..........

រាជធានីខេត្ត.......... ថ្ងៃទី.....ខែ......ឆ្នាំ........

ហត្ថលេខានិងឈ្មោះ

...........................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាបឋមសិក្សាចៅពញាហុក**

## ពាក្យសុំអនុញ្ញាតច្បាប់

នាងខ្ញុំឈ្មោះ **សុខ ធីតា** ភេទស្រី អាយុ១១ឆ្នាំ ជាសិស្សរៀនថ្នាក់ទី៦(ក) នៃសាលាបឋមសិក្សាចៅពញាហុក រាជធានីភ្នំពេញ។

**សូមគោរពជូន**

លោកគ្រូ/អ្នកគ្រូប្រចាំថ្នាក់ទី៦(ក)

តាមរយៈ : ប្រធានថ្នាក់ទី៦(ក)

កម្មវត្ថុ : សំណើសុំអនុញ្ញាតច្បាប់ឈប់សម្រាកចំនួន០១ថ្ងៃថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨

មូលហេតុ : មានជំងឺគ្រុនក្ដៅ

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងមូលហេតុខាងលើនេះ សូមលោកគ្រូ/អ្នកគ្រូ មេត្តាពិនិត្យ និងអនុញ្ញាតច្បាប់ដល់ខ្ញុំនាងខ្ញុំបានឈប់សម្រាកដោយក្ដីអនុគ្រោះ។

សូមលោកគ្រូ/អ្នកគ្រូ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨

ហត្ថលេខា និងឈ្មោះ

**សុខ ធីតា**

# អត្រាកំណែ

## អត្រាពិន្ទុសំណេរបំពេញពាក្យសុំផ្សេងៗ

អត្រាពិន្ទុសំណេរបំពេញពាក្យសុំផ្សេងៗក៏ដូចជាអត្រាពិន្ទុតែងសេចក្តីពណ៌នាពីមនុស្ស សត្វ វត្ថុ រុក្ខជាតិដទៃទៀតដែរ គឺមានអត្រាពិន្ទុ១០/១០ដែរ។ លោកគ្រូអ្នកគ្រូត្រូវអនុវត្តតាមការណែនាំអំពីអត្រា ពិន្ទុនៅក្នុងសំណេររបស់សិស្សតាមប្រភេទពាក្យសុំនីមួយៗក្នុងគម្រោងតែងដូចខាងក្រោមឱ្យបានត្រឹមត្រូវ។

**ក- សេចក្តីផ្តើម** (៤,០០ពិន្ទុ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាបឋមសិក្សា**.................. *(១,០០ពិន្ទុ)*

ពាក្យសុំអនុញ្ញាតច្បាប់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ .................ភេទ.... អាយុ.......ឆ្នាំ ជាសិស្សរៀនថ្នាក់ទី.... ***(១,០០ពិន្ទុ)***
នៃសាលា បឋមសិក្សា..................... ***(១,០០ពិន្ទុ)***
រាជធានី/ខេត្ត......................... ***(១,០០ពិន្ទុ)***

**ខ- តួសេចក្តី** (៤,០០ពិន្ទុ)

សូមគោរពជូន

លោកគ្រូ/អ្នកគ្រូប្រចាំថ្នាក់ទី.......... ***(១,០០ពិន្ទុ)***

តាមរយ : ប្រធានថ្នាក់ទី...... ***(១,០០ពិន្ទុ)***
កម្មវត្ថុ : សំណើសុំអនុញ្ញាតច្បាប់ចំនួន......ថ្ងៃ ***(១,០០ពិន្ទុ)***
មូលហេតុ : .................................................... ***(១,០០ពិន្ទុ)***

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងមូលហេតុខាងលើនេះ សូមលោកគ្រូ/អ្នកគ្រូ មេត្តាពិនិត្យ និងអនុញ្ញាតច្បាប់ដល់ខ្ញុំបាទ/នាងខ្ញុំបានឈប់សម្រាកដោយក្តីអនុគ្រោះ។

**គ- សេចក្តីបញ្ចប់** (**១,០០ពិន្ទុ**)

សូមលោកគ្រូ/អ្នកគ្រូ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ............... ខែ.......... ឆ្នាំ....... ព.ស..........

រាជធានី ខេត្ត.......... ថ្ងៃទី.....ខែ......ឆ្នាំ......... ***(១,០០ពិន្ទុ)***

ហត្ថលេខា និងឈ្មោះ

**រចនាបថ:** អក្សរស្អាត បំពេញចន្លោះពាក្យក្នុងប្រភេទលិខិតឬពាក្យសុំនីមួយៗបានត្រឹមត្រូវ និងគ្មានកំហុសអក្ខរាវិរុទ្ធ ***(១,០០ពិន្ទុ)***

**៧.១០.២- ឧទាហរណ៍ទី២** (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនបំពេញនិងគូសសញ្ញាក្នុងប្រអប់ប្រវត្តិរូបរបស់ប្អូនតាមទម្រង់ដូចខាងក្រោមឱ្យបានត្រឹមត្រូវ។

## គម្រោងតែង

**ក- សេចក្តីផ្តើម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាបឋមសិក្សា..................

**ប្រវត្តិរូបសង្ខេប**

១- ឈ្មោះសិស្ស..........................ភេទ........អក្សរឡាតាំង......................រៀនថ្នាក់ទី......នៃសាលា ..................ស្ថិតនៅក្នុងកម្រងសាលា...................ភូមិ.........ឃុំ សង្កាត់...........ស្រុក ខណ្ឌ ក្រុង .............. រាជធានី ខេត្ត...........................

២- ថ្ងៃ ខែ ឆ្នាំកំណើត: ថ្ងៃទី........ ខែ............ ឆ្នាំ................ សញ្ជាតិ..........................

៣- ទីកន្លែងកំណើត: ភូមិ............ឃុំ/សង្កាត់...................ស្រុក/ក្រុង...................ខេត្ត.................

**ខ- តួសេចក្តី**

៤- ឈ្មោះឪពុក......................មុខរបរ.....................................រស់ ☐ ស្លាប់ ☐

៥- ឈ្មោះម្តាយ.......................មុខរបរ.....................................រស់ ☐ ស្លាប់ ☐

៦- ឈ្មោះអាណាព្យាបាល.......................................មុខរបរ..........................................

៧- មានបងប្អូនបង្កើតប៉ុន្មាននាក់? ចំនួន...........នាក់ប្រុស..............នាក់ស្រី...............ជាកូនទី....

៨- ស្ថានភាពគ្រួសារ ក្រ ☐ មធ្យម ☐ ធូរធារ ☐

៩- បានចូលរៀនថ្នាក់មតេយ្យឬសាលាមតេយ្យឬទេ? បាន ☐ អត់ ☐

១០- ធ្លាប់បោះបង់ការសិក្សាឬទេ? ធ្លាប់ ☐ ទេ ☐ ថ្នាក់ទី........ ហេតុអ្វី...............................

**គ- សេចក្តីបញ្ចប់**

១១- អាសយដ្ឋានបច្ចុប្បន្ន ភូមិ.........ក្រុម.......ឃុំ សង្កាត់............ស្រុក ខណ្ឌ ក្រុង............ខេត្ត..........

១២- លេខទូរស័ព្ទមាតាបិតាឬអាណាព្យាបាល.................................

ហត្ថលេខាសាមីខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាបឋមសិក្សា ក្រុងព្រៃវែង

**ប្រវត្តិរូបសង្ខេប**

១- **ឈ្មោះសិស្ស:** ធីរិទ្ធ សុធារាជ ភេទ:ប្រុស អក្សរឡាតាំង: THIRITH SOTHEAREACH
រៀនថ្នាក់:ទី៥«ខ» នៃសាលាបឋមសិក្សាព្រៃវែងក្រុងស្ថិតនៅក្នុងកម្រងសាលាព្រៃវែងក្រុងភូមិលេខ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

២- **ថ្ងៃ ខែ ឆ្នាំកំណើត:** ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៦ សញ្ជាតិ ខ្មែរ

៣- **ទីកន្លែងកំណើត:** ភូមិលេខ៨ សង្កាត់ កំពង់លាវ ក្រុង ព្រៃវែង ខេត្តព្រៃវែង

៤- **ឈ្មោះឪពុក** : គង់ ធីរិទ្ធ មុខរបរ : គ្រូបង្រៀន រស់ ☑ ស្លាប់ ☐

៥- **ឈ្មោះម្ដាយ:** ម៉ម នារី មុខរបរ : អាជីវករ រស់ ☐ ស្លាប់ ☐

៦- **ឈ្មោះអាណាព្យាបាល** ណុប សម្រស់ មុខរបរ : ព្រះរាជអាជ្ញា

៧- **មានបងប្អូនបង្កើតប៉ុន្មាននាក់?** ចំនួន៣នាក់ ប្រុស៣នាក់ ស្រី០ ជាកូនទី៣

៨- **ស្ថានភាពគ្រួសារ:** ក្រ ☐ មធ្យម ☑ ធូរធារ ☐

៩- **បានចូលរៀនថ្នាក់មតេយ្យឬសាលាមតេយ្យឬទេ?** បាន ☑ អត់ ☐

១០- **ធ្លាប់បោះបង់ការសិក្សាឬទេ?** ធ្លាប់ ☐ ទេ ☑ ថ្នាក់ទី......... ហេតុអ្វី.......

១១- **អាសយដ្ឋានបច្ចុប្បន្ន:** ភូមិលេខ៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

១២- **លេខទូរស័ព្ទមាតាបិតាឬអាណាព្យាបាល:** ០៨៩ ៣២៨ ០៨៦(ឪពុក) ០១២ ៥៣០ ០៨៥(ម្ដាយ)

ហត្ថលេខាសាមីខ្លួន

**ធីរិទ្ធ សុធារាជ**

## ៧.១០.៣- ឧទាហរណ៍ទី៣ (ថ្នាក់ទី៥ និងទី៦)

**ប្រធាន**: ចូរប្អូនបំពេញប័ណ្ណសម្គាល់ខ្លួនរបស់ប្អូនតាមទម្រង់ខាងក្រោមឱ្យបានត្រឹមត្រូវ។

### គម្រោងតែង

**ក- សេចក្តីផ្តើម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**សាលាបឋមសិក្សា**..........................
កម្រង.......................

**ខ- តួសេចក្តី**

ប័ណ្ណសម្គាល់ខ្លួនសិស្ស

១- ឈ្មោះសិស្ស ....................................ភេទ........អក្សរឡាតាំង................. រៀនថ្នាក់ទី...........
នៃសាលា .........................................ស្ថិតនៅក្នុងកម្រងសាលា .............................
២- អត្តលេខសិស្ស: ................................
៣- ឆ្នាំសិក្សា: ................-……………………..
៤- ម្តាយឈ្មោះ: ................................... មុខរបរ:.........................................................
៥- ឪពុកឈ្មោះ: ................................... មុខរបរ:.........................................................
៦- អាណាព្យាបាល: ............................ មុខរបរ:.........................................................

**គ- សេចក្តីបញ្ចប់**

៧- ផ្នែកខាងក្រោយប័ណ្ណ អាសយដ្ឋានបច្ចុប្បន្នភូមិ..........................
៨- លេខទូរស័ព្ទមាតាបិតា/អាណាព្យាបាល.....................................

ថ្ងៃ.............. ខែ.......... ឆ្នាំ....... ព.ស.........
រាជធានី ខេត្ត...........ឈ ថ្ងៃទី.......ខែ..........ឆ្នាំ........

ហត្ថលេខានិងឈ្មោះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**សាលាបឋមសិក្សា កំពង់ពពិល**
កម្រង កំពង់ពពិល

## ប័ណ្ណសម្គាល់ខ្លួនសិស្ស

១- **ឈ្មោះសិស្ស**: ឆេង ម៉េងធី ភេទស្រីអក្សរឡាតាំង CHENG MENGTY រៀនថ្នាក់ទី៥«ក» នៃសាលាបឋមសិក្សាកំពង់ពពិលស្ថិតនៅក្នុងកម្រងសាលាកំពង់ពពិល
២- **អត្តលេខសិស្ស**: ១៧២៦០
៣- **ឆ្នាំសិក្សា**: ២០១៦-២០១៧
៤- **ម្តាយឈ្មោះ**: ម៉ុន ឆេងលី មុខរបរ: លក់ដូរ
៥- **ឪពុកឈ្មោះ**: ជា ឆេង មុខរបរ: គ្រូបង្រៀន
៦- **អាណាព្យាបាល**: ជា បួយ មុខរបរ: លក់ដូរ
៧- **អាសយដ្ឋានបច្ចុប្បន្ន**: ភូមិកំពង់ពពិល ឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង
៨- **លេខទូរស័ព្ទមាតាបិតាឬអាណាព្យាបាល**: ០៧៧ ៨៤៦ ៩៤៦និង ០១៥ ៩០៦ ០១៦

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំច ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨
**ហត្ថលេខានិងឈ្មោះ**

## ឯកសារពិគ្រោះ


១- សៀវភៅរៀនអក្សរថ្នាក់ទី៣ភាគ១ក្រសួងអប់រំ ឆ្នាំ១៩៨៤

២- សៀវភៅរៀនអក្សរថ្នាក់ទី៤ភាគ២ក្រសួងអប់រំ ឆ្នាំ១៩៨៨

៣- សៀវភៅរៀនអក្សរថ្នាក់ទី៥ភាគ១ក្រសួងអប់រំ ឆ្នាំ១៩៨៨

៤- សៀវភៅភាសាខ្មែរថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១១

៥- សៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី៣ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៣

៦- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត

៧- កម្មវិធីសិក្សាលម្អិតភាសាខ្មែរកម្រិតអប់រំមូលដ្ឋាន២០០៦

៨- ក្របខ័ណ្ឌកម្មវិធីសិក្សា២០១៥។

# បំណែងចែកខ្លឹមសារ និងប្រធានបទតែងសេចក្តី
## សម្រាប់បឋមសិក្សា ថ្នាក់ទី៣ ទី៤ ទី៥ និងទី៦

| ខ្លឹមសារ និងប្រធានបទ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ |
|---|---|---|---|---|
| ១- វិធីសាស្ត្រសរសេរតែងសេចក្តី<br>២- ប្រការគួរចៀសវាងក្នុងការសរសេរតែងសេចក្តី<br>៣- ប្រភេទតែងសេចក្តី<br>៤- គោលបំណង<br>៥- តែងសេចក្តីបែបពណ៌នា | √ | √ | √ | √ |
| ១- ប្រធានពណ៌នាអំពីមនុស្ស៖<br>*ឧទាហរណ៍ទី១* ប្រធាន: ចូរប្អូនពណ៌នាអំពី មិត្តភក្តិរបស់ប្អូនម្នាក់ដែលប្អូនបានស្គាល់។ | √ | √ | √ | √ |
| *ឧទាហរណ៍ទី២* ប្រធាន: ចូរប្អូនពណ៌នាអំពីលោកគ្រូរបស់ប្អូន។ | | | √ | √ |
| *ឧទាហរណ៍ទី៣* ប្រធាន: ចូរប្អូនពណ៌នាអំពីជីដូនរបស់ប្អូន។ | | | √ | √ |
| *ឧទាហរណ៍ទី៤* ប្រធាន: ចូរប្អូនពណ៌នាអំពីមន្ត្រីនគរបាលចរាចរណ៍ម្នាក់ដែលប្អូនបានស្គាល់។ | | | √ | √ |
| *ឧទាហរណ៍ទី៥* ប្រធាន: ចូរប្អូនពណ៌នាអំពីជនពិការម្នាក់ដែលប្អូនបានស្គាល់។ | | | √ | √ |
| ២- ប្រធានពណ៌នាអំពីសត្វ៖<br>*ឧទាហរណ៍ទី១* ប្រធាន: ចូរប្អូនពណ៌នាអំពីរូបរាងនិងផលប្រយោជន៍មេមាន់ដែលប្អូនចិញ្ចឹម។ | √ | √ | √ | √ |
| *ឧទាហរណ៍ទី២* ប្រធាន: ឪពុករបស់ប្អូនមានគោមួយនឹម។ ចូរប្អូនពណ៌នាអំពីគោណាមួយដែលប្អូនស្រឡាញ់។ | √ | √ | √ | √ |
| *ឧទាហរណ៍ទី៣* ប្រធាន: ចូរប្អូនពណ៌នាអំពីសត្វកុកដែលប្អូនបានស្គាល់ឬធ្លាប់បានឃើញ។ | √ | √ | √ | √ |
| *ឧទាហរណ៍ទី៤* ប្រធាន: ចូរប្អូនពណ៌នាអំពីសត្វក្ងោកដែលប្អូនបានស្គាល់ឬធ្លាប់បានឃើញ។ | | | √ | √ |
| *ឧទាហរណ៍ទី៥* ប្រធាន: ចូរប្អូនពណ៌នាអំពីសត្វសេកដែលប្អូនធ្លាប់បានឃើញ។ | √ | √ | √ | √ |
| *ឧទាហរណ៍ទី៦* ប្រធាន: ម្តាយប្អូនចិញ្ចឹមជ្រូកមួយក្បាល។ ចូរប្អូនពណ៌នាអំពីជ្រូកចិញ្ចឹមនោះ។ | √ | √ | √ | √ |
| *ឧទាហរណ៍ទី៧* ប្រធាន: មិត្តភក្តិរបស់ប្អូនម្នាក់បានឱ្យឆ្កែមួយដល់ប្អូន។ ចូរប្អូនពណ៌នាអំពីឆ្កែនោះ។ | √ | √ | √ | √ |
| *ឧទាហរណ៍ទី៨* ប្រធាន: ចូរប្អូនពណ៌នាអំពីសត្វឆ្មាដែលចិញ្ចឹមនៅក្នុងផ្ទះរបស់ប្អូន។ | √ | √ | √ | √ |

| | | | | |
|---|---|---|---|---|
| ***ឧទាហរណ៍ទី៩*** ប្រធា : ចូរប្អូនពណ៌នាអំពីសត្វដំរីដែលប្អូនបានឃើញ។ | | | √ | √ |
| ***ឧទាហរណ៍ទី១០*** លំហាត់សម្រាប់សិស្សអនុវត្តដោយហ្វឹកហាត់ធ្វើ<br>តែងសេចក្តីតាមគម្រោងដូចខាងក្រោម។ ប្រធាន: ចូរប្អូនពណ៌នាអំពី<br>សត្វក្របីដែលគ្រួសារប្អូនបានចិញ្ចឹម។ | | | √ | √ |
| ៣- ប្រធានពណ៌នាអំពីវត្ថុ៖<br>ឧទាហរណ៍ទី១ ប្រធាន : ចូរប្អូនរៀបរាប់ពីក្តារខៀន<br>ឈើនៅក្នុងថ្នាក់រៀនរបស់ប្អូន។ | √ | √ | √ | √ |
| ***ឧទាហរណ៍ទី២*** ប្រធាន: ចូរប្អូនរៀបរាប់ពីវត្ថុដែលមាននៅក្នុងថ្នាក់រៀន<br>របស់ប្អូន។ | √ | √ | √ | √ |
| ***ឧទាហរណ៍ទី៣*** ប្រធាន: ចូរប្អូនពណ៌នាអំពីបន្ទប់គេងរបស់ប្អូន។ | | | √ | √ |
| ***ឧទាហរណ៍ទី៤*** ប្រធាន: ចូរប្អូនរៀបរាប់ពីត្បាល់បុកគ្រឿងនិងអង្រែនៅក្នុង<br>ផ្ទះបាយរបស់ប្អូន។ | | | √ | √ |
| ***ឧទាហរណ៍ទី៥*** ប្រធាន: ចូរប្អូនរៀបរាប់ពីសម្ភារៈប្រើប្រាស់នៅក្នុងផ្ទះបាយ<br>របស់ប្អូន។ | | | √ | √ |
| ៤- ប្រធានពណ៌នាអំពីរុក្ខជាតិនិងផ្លែឈើ៖<br>***ឧទាហរណ៍ទី១*** ប្រធាន: ចូរប្អូនពណ៌នាអំពីដើមចេកណាំវ៉ាដែលដាំនៅក្នុង<br>ចម្ការនិងផលប្រយោជន៍របស់វា។ | | | √ | √ |
| ***ឧទាហរណ៍ទី២*** ប្រធាន: ចូរប្អូនពណ៌នាអំពីដើមត្នោតនិងអត្ថប្រយោជន៍<br>របស់វាឱ្យបានក្បោះក្បាយ។ | | | √ | √ |
| ***ឧទាហរណ៍ទី៣*** ប្រធាន: ចូរប្អូនពណ៌នាអំពីផ្លែស្វាយទុំមួយ និងផល<br>ប្រយោជន៍របស់វាឱ្យបានក្បោះក្បាយ។ | √ | √ | | |
| ***ឧទាហរណ៍ទី៤*** ប្រធាន: ចូរប្អូនពណ៌នាអំពីផ្លែចេកអំបូងទុំមួយស្នូងនិង<br>ផលប្រយោជន៍របស់វាឱ្យបានក្បោះក្បាយ ។ | √ | √ | | |
| ***ឧទាហរណ៍ទី៥*** ប្រធាន: ចូរប្អូនពណ៌នាអំពីផ្លែក្រូចឃ្វិចទុំនិង<br>ផលប្រយោជន៍របស់វាឱ្យបានក្បោះក្បាយ។ | √ | √ | | |
| ៥- ប្រធានពណ៌នាអំពីទេសភាព៖<br>***ឧទាហរណ៍ទី១*** ប្រធាន: ចូរប្អូនពណ៌នាអំពីសួនបន្លែក្នុងសាលារៀនរបស់<br>ប្អូន។ | | | √ | √ |
| ***ឧទាហរណ៍ទី២*** ប្រធាន: ចូរប្អូនពណ៌នាអំពីទេសភាពវាលស្រែនៅ<br>ពេលប្រជាកសិករកំពុងដកស្ទូង។ | | | √ | √ |
| ***ឧទាហរណ៍ទី៣*** ប្រធាន: ចូរប្អូនពណ៌នាអំពីទេសភាពវាលស្រែនៅរដូវ<br>ចម្រូត។ | | | √ | √ |
| ***ឧទាហរណ៍ទី៤*** ប្រធាន : ចូរប្អូណពណ៌នាអំពីទេសភាពនៅមាត់ទន្លេដែល<br>ប្អូនៗបានទៅស្ទូចត្រី។ | | | √ | √ |
| ***ឧទាហរណ៍ទី៥*** ប្រធាន: សាលារៀនរបស់ប្អូនបានរៀបចំកម្មវិធីមួយដើម្បី<br>ចូលរួមអបអរសាទរទិវាអន្តរជាតិកុមារមួយមិថុនា។ ចូរប្អូនពណ៌នាឱ្យបាន | | | √ | √ |

| | | | | |
|---|---|---|---|---|
| ក្បោះក្បាយ។ | | | | |
| ***ឧទាហរណ៍ទី៦*** ប្រធាន: ចូរប្អូនពណ៌នាឱ្យបានគ្រប់ជ្រុងជ្រោយអំពីទិដ្ឋភាពនិងសកម្មភាពនៅចំណតរថយន្តក្រុង។ | | | √ | √ |
| ***ឧទាហរណ៍ទី៧*** ប្រធាន: ចូរប្អូនពណ៌នាអំពីទេសភាពសួនបន្លែនៅផ្ទះរបស់ប្អូន។ | | | √ | √ |
| ***ឧទាហរណ៍ទី៨*** ប្រធាន: ចូរអ្នកពណ៌នាអំពីទេសភាពវត្តឯកភ្នំ។ | | | √ | √ |
| ៦- ប្រធានពណ៌នាអំពីទីកន្លែង៖<br>***ឧទាហរណ៍ទី១*** ប្រធាន: ចូរប្អូនពណ៌នាអំពីសារមន្ទីរជាតិដែលប្អូនបានទៅទស្សនា។ | | | √ | √ |
| ***ឧទាហរណ៍ទី២*** ប្រធាន: ចូររៀបរាប់អំពីរមណីយដ្ឋានគិរីរម្យដែលប្អូនបានទៅកម្សាន្តកាលពីថ្ងៃអាទិត្យមុន។ | | | √ | √ |
| ***ឧទាហរណ៍ទី៣*** ប្រធាន: ចូរប្អូនរៀបរាប់អំពីទិដ្ឋភាពវត្តនៅក្នុងភូមិអ្នកនារដូវបុណ្យភ្ជុំបិណ្ឌឱ្យបានក្បោះក្បាយ។ | | | √ | √ |
| ***ឧទាហរណ៍ទី៤*** លំហាត់សម្រាប់សិស្សអនុវត្តដោយហ្វឹកហាត់ធ្វើសេចក្តីអធិប្បាយតាមគម្រោងដូចខាងក្រោម។ ប្រធាន: ចូរប្អូនពណ៌នាអំពីសាលារៀន។ | | | √ | √ |
| ៧- ប្រធានពណ៌នាអំពីព្រឹត្តិការណ៍៖<br>***ឧទាហរណ៍ទី១*** ប្រធាន: ចូរប្អូនពណ៌នា អំពីគ្រោះថ្នាក់ចរាចរណ៍ដែលប្អូនបានឃើញ។ | √ | √ | √ | √ |
| ***ឧទាហរណ៍ទី២*** ប្រធាន: ចូរប្អូនពណ៌នាអំពីព្រឹត្តិការណ៍គ្រោះទឹកជំនន់នៅក្នុងភូមិមួយ។ | | | √ | √ |
| ***ឧទាហរណ៍ទី៣*** លំហាត់សម្រាប់សិស្សអនុវត្តដោយហ្វឹកហាត់ធ្វើសេចក្តីអធិប្បាយតាមគម្រោងដូចខាងក្រោម។ ប្រធាន: ចូរប្អូនពណ៌នាអំពីទឹកភ្លៀងដែលប្អូនបានឃើញឱ្យបានក្បោះក្បាយ។ | | | √ | √ |
| ៨- ប្រធានពណ៌នាបែបនិទានរឿង៖<br>***ឧទាហរណ៍ទី១*** ប្រធាន: កាលពីថ្ងៃអាទិត្យសប្តាហ៍មុនជីដូនរបស់ប្អូនបាននិទានរឿងមួយឱ្យប្អូនស្តាប់។ ចូរប្អូនសរសេររៀបរាប់រឿងនិទាននោះឡើងវិញឱ្យបានក្បោះក្បាយ។ | | | √ | √ |
| ៩- ប្រធានសរសេរសំបុត្រសួរសុខទុក្ខ៖<br>***ឧទាហរណ៍ទី១*** ប្រធាន: ចូរប្អូនសរសេរសំបុត្រមួយច្បាប់ដើម្បីសួរសុខទុក្ខមិត្តរបស់ប្អូនដែលបានទៅសិក្សានៅឆ្ងាយពីប្អូន។ | | | √ | √ |
| ***ឧទាហរណ៍ទី២*** ប្រធាន: ចូរអ្នកសរសេរសំបុត្រសួរសុខទុក្ខឪពុកម្តាយរបស់អ្នកនៅស្រុកកំណើត។ | | | √ | √ |
| ***ឧទាហរណ៍ទី៣*** ប្រធាន: ចូរប្អូនសរសេរសំបុត្រមួយច្បាប់ដើម្បីសួរសុខទុក្ខសត្យាមិត្តរបស់ប្អូន។ | | | √ | √ |

| | | | | |
|---|---|---|---|---|
| ***ឧទាហរណ៍ទី៤*** ប្រធានៈ ចូរប្អូនសរសេរសំបុត្រសួរសុខទុក្ខមិត្តរបស់ប្អូនម្នាក់ដែលមានទុក្ខដោយសារគ្រោះ ខ្យល់ព្យុះប៉ះពាល់គេហដ្ឋានដែលកំពុងរស់នៅសព្វថ្ងៃ។ | | | √ | √ |
| ***ឧទាហរណ៍ទី៥*** ប្រធានៈ ចូរប្អូនសរសេរសំបុត្រមួយច្បាប់ទៅសួរសុខទុក្ខបងស្រីរបស់ប្អូនដែលបានបែកគ្នាពីស្រុកកំណើតមកសិក្សានៅរាជធានីភ្នំពេញ។ | | | √ | √ |
| ១០- សំណេរបំពេញពាក្យសុំផ្សេងៗ៖ ***ឧទាហរណ៍ទី១*** ប្រធានៈ ចូរប្អូនបំពេញ ពាក្យសុំអនុញ្ញាតច្បាប់ឱ្យបានត្រឹមត្រូវ។ | | | √ | √ |
| ***ឧទាហរណ៍ទី២*** ប្រធានៈ ចូរប្អូនបំពេញប្រវត្តិរូបរបស់ប្អូនដូចខាងក្រោមឱ្យបានច្បាស់លាស់។ | | | √ | √ |
| ***ឧទាហរណ៍ទី៣*** ប្រធានៈ ចូរប្អូនបំពេញនូវបណ្ណសម្គាល់ខ្លួនរបស់ប្អូន។ | | | √ | √ |